## ក្រសួងអប់រំ យុវជន និងកីឡា
Ministry of Education, Youth and Sport

## វិទ្យាស្ថានជាតិអប់រំ
National Institute of Education

# និក្ខេបបទ

# ការអនុវត្ត និងបញ្ហាប្រឈមនៃកម្មវិធីអាហារូបករណ៍សិស្សក្រីក្រ នៅបឋមសិក្សាក្នុងរាជធានីភ្នំពេញ

**"Implementation and Challenges of Pro-Poor Students Scholarship Program at Primary in Phnom Penh"**

ដោយ/**By**


**ស្រី ម៉ៅ**

**SREY MAO**


**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦**

**Accepted in Partial Fulfillment of Requirement for Master's Degree of Educational Administration (MEA), Batch 6**

**ឯកទេស៖ គ្រប់គ្រងអប់រំ**

**Specialties: Education Management**

**ឆ្នាំសិក្សា ២០១៧ - ២០១៩**

**Academic Year 2017-2019**


**ឧបត្ថម្ភដោយ ៖ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា**

Supported by: Cambodia International Education Support Foundation (CIESF)

## ក្រសួងអប់រំ យុវជន និងកីឡា
Ministry of Education, Youth and Sport

## វិទ្យាស្ថានជាតិអប់រំ
National Institute of Education

# និក្ខេបបទ

# ការអនុវត្ត និងបញ្ហាប្រឈមនៃកម្មវិធីអាហារូបករណ៍សិស្សក្រីក្រ នៅបឋមសិក្សាក្នុងរាជធានីភ្នំពេញ

**“Implementation and Challenges of Pro-Poor Students Scholarship Program at Primary in Phnom Penh”**

ដោយ/**By**

**ស្រី ម៉ៅ**

**SREY MAO**

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់**

**ផ្នែក: គ្រប់គ្រងអប់រំ ជំនាន់ទី៦**

**ឯកទេស: ការគ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា: ២០១៧ - ២០១៩**

**សាស្ត្រាចារ្យដឹកនាំ៖ បណ្ឌិត នី រដ្ឋា**

**សាស្ត្រាចារ្យដឹកនាំរង៖ លោកស្រី ប៊ុន សុផានី**

**ឧបត្ថម្ភដោយ ៖ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា**

Supported by: Cambodia International Education Support Foundation (CIESF)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ:**៩៦២៩ **អយក.** ១៩

**(ការសម្ងាត់)**

## លិខិតឧទ្ទេសនាម

**យោង ៖** -បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-ឯ.ឧ បណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯ.ឧបណ្ឌិត សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-ឯកឧត្តម លឹម សុធា | អគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ | សមាជិក |
| ៤-លោកបណ្ឌិត នូវ វីរ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-ឯកឧត្តម នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦-លោកជំទាវបណ្ឌិត យូន វិច្ឆិកា | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៧-លោក ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯ.ឧបណ្ឌិត ម៉ុក សារ៉ុម | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៩-ឯ.ឧបណ្ឌិត ឌី ខាំបូលី | អគ្គនាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១០-ឯ.ឧ បណ្ឌិត សិន សេងហុក | នាយកដ្ឋាននីតិកម្ម | សមាជិក |
| ១១-លោកបណ្ឌិត សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១២-លោកបណ្ឌិត ឈូក ច័ន្ទឆាយា | នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ | សមាជិក |
| ១៣-លោកបណ្ឌិត នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោកជំទាវ អស់លោក ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅនៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ សុក្រ ១ រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០១៩

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក

-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"

-សាមីខ្លួន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ - ឯកសារវិទ្យាស្ថានជាតិអប់រំ

# សេចក្តីប្រកាសអះអាងរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថានិក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា "**ការអនុវត្ត និងបញ្ហាប្រឈមនៃកម្មវិធីអាហារូបករណ៍សិស្សក្រីក្រនៅបឋមសិក្សាក្នុងរាជធានីភ្នំពេញ**" សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានអប់រំ គឺជាស្នាដៃផ្ទាល់របស់ខ្ញុំបាទទាំងស្រុង។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់សញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយឡើយទេ។ គ្មានសេចក្តីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវនេះ ពិតជាចងក្រងដោយខ្ញុំបាទផ្ទាល់ពិតប្រាកដមែន។

ថ្ងៃអង្គារ ១៤កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៩

**ហត្ថលេខាបេក្ខជន**

**ស្រី ម៉ៅ**

# លិខិតបញ្ជាក់

បណ្ឌិត ជី វដ្ឋា ជាសាស្ត្រាចារ្យដឹកនាំ

លោកស្រី ប៊ុន សុផានី ជាសាស្ត្រាចារ្យដឹកនាំរង

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោក ស្រី ម៉ៅ ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ "**ការអនុវត្ត និងបញ្ហាប្រឈមនៃកម្មវិធីអាហារូបករណ៍សិស្សក្រីក្រនៅបឋមសិក្សាក្នុងរាជធានីភ្នំពេញ**" ពិតប្រាកដមែន។

ថ្ងៃអង្គារ ១៤កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៩

| | |
|---|---|
| ....................................... | ..................................... |
| បណ្ឌិត ជី វដ្ឋា | លោកស្រី ប៊ុន សុផានី |
| .................................... | នាយិការងវិទ្យាស្ថានជាតិអប់រំ |

## សេចក្តីថ្លែងអំណរគុណ

ជាបឋម ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ លោកអ្នកមានគុណទាំងពីរ ភរិយា បងប្អូន និងមិត្តភក្តិទាំងអស់ដែលបានជួយឧបត្ថម្ភគាំទ្រទាំងផ្នែកថវិកាសម្ភារៈ ចិត្ត គំនិត ប្រាជ្ញា និងផ្នែកស្មារតីដល់ខ្ញុំបាទខណៈពេលសិក្សានាពេលកន្លងមក។

ខ្ញុំបាទសូមអនុញ្ញាតគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះរាជរដ្ឋាភិបាលកម្ពុជា និងថ្នាក់ដឹកនាំប្រទេសគ្រប់លំដាប់ថ្នាក់ ដែលបានខិតខំកសាងប្រទេសជាតិឱ្យមានសន្តិភាព ស្ថេរភាព និងការអភិវឌ្ឍលើគ្រប់វិស័យរហូតមកដល់បច្ចុប្បន្ននេះ ប្រទេសជាតិមានសន្តិភាព ស្ថេរភាព និងការអភិវឌ្ឍ ទើបការអប់រំមានភាពសម្បូរបែប ល្អប្រសើរ មានគុណភាព និងមានការប្រកួតប្រជែងក្នុងតំបន់ និងសកលលោក។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងក្រៃលែងចំពោះក្រសួងអប់រំ យុវជន និងកីឡា និងថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់របស់ក្រសួងអប់រំ ដែលបានខិតខំប្រឹងប្រែងយ៉ាងសស្រាក់សស្រាំក្នុងការកសាង និងអភិវឌ្ឍវិស័យអប់រំនៅកម្ពុជា ឱ្យមានភាពល្អប្រសើរគួរជាទីមោទនៈពោលគឺបានកសាងធនធានមនុស្សពេញលេញជូនជាតិមាតុភូមិ។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងក្រៃលែងដល់វិទ្យាស្ថានជាតិអប់រំ ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់នៃវិទ្យាស្ថានជាតិអប់រំ និងជាពិសេសអង្គការមូលនិធិគាំទ្រការអប់រំអន្តរជាតិកម្ពុជា(Cambodia International Education Support Foundation, CIESF) ដែលបានរៀបចំកម្មវិធី និងផ្តល់អាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនេះឡើង និងផ្តល់ឱកាសសម្រាប់ខ្ញុំបាទបានប្រឡងជាប់ ហើយបានចូលសិក្សានៅវិទ្យាស្ថានជាតិអប់រំ ក្នុងឆ្នាំសិក្សា (២០១៧-២០១៩) នាពេលកន្លងទៅថ្មីៗនេះ។

ខ្ញុំបាទសូមគោរពថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ គណៈកម្មការគ្រប់គ្រង និងដឹកនាំការបណ្តុះបណ្តាលវគ្គសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំ នៃវិទ្យាស្ថានជាតិអប់រំគ្រប់លំដាប់ថ្នាក់ ព្រមទាំងឯកឧត្តម លោកជំទាវ លោក លោកស្រីជាសាស្ត្រាចារ្យទាំងអស់ ដែលបានចំណាយនូវពេលវេលាដ៏មានតម្លៃផ្ទេរចំណេះដឹង បំណិន ឥរិយាបថ បទពិសោធន៍ និងមេរៀនជីវិតល្អៗជាច្រើន ពិសេសលើផ្នែកគ្រប់គ្រងដឹកនាំ ការរៀបចំ និងធ្វើផែនការក្នុងវិស័យអប់រំ មកដល់ខ្ញុំបាទផ្ទាល់ និងមិត្តរួមជំនាន់ដ៏ទៃទៀតដូចៗគ្នា និងស្មើៗគ្នា។ ជាពិសេស ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងអនេកដែលរកអ្វីមកប្រៀបផ្ទឹមពុំបានជូនចំពោះ លោកសាស្ត្រាចារ្យបណ្ឌិត **នី រដ្ឋា** ជាសាស្ត្រាចារ្យណែនាំ និងលោកស្រី **ម៉ុន សុផានី** ជាសាស្ត្រាចារ្យជំនួយ ដែលលោកទាំងទ្វេតែងតែចំណាយពេលដ៏មានតម្លៃពន្យល់ណែនាំពីចំណុចគន្លឹះល្អៗនៃដំណាក់កាលមួយទៅដំណាក់កាលមួយ និងគ្រប់ជំហានទាំងអស់ រហូត

ទើបធ្វើឱ្យការសិក្សាស្រាវជ្រាវរបស់ខ្ញុំបានសម្រេចជោគជ័យ បញ្ចប់យ៉ាងរលូន ប្រកបដោយគុណភាព និងប្រសិទ្ធភាពសម្រាប់បម្រើឱ្យការអភិវឌ្ឍវិស័យអប់រំកម្ពុជា។ មួយចំណែកទៀត ខ្ញុំបាទសូមថ្លែងអំណរគុណចំពោះ លោក លោកស្រីជាមិត្តរួមជំនាន់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំទាំងអស់ ខ្ញុំពិតជាមានមោទនភាពដែលមានលោក លោកស្រីជាមិត្ត ព្រោះលោកអ្នកទាំងអស់គ្នា ជាមនុស្សដែលមានសមានចិត្តល្អ ក្នុងការចែករំលែកនូវចំណេះដឹង បំណិន ឥរិយាបថ បទពិសោធន៍ និងមេរៀនជីវិតល្អៗសម្រាប់ខ្ញុំ។

ខ្ញុំបាទសូមថ្លែងអំណរគុណដល់ គណៈគ្រប់គ្រងមន្ទីរអប់រំរាជធានីភ្នំពេញ ការិយាល័យអប់រំខណ្ឌ គណៈគ្រប់គ្រងសាលា បុគ្គលិកទីចាត់ការ លោកគ្រូ អ្នកគ្រូ ព្រមទាំងប្អូនៗសិស្សានុសិស្ស និងមាតាបិតាឬអ្នកអាណាព្យាបាលនៃសាលាបឋមសិក្សាគោលដៅក្នុងរាជធានីភ្នំពេញ ដែលបានសហការ និងសម្របសម្រួលយ៉ាងល្អប្រសើរក្នុងដំណើរការចុះប្រមូលទិន្នន័យ ដែលជាកត្តារួមចំណែកមួយយ៉ាងធំធេង ក្នុងការធ្វើឱ្យការសិក្សាស្រាវជ្រាវរបស់ខ្ញុំទទួលបានលទ្ធផលជោគជ័យមួយរយភាគរយ។

ខ្ញុំបាទសូមឧទ្ទិសនូវស្នាដៃស្រាវជ្រាវនេះ ជូនចំពោះដួងវិញ្ញាណក្ខន្ធបុព្វបុរសខ្មែរគ្រប់សម័យកាល ដែលបានតស៊ូដើម្បីបុព្វហេតុជាតិមាតុភូមិ និងជូនចំពោះដួងវិញ្ញាណក្ខន្ធញាតិការប្រាំពីរសន្តានដែលបានបែកកាយរំលាយក្ខន្ធទៅកាន់បរលោកហើយ និងសូមលោកទាំងនោះបែរភក្ត្រាងាកក្រោយឱ្យពរជ័យដល់ប្រទេសកម្ពុជាប្រកបដោយសន្តិភាព និងការអភិវឌ្ឍជានិច្ចនិរន្តរ៍ទៅ។

ជាទីបញ្ចប់ ខ្ញុំបាទសូមបួងសួងដល់អស់វត្ថុស័ក្តិសិទ្ធក្នុងលោក ពិសេសក្នុងព្រះរាជាណាចក្រកម្ពុជា សូមប្រសិទ្ធពរជ័យសិរីបវរមហាប្រសើរ ជូនចំពោះលោកអ្នកមានគុណទាំងពីរ និងអ្នកទាំងអស់គ្នា សូមមានសុខភាពល្អបរិបូរណ៍ កម្លាំងកាយ ប្រាជ្ញា និងស្មារតីមាំមួន ភ្លឺថ្លា មានសេចក្តីសុខ និងសេចក្តីចម្រើន រកទទួលទានមានបាន កើតកាលវាលគុម្ព ត្រជាក់ត្រជុំ សុខដុមរមនា និងសម្រេចបានជោគជ័យគ្រប់ភារកិច្ចជានិច្ចនិរន្តរ៍ និងជួបប្រសព្វនូវពុទ្ធពរទាំងបួនប្រការគឺ៖ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ!**

# មូលន័យសង្ខេប

ការសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី ការអនុវត្ត និងបញ្ហាប្រឈមនៃកម្មវិធីអាហារូបករណ៍សិស្សក្រីក្រនៅបឋមសិក្សាក្នុងរាជធានីភ្នំពេញ ដោយផ្អែកលើផ្នែកសំខាន់នៃគោលការណ៍ប្រតិបត្តិ និងសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីកម្មវិធីផ្តល់អាហារូបករណ៍នៅបឋមសិក្សាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ទោះយ៉ាងណា ការសិក្សានេះមិនបានគ្រប ដណ្តប់ទូទាំងប្រទេសនោះទេ។ សាលាបឋមសិក្សាគោលដៅចំនួនតែ៧ប៉ុណ្ណោះ ដែលត្រូវបានជ្រើសរើសចេញពីខណ្ឌ ៧ផ្សេងគ្នា នៅក្នុងរាជធានីភ្នំពេញ។ មនុស្សសរុបចំនួន១៧២នាក់ ត្រូវបានបំពេញកម្រងសំណួរតាមវិធីសាស្រ្តផ្សេងៗពីគ្នា រួមទាំងមនុស្សសំខាន់ៗដូចជា ប្រធានមន្ទីរអប់រំ មន្ត្រីការិយាល័យនៃមន្ទីរអប់រំ មន្ត្រីការិយាល័យអប់រំខណ្ឌ នាយកនិងនាយិកា គ្រូបន្ទុកថ្នាក់ សិស្សក្រីក្រដែលបានទទួលអាហារូបករណ៍ពីកម្មវិធី និងអាណាព្យាបាលរបស់សិស្ស។

ការសិក្សាស្រាវជ្រាវនេះ បានបង្ហាញថា ៨៣.៣ភាគរយ ទទួលព័ត៌មានស្តីពីការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ តាមរយៈលោកគ្រូ អ្នកគ្រូ និងពេលគោរពទង់ជាតិ ឬបិទផ្សាយព័ត៌មានតាមក្តារខៀននៅសាលារៀន ជាការផ្សព្វផ្សាយមានប្រសិទ្ធភាពជាងគេបំផុត ខណៈត្រឹមតែ ១៦.៧ភាគរយប៉ុណ្ណោះ បានដឹងព័ត៌មានតាមរយៈភូមិ សង្កាត់ ឬអាជ្ញាធរ។ ការរកឃើញមួយទៀតបានបង្ហាញថា ការចុះផ្ទៀងផ្ទាត់នៅតាមខ្នងផ្ទះសិស្សដោយគណៈកម្មការមូលដ្ឋានមានតែ ១២.១ភាគរយ ក្នុងចំណោមសិស្សទាំងអស់ ដូច្នេះនាំឱ្យការជ្រើសរើសសិស្សអាហារូបករណ៍ពុំបានចំគោលដៅពិតប្រាកដទេ។

ទន្ទឹមនឹងនេះដែរ ការសិក្សាស្រាវជ្រាវក៏បានរកឃើញនូវបញ្ហាប្រឈម មួយចំនួនដូចជា ៦៩% នៃសិស្សពីសាលាដែលបានជ្រើសរើស មានបញ្ហាខ្លាំងចំពោះជីវភាព ៥៩%ក្នុងចំណោមពួកគេ ខ្វះខាតសម្ភារៈសិក្សា និង៣៩%ក្នុងចំណោមពួកគេ ខ្វះខាតមធ្យោបាយធ្វើដំណើរប្រចាំថ្ងៃទៅសាលារៀន។ លើសពីនេះទៀត ១៩% នៃអាណាព្យាបាលបានប្រឈមនិងផលលំបាកហើយចំណាយពេល វេលាច្រើន ក្នុងការធ្វើដំណើរទៅចូលរួមបើកប្រាក់អាហារូបករណ៍។ ជាចុងក្រោយមានសំណូមពរមួយចំនួនពីគ្រប់ភាគីពាក់ព័ន្ធ ដូចជា៖ (១)ការបង្កើនថវិកាបន្ថែមសម្រាប់មន្ត្រីទទួលបន្ទុកលើការងារអាហារូបករណ៍ (២)ការបង្កើនវគ្គបំប៉នសមត្ថភាពស្តីពីការគ្រប់គ្រងកម្មវិធីអាហារូបករណ៍ (៣)ការបង្កើនយន្តការ និងកញ្ចប់ថវិកាក្នុងការត្រួតពិនិត្យតាមដាន និងគ្រប់គ្រង (៤)ការបង្កើនចំនួនសិស្សអាហារូបករណ៍។ ការផ្តល់អាហារូបករណ៍សិស្សក្រីក្រដល់គ្រឹះស្ថានតាមចំនួនជាក់លាក់មួយ ដើម្បីលើកកម្ពស់សមភាពយេនឌ័រ ក្នុងនោះចំនួនសិស្សស្រីមាន ៦០% និងសិស្សប្រុសចំនួន ៤០%។ ហេតុផលដែលគិតថាការផ្តល់អាទិភាពឱ្យសិស្សស្រីច្រើនជាងសិស្សប្រុស ដោយសារសិស្សស្រីជាសិស្សងាយរងការបោះបង់ការសិក្សា តែលទ្ធផលសិក្សា ល្អជាងសិស្សប្រុស។

## Abstract

The research on the Implementation and Challenges of Pro-Poor Students Scholarship Program at Primary in Phnom Penh is based on the executive principle and guidance from the Ministry of Education, Youth and Sport on national and sub national scholarship programs. However, the study was not cover the whole country; only seven target schools with scholarships for poor students in different seven districts in Phnom Penh were selected. A total of 172 correspondents were interviewed in various ways including key individuals such as directors of education, officers of education, officers of district education, principals of schools, teachers in charge of the poor-student classes who received scholarships from the programs and guardians of students.

The study showed that 83.3% of scholarship information was reached by poor students through teachers and flags respecting time or posting information on blackboards at schools as the most effective outlets while only 16.7% was known from villages, neighborhoods or authorities. Another finding showed that the home-based verification from local committees was only 12.1% among all students so that the selection for scholarship programs was not in the right approach.

At the same time, the study also found several challenges that 64% of the students at the selected schools had serious difficulties in their living, 59% needed study materials and 39% lacked daily transportation to and from schools. In addition, 19% of parents faced difficulties and took long time for traveling to receive too little supports from the scholarship programs. At last, there are also some suggestions from all concerned parties: (1) increasing funding for scholarship officers, (2) increasing trainings on program management; (3) increasing the mechanism and budget for monitoring and management; (4) increasing the amount of scholar students. Providing scholarships to poor students at definite institutions to promote gender equality, of which 60% are female and 40% are male. Reasons for prioritizing female more than male because female students are more vulnerable to drop out of school, but better performing.

# បញ្ជីមាតិកា

ទំព័រ

សេចក្តីប្រកាសអះអាងរបស់បេក្ខជន ........ i
លិខិតបញ្ជាក់ ........ ii
សេចក្តីថ្លែងអំណរគុណ ........ iii
មូលន័យសង្ខេប ........ v
បញ្ជីមាតិកា ........ vii
បញ្ជីអក្សរកាត់ ........ x
បញ្ជីតារាង ........ xi
បញ្ជីក្រាហ្វិក ........ xii
បញ្ជីដ្យាក្រាម ........ xiii
ជំពូកទី១ ........ 1
សេចក្តីផ្តើម ........ 1
ជំពូកទី១ ........ 1
សេចក្តីផ្តើម ........ 1
១.១. លំនាំបញ្ហានៃការស្រាវជ្រាវ ........ 1
១.២. បញ្ហានៃការស្រាវជ្រាវ ........ 2
១.៣. គោលបំណងនៃការស្រាវជ្រាវ ........ 2
១.៤. សំណួរស្រាវជ្រាវ ........ 3
១.៥. សារៈសំខាន់នៃការស្រាវជ្រាវ ........ 3
១.៦. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ 3
១.៦.១. វិសាលភាពនៃការស្រាវជ្រាវ ........ 3
១.៦.២. ដែនកំណត់នៃការស្រាវជ្រាវ ........ 3
១.៧. រចនាសម្ព័ន្ធស្រាវជ្រាវ ........ 4
ជំពូកទី២ ........ 1
ការរំលឹកទ្រឹស្តី ........ 1
ជំពូកទី២ ........ 5

ការរំលឹកទ្រឹស្តី......5
២.១. ព័ត៌មានទូទៅ......5
២.២. និយមន័យពាក្យគន្លឹះ......5
២.៣. កម្មវិធីអាហារូបករណ៍ហៃទី......6
២.៤. គោលនយោបាយទៅលើកំណែទម្រង់នៃការបង្រៀន និងរៀននៅប្រទេសថៃ......7
២.៤.១. ប្រព័ន្ធអប់រំដោយឥតបង់ថ្លៃរយៈពេល១២ឆ្នាំ......7
២.៤.២. មូលនិធិកំចីសម្រាប់ការអប់រំ......7
២.៤.៣. គម្រោងរៀនតាមបែបអឺមែលអន្តរកម្ម......7
២.៤.៤. សិក្សាពីការងារដើម្បីចាប់យកគម្រោងនៃក្តីស្រម៉ៃរបស់អ្នក......8
២.៥. ហិរញ្ញប្បទានរបស់ដៃគូរអភិវឌ្ឍ......8
២.៦. គោលបំណងរួមនៃកម្មវិធីអាហារូបករណ៍......8
២.៧. ការរក្សាសិស្សឱ្យនៅក្នុងប្រព័ន្ធអប់រំតាមរយៈកម្មវិធីអាហារូបករណ៍......9
២.៨. លក្ខខណ្ឌនៃការផ្តល់អាហារូបករណ៍......9
២.៩. នីតិវិធីនៃការផ្តល់អាហារូបករណ៍......10
២.១០. គណៈកម្មការគ្រប់គ្រងអាហារូបករណ៍មូលដ្ឋាន......11
២.១០.១. តួនាទី និងភារកិច្ច......11
២.១០.២. របៀបរបបការងារ......13
២.១១. គណៈកម្មការគ្រប់គ្រងអាហារូបករណ៍ក្រុង ស្រុក ខណ្ឌ......13
២.១១.១. សមាសភាព......13
២.១១.២. ភារកិច្ច និងការទទួលខុសត្រូវ......13
២.១២. គណៈកម្មការគ្រប់គ្រងអាហារូបករណ៍រាជធានី ខេត្ត (គ.អ.ខ.)......14
២.១២.១. សមាសភាព......14
២.១២.២. ភារកិច្ច និងការងារទទួលខុសត្រូវ......14
២.១៣. ការបើកប្រាក់អាហារូបករណ៍ជូនសិស្សក្រីក្រ......16
២.១៤. យន្តការដោះស្រាយបណ្តឹងតវ៉ា......16
២.១៤.១. របៀបប្តឹងតវ៉ា......16
២.១៤.២. គណៈកម្មការដោះស្រាយបណ្តឹងតវ៉ា......16
២.១៤.៣. ដំណើរការដោះស្រាយបណ្តឹងតវ៉ា......17
ជំពូកទី៣......18

វិធីសាស្ត្រស្រាវជ្រាវ ..... 18
៣.១. វិធីសាស្ត្រនៃការស្រាវជ្រាវ ..... 18
៣.២. ដំណើរការនៃការជ្រើសរើសសំណាកគំរូ ..... 18
៣.៣. ឧបករណ៍សម្រាប់ប្រមូលទិន្នន័យ ..... 20
៣.៣.១. កម្រងសំណួរសម្រាប់បំពេញ ..... 20
៣.៣.២. កម្រងសំណួរសម្រាប់សម្ភាស ..... 21
៣.៤ ដំណើរការនៃការប្រមូលទិន្នន័យ ..... 21
៣.៥. វិធីសាស្ត្រវិភាគទិន្នន័យ ..... 22
ជំពូកទី៤ ..... 23
លទ្ធផល និងការពិភាក្សា ..... 23
៤.១ ព័ត៌មានទូទៅរបស់អាណាព្យាបាល និងសិស្សទទួលអាហារូបករណ៍ ..... 23
៤.១.១ ព័ត៌មានទូទៅរបស់សិស្សដែលបានទទួលអាហារូបករណ៍សិស្សក្រីក្រ ..... 24
៤.១.២ ព័ត៌មានទូទៅរបស់អាណាព្យាបាលសិស្សអាហារូបករណ៍ក្រីក្រ ..... 26
៤.២. ព័ត៌មានលម្អិតស្តីពីការទទួលបានអាហារូបករណ៍ ..... 26
៤.២.១ ការផ្សព្វផ្សាយអំពីកម្មវិធីអាហារូបករណ៍ ..... 26
៤.២.២ ការជ្រើសរើសសិស្សអាហារូបករណ៍ ..... 28
៤.២.៣ ប្រសិទ្ធភាពនៃការផ្តល់អាហារូបករណ៍ ..... 32
៤.២.៤ ការជំរុញការផ្តល់អាហារូបករណ៍ ..... 37
៤.២.៥ យន្តការនៃការគ្រប់គ្រង ..... 40
៤.២.៦ កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ ..... 42
៤.២.៧ បញ្ហាប្រឈមនានា ..... 43
៤.៣ ការពិភាក្សាលើលទ្ធផល ..... 45
ជំពូកទី៥ ..... 47
សេចក្តីសន្និដ្ឋាន និងសំណូមពរ ..... 47
៥.១- សេចក្តីសន្និដ្ឋាន ..... 47
៥.២- សំណូមពរ និងអនុសាសន៍ ..... 48

# បញ្ជីអក្សរកាត់

| | |
|---|---|
| គ.អ.ខ. | គណៈកម្មការគ្រប់គ្រងអាហារូបករណ៍រាជធានី ខេត្ត |
| គ.អ.ស. | គណៈកម្មការគ្រប់គ្រងអាហារូបករណ៍ក្រុង ស្រុក ខណ្ឌ |
| គ.អ.ម. | គណៈកម្មការគ្រប់គ្រងអាហារូបករណ៍សាលារៀនមូលដ្ឋាន |
| អ.យ.ក. | ក្រសួងអប់រំ យុវជន និងកីឡា |
| MoEYS | Ministry of Education, Youth and Sport |
| NIE | National Institute of Education |
| PAP | Project Affected Persons |
| JFPR | Japan Fund for Poverty Reduction |
| BETT | Basic Education Teacher Training |
| EEQP | Enhancing Education Quality Project |
| CESSP | Cambodia Education Sector Support Project |
| SESSP | The Second Education Sector Support Project |
| USAID | United States Agency for International Development |
| ADB | Asia Development Bank |
| GPE | Global Partnership for Education |
| DSMC | District Scholarship Management Committee |
| LSMC | Local Scholarship Management Committee |
| PSMC | Provincial Scholarship Management Committee |
| SPSS | Statistical Package for the Social Sciences |
| PB | Program Budgeting |

# បញ្ជីតារាង

តារាងទី1៖ លក្ខខណ្ឌជ្រើសរើសសិស្សអាហារូបករណ៍ក្រីក្រ (n=៣២) ................................10

តារាងទី2 ៖ ប្រភេទអ្នកត្រូវចូលរួមផ្តល់បំពេញកម្រងសំណួរ .............................................19

តារាងទី3 ៖ ព័ត៌មានទូទៅអំពីសិស្សអាហារូបករណ៍ក្រីក្រដែលបានបំពេញកម្រងសំណួរ ....19

# បញ្ជីក្រាហ្វិក

ក្រាហ្វិកទី1៖ ស្ថិតិសិស្សដែលបានចូលរួមបំពេញកម្រងសំណួរ........................................24
ក្រាហ្វិកទី 2៖ មុខរបរមាតាបិតា ឬអាណាព្យាបាលសិស្សអាហារូបករណ៍ក្រីក្រ ...................25
ក្រាហ្វិកទី 3 ៖ អាយុរបស់មាតាបិតា ឬអាណាព្យាបាលសិស្សបានបំពេញកម្រងសំណួរ ......26
ក្រាហ្វិកទី4 ៖ ដំណើរការផ្សព្វផ្សាយព័ត៌មានអាហារូបករណ៍បានពីមន្ត្រីទទួលបន្ទុក ............27
ក្រាហ្វិកទី5៖ មធ្យោបាយដែលសិស្សទទួលព័ត៌មានស្តីពីកម្មវិធីអាហារូបករណ៍...................28
ក្រាហ្វិកទី6៖ លក្ខខណ្ឌជ្រើសរើសអាហារូបករណ៍ដែលសិស្សនិងមាតាបិតាសិស្សបានដឹង ....29
ក្រាហ្វិកទី7៖ ការបញ្ជាក់របស់សិស្ស មាតាបិតាសិស្សពីការចុះពិនិត្យផ្ទៀងផ្ទាត់ដល់ផ្ទះ .......31
ក្រាហ្វិកទី8៖ ផែនការសកម្មភាពរបស់គណៈកម្មការអាហារូបករណ៍..................................33
ក្រាហ្វិកទី9៖ ការបញ្ជាក់របស់សិស្ស ពីការយកចិត្តទុកដាក់របស់គ្រូមកលើពួកគេ ...............33
ក្រាហ្វិកទី10៖ ការរំពឹងទុកថាសិស្សអាហារូបករណ៍នឹងបន្តរៀនរហូតដល់ចប់បឋមសិក្សា......34
ក្រាហ្វិកទី11៖ ការសម្ភាសផ្ទាល់ជាមួយសិស្ស និងមាតាបិតាឬអ្នកអាណាព្យាបាល .............35
ក្រាហ្វិកទី12៖ យោបល់របស់សិស្ស និងមាតាបិតាឬអ្នកអាណាព្យាបាលអំពីបរិមាណនៃប្រាក់អាហារូបករណ៍ ...........................................................................................................36
ក្រាហ្វិកទី13៖ លទ្ធផលសិក្សារបស់សិស្សអាហារូកបរណ៍ ................................................36
ក្រាហ្វិកទី14៖ ភាពទៀងទាត់នៃលំហូរថវិកាអាហារូបករណ៍នៅតាមកម្រិត.........................39
ក្រាហ្វិកទី15៖ ការសម្របសម្រួលសិស្សឱ្យបន្តទទួលបានប្រាក់អាហារូបករណ៍ ....................40

# បញ្ជីដ្យាក្រាម

ដ្យាក្រាមទី1៖ ការចុះផ្ទៀងផ្ទាត់ព័ត៌មានរបស់គណៈកម្មការជ្រើសរើសនៅតាមផ្ទះសិស្ស .....30
ដ្យាក្រាមទី2៖ ការប្រជុំសម្រេចជ្រើសរើសសិស្សអាហារូបករណ៍ក្រីក្ររបស់គណៈកម្មការ....32
ដ្យាក្រាមទី3៖ ព័ត៌មានស្តីពីការបើកប្រាក់អាហារូបករណ៍ដែលទទួលបានពីសិស្ស...............37
ដ្យាក្រាមទី4៖ ព័ត៌មានស្តីពីការបើកប្រាក់អាហារូបករណ៍ដែលទទួលបានពីសិស្ស...............38
ដ្យាក្រាមទី5៖ ព័ត៌មានស្តីពីខកខានមិនអាចបើកប្រាក់បាន ដែលទទួលបានពីសិស្ស...........38
ដ្យាក្រាមទី6៖ ការបណ្តុះបណ្តាលដល់មន្ត្រីទទួលបន្ទុកក្នុងរយៈពេល៣ឆ្នាំចុងក្រោយ .........40
ដ្យាក្រាមទី7៖ ការពេញចិត្តនឹងការអនុវត្តកម្មវិធីអាហារូបករណ៍របស់មន្ត្រីទទួលបន្ទុក .........41
ដ្យាក្រាមទី8៖ ការចូលរួមសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ .......................................42
ដ្យាក្រាមទី9៖ ការចូលរួមរបស់សហគមន៍........................................................................43

# ជំពូកទី១
# សេចក្ដីផ្ដើម

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១. លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជាបានកសាងវិស័យអប់រំពីបាតដៃទទេ ក្រោយសង្គ្រាមស៊ីវិល និងរបបប្រល័យ ពូជសាសន៍ត្រូវបានបញ្ចប់នៅឆ្នាំ១៩៧៩។ រហូតដល់ឆ្នាំ១៩៩៨ ប្រទេសកម្ពុជាក៏បានទទួលសុខសន្តិភាពពេញលេញទូទាំងប្រទេស តាមរយៈនយោបាយឈ្នះឈ្នះរបស់រាជរដ្ឋាភិបាលកម្ពុជា។ កិច្ចខិតខំប្រឹងប្រែងទាំងនេះ ទទួលបានជោគជ័យយ៉ាងធំធេង ជាក់ស្តែងក្នុងឆ្នាំសិក្សា២០១៦-២០១៧ អត្រាពិតនៃការចុះឈ្មោះចូលរៀននៅបឋមសិក្សា មាន ៩៥,១០ ភាគរយ ក្នុងនោះកុមារអាយុ៦ឆ្នាំ ចំនួន ១២៩ ១៩១នាក់ អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សាមាន៧៩,៨៧ភាគរយ ដែលក្នុងនោះសិស្សស្រីមាន ៨៣,២២ភាគរយ(នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ(EMIS) ឆ្នាំសិក្សា២០១៦-២០១៧ ទំព័រទី៥៥)។

ដោយឡែកការបោះបង់ការសិក្សាមានការថយចុះនារយៈពេលចុងក្រោយនេះ អត្រាបោះបង់ការសិក្សានៅថ្នាក់ទី១ មានការថយចុះពី ៦,៣០ភាគរយ ក្នុងឆ្នាំសិក្សា២០១៣-២០១៤ មកនៅត្រឹម ៣,៧០ភាគរយ ក្នុងឆ្នាំសិក្សា២០១៦-២០១៧ ហើយអត្រានេះនៅមានគម្លាតគួរឱ្យកត់សម្គាល់រវាងតំបន់ប្រជុំជន និងតំបន់ជនបទ (នាយកដ្ឋានបឋមសិក្សា, ២០១៩-២០២៣, ទំព័រទី១)។ ទោះជាយ៉ាងណាក៏ដោយការបោះបង់ការសិក្សានៅថ្នាក់ចុងបញ្ចប់នៃកម្រិតបឋមសិក្សាមានការកើនឡើង ដែលក្នុងនោះការបោះបង់ការសិក្សានៅថ្នាក់ទី៥ និងទី៦ មាន៥,១០ភាគរយ ដែលភាគច្រើនគឺក្រុមសិស្សដែលមកពីគ្រួសារក្រីក្រ គ្រួសារស្ថិតក្នុងស្ថានភាពលំបាក និងគ្រួសារមកពីក្រុមជនជាតិដើមភាគតិច (នាយកដ្ឋានបឋមសិក្សា, ២០១៩-២០២៣, ទំព័រទី១)។

ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនោះ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញ និងអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៤-២០១៨ កម្មវិធីគាំទ្រវិស័យអប់រំរយៈពេលមធ្យម និងគោលនយោបាយអប់រំសម្រាប់ទាំងអស់គ្នារយៈពេលវែង ឱ្យសម្រេចបាននូវសមធម៌នៃការអប់រំកម្រិតមូលដ្ឋាន រយៈពេល៩ឆ្នាំ ចាំបាច់ត្រូវមានគោលវិធីសម្រាប់ការកាត់បន្ថយចំណាយ ដែលជាឧបសគ្គដល់គ្រួសារក្រីក្រ ចំពោះការអប់រំនៅបឋមសិក្សា។ ឆ្លើយតបទៅនឹងបរិបទទាំងនេះ ក្រសួងអប់រំ យុវជន និងកីឡា បានអនុវត្តកម្មវិធីអាហារូបករណ៍សិស្សក្រីក្រនៅបឋមសិក្សា ដែលជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការលើកកម្ពស់សមធម៌ក្នុងការទទួលបានការអប់រំ ការរក្សាភាពគង់វង្សក្នុងការសិក្សារបស់កុមារ និងការបញ្ចប់ការសិក្សានៅបឋមសិក្សានិង

មធ្យមសិក្សាចំណោះទូទៅ។ កម្មវិធីអាហារូបករណ៍នៅបឋមសិក្សានេះបានចាប់ ផ្ដើមនៅក្នុងឆ្នាំសិក្សា២០១៤-២០១៥ ដោយមានការគាំទ្រពីភាពជាដៃគូសកលសម្រាប់ការអប់រំ និងផ្នែកដទៃទៀតនៃការផ្ដល់អាហារូបករណ៍ជូនសិស្សក្រីក្រនៅបឋមសិក្សាមានដូចជា៖

-កម្មវិធីស្បៀងអាហារពិភពលោក ផ្ដល់អាហារូបករណ៍ជាស្បៀង និងជាសាច់ប្រាក់

-គម្រោងគាំទ្រវិស័យអប់រំលើកទី២នៃភាពជាដៃគូសកលសម្រាប់ការអប់រំ (SESSP-GPE) នៃធនាគារពិភពលោក ផ្ដល់សាច់ប្រាក់ដល់សិស្សក្រីក្ររៀនពូកែ

-អង្គការក្រៅរដ្ឋាភិបាលមួយចំនួនផ្ដល់ជាសម្ភារៈសិក្សា ជាទ្រង់ទ្រាយតូចនៅតំបន់ខ្លះៗ

នាពេលបច្ចុប្បន្ន ថវិកាអាហារូបករណ៍ត្រូវបានឧបត្ថម្ភទាំងស្រុងដោយថវិកាជាតិ និងមានលក្ខណៈជាស្ថាប័នពេញលេញ ដោយបានផ្ដល់អត្ថប្រយោជន៍ដល់កុមារពីថ្នាក់ទី៤ ដល់ទី៦។ ជាពិសេសនៅឆ្នាំសិក្សា២០១៨-២០១៩ រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចពង្រីកកម្មវិធីអាហារូបករណ៍នៅបឋមសិក្សាពីថ្នាក់ទី១ ដល់ទី៦ (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៨)។

## ១.២. បញ្ហានៃការស្រាវជ្រាវ

បច្ចុប្បន្នក្រសួងអប់រំ យុវជន និងកីឡា បានកំពុងព្យាយាមធ្វើការកែទម្រង់វិស័យអប់រំដើម្បីធ្វើយ៉ាងណាសម្រេចបាននូវការអប់រំមួយប្រកបដោយគុណភាព ធានាបាននូវធនធានមនុស្សប្រកបដោយសមត្ថភាពខ្ពស់ មានចំណេះដឹងទូលំទូលាយ និងមានសីលធម៌ និងជំនាញ បំណិនផ្នែករឹង និងផ្នែកទន់នៃធនធានមនុស្សខ្មែរ។ ដោយសារតែភាពក្រីក្រ និងបញ្ហាទន់ខ្សោយខាងសេដ្ឋកិច្ច ដែលបណ្ដាលឱ្យសិស្សមួយចំនួនធំនៅតាមទីជនបទ ឬតាមបណ្ដាខេត្ត ក្រុងនានា និងរាជធានីភ្នំពេញ បានបោះបង់ចោលការសិក្សាហើយងាយចាប់យកមុខរបរ ឬវិជ្ជាជីវៈបច្ចេកទេសផ្សេងៗ ឬការធ្វើចំណាកស្រុក និងការងារដែលអាចផ្ដល់ប្រាក់កម្រៃបានឆាប់រហ័សសម្រាប់ផ្គត់ផ្គង់គ្រួសារ។ ដូច្នេះភាពចាំបាច់ក្នុងការសិក្សាអំពីការអនុវត្តកម្មវិធីអាហារូបករណ៍ព្រមទាំងនីតិវិធី និងបញ្ហាប្រឈមក្នុងការអនុវត្តកម្មវិធីអាហារូបករណ៍សិស្សក្រីក្រនៅបឋមសិក្សា ក្នុងរាជធានីភ្នំពេញនឹងជួយផ្ដល់ជាព័ត៌មាន ហើយនិងជាធាតុចូលដ៏សំខាន់មួយក្នុងការរៀបចំផែនការ គោលនយោបាយ យុទ្ធសាស្ត្រ ឬការសិក្សាស្រាវជ្រាវអំពីបញ្ហាប្រឈមរបស់សិស្សបោះបង់ការសិក្សា និងកំណត់បានពីដំណោះស្រាយនៃបញ្ហាទាំងនោះ។

## ១.៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ មានគោលបំណងសំខាន់ពីរដូចខាងក្រោម៖

(១) សិក្សាពីដំណើរការ និងយន្តការនៃការអនុវត្តជាក់ស្ដែង របស់កម្មវិធីអាហារូបករណ៍សិស្សក្រីក្រនៅកម្រិតបឋមសិក្សា និង

(២) សិក្សាពីបញ្ហាប្រឈមក្នុងការអនុវត្តកម្មវិធីអាហារូបករណ៍។

## ១.៤. សំណួរស្រាវជ្រាវ

ដើម្បីសម្រេចគោលបំណងខាងលើ ការសិក្សាស្រាវជ្រាវនេះផ្តោតលើសំណួរស្រាវជ្រាវចំនួនពីរ គឺ (១) តើការអនុវត្តជាក់ស្តែងក្នុងរាជធានីភ្នំពេញរបស់កម្មវិធីអាហារូបករណ៍សិស្សក្រីក្រនៅបឋមសិក្សាមានដំណើរការ និងយន្តការយ៉ាងដូចម្តេច? (២) តើការអនុវត្តកម្មវិធីនេះជួបនឹងបញ្ហាប្រឈមអ្វីខ្លះ?

## ១.៥. សារៈសំខាន់នៃការស្រាវជ្រាវ

លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះនឹងផ្តល់នូវផលប្រយោជន៍ដូចខាងក្រោមៈ

-កំណត់ពីបញ្ហាប្រឈមរបស់កម្មវិធី ដើម្បីសិក្សា និងរៀបចំផែនការដោះស្រាយ

-កំណត់ជាគោលនយោបាយជាតិស្តីពីអាហារូបករណ៍ និងអាហារូបត្ថម្ភ ដើម្បីពង្រឹងប្រសិទ្ធភាពការងារ

-ពង្រឹងសមត្ថភាពមន្ត្រីលើការងារស្រាវជ្រាវ

-ជាឯកសារគោលសម្រាប់ការងារស្រាវជ្រាវបន្ត។

## ១.៦. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៦.១. វិសាលភាពនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះត្រូវបានធ្វើឡើងនៅរាជធានីភ្នំពេញ ដោយយកខណ្ឌ៧ និងសាលាបឋមសិក្សា៧ ស្ថិតនៅតាមតំបន់គោលដៅផ្សេងៗគ្នា រួមមានតំបន់ផ្សារ តំបន់រោងចក្រ និងជាយក្រុង ដោយផ្តោតទៅលើដំណើរការជាក់ស្តែងនៃការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ បញ្ហាប្រឈមនានានៅក្នុងគោលដៅដែលបានកំណត់ខាងលើ។

### ១.៦.២. ដែនកំណត់នៃការស្រាវជ្រាវ

ទិន្នន័យព័ត៌មានមូលដ្ឋានដែលនឹងបង្ហាញនេះ តំណាងឱ្យខណ្ឌទាំង៧ និងតំណាងឱ្យសាលាបឋមសិក្សាទាំង៨៦ ដែលមានកម្មវិធីអាហារូបករណ៍សិស្សក្រីក្រី និងបានអនុវត្តកន្លងមកក្នុងរាជធានីភ្នំពេញតែប៉ុណ្ណោះ គឺមិនមែនតំណាងឱ្យខេត្ត ក្រុង ស្រុក ខណ្ឌ និងសាលាបឋមសិក្សាទូទាំងប្រទេសឡើយ។

សំណាកគំរូនៃការសិក្សាស្រាវជ្រាវនេះត្រូវបានកំណត់យកតាមគោលបំណងរបស់អ្នកសិក្សាស្រាវជ្រាវដោយឈរលើមូលដ្ឋាន នៃការអនុវត្តការងារជាក់ស្តែងទាក់ទងនឹងកម្មវិធីអាហារូបករណ៍នាពេលកន្លងមករួមមានៈ កម្រិតល្អ កម្រិតបង្គួរ កម្រិតមធ្យម និងកម្រិតក្រោមធ្យម។ ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ និងមន្ត្រីជំនាញចំនួន០៣នាក់ផ្សេងទៀត ដែលជាសមាសភាពគណៈកម្មការគ្រប់គ្រងអាហារូបករណ៍ថ្នាក់រាជធានីព្រមទាំងមន្ត្រីការិយាល័យអប់រំខណ្ឌចំនួន០៧នាក់ ថែមទៀតគឺត្រូវបានយកធ្វើជាមូលដ្ឋាន

ក្នុងការផ្តល់ព័ត៌មានពីកម្រិតនៃការអនុវត្តការងាររបស់គណៈកម្មការគ្រប់គ្រងអាហារូបករណ៍មូលដ្ឋានចំនួន០៧នាក់ នាយកឬនាយិកា ចំនួន០៧នាក់ គ្រូទទួលបន្ទុកថ្នាក់ចំនួន ០៧នាក់ សិស្សដែលបានទទួលអាហារូបករណ៍ចំនួន៧០នាក់ និងមាតាបិតាឬអាណាព្យាបាលសិស្សដែលទទួលបានអាហារូបករណ៍ចំនួន៧០នាក់ ក្នុងចំណោមសាលារៀនទាំង០៧ ដែលនឹងត្រូវបានជ្រើសរើសដើម្បីឱ្យបំពេញកម្រងសំណួរស្រាវជ្រាវ ដើម្បីសម្រេចតាមគោលបំណងនៃការស្រាវជ្រាវ។ ចំនួនសំណាកគំរូសរុបចំនួន១៧២នាក់។

## ១.៧. រចនាសម្ព័ន្ធស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះបានបែងចែកជា៥ជំពូក ដូចខាងក្រោម៖

-ជំពូកទី១៖ សេចក្តីផ្តើម: ជំពូកនេះបានបង្ហាញពីគោលបំណងនៃការចោទបញ្ហានៃការសិក្សាស្រាវជ្រាវ លំនាំនៃការស្រាវជ្រាវនិងសារៈសំខាន់នៃការសិក្សាស្រាវជ្រាវ។

-ជំពូកទី២៖ រំលឹកទ្រឹស្តី: (រំលឹកទ្រឹស្តីដែលពាក់ព័ន្ធ) លើកឡើងពីទ្រឹស្តីណាដែលទាក់ទង និងចំណុចទាំងអស់ដែលបានចោទក្នុងចំណោទបញ្ហា។

-ជំពូកទី៣៖ វិធីសាស្រ្តស្រាវជ្រាវ: ត្រូវបង្ហាញពីគម្រោងវិភាគ និងវិធីសាស្រ្តស្រាវជ្រាវដែលបញ្ជាក់ពីអត្ថប្រយោជន៍នៃប្រធានបទ វិសាលភាពនៃការសិក្សាស្រាវជ្រាវនិងបង្ហាញពីទំនាក់ទំនងរវាងចំណុចនីមួយៗ ដែលបានចោទក្នុងចំណោទបញ្ហាទៅនឹងប្រធានបទ។

-ជំពូកទី៤៖ លទ្ធផលនិងការពិភាក្សា: ត្រូវលើកឡើងពីលក្ខណៈជាក់ស្តែងដែលយើងបានធ្វើការសិក្សាស្រាវជ្រាវ ហើយចំណុចដែលត្រូវលើកឡើងគឺត្រូវឱ្យចូលទៅក្នុងចំណុចទាំងអស់ដែលបានចោទសួរក្នុងចំណោទបញ្ហា។ ការពិភាក្សាលើលទ្ធផលនៃការសិក្សាស្រាវជ្រាវ វិភាគទៅលើចំណុចខ្លាំងទាំងអស់ដែលបានអនុវត្តន៍ជាក់ស្តែង ថាតើវាដូចគ្នាទៅនឹងទ្រឹស្តីដែរឬទេ? គឺធ្វើឡើងក្នុងគោលបំណងវិភាគរកឱ្យឃើញចំណុចខ្វះខាត និងបញ្ហាប្រឈម ដើម្បីកែលម្អ(គឺវិភាគលើកម្រងសំណួរ)។

-ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងការផ្តល់សំណូមពរ: ធ្វើការសន្និដ្ឋានទៅលើចំណុចទាំងអស់ដែលបានវិភាគ និងផ្តល់ជាយោបល់ទៅលើចំណុចកែលម្អឬចំណុចខ្វះខាត និងបញ្ហាប្រឈម។

# ជំពូកទី២
# ការរំលឹកទ្រឹស្តី

# ជំពូកទី២
# ការរំលឹកទ្រឹស្តី

## ២.១. ព័ត៌មានទូទៅ

កម្មវិធីលើកទឹកចិត្ត ត្រូវបានបង្កើតឡើងដើម្បីជួយគ្រួសារជួបការលំបាកក្នុងការចំណាយលើការសិក្សាដោយផ្ទាល់និងដោយប្រយោល (USAID, 2006)។ ការចំណាយលើការអប់រំដោយផ្ទាល់រួមមាន ថ្លៃសិក្សា ថ្លៃប្រឡង ឯកសណ្ឋាន ស្បែកជើង សៀវភៅ និងការផ្គត់ផ្គង់ផ្សេងៗអាស្រ័យលើសាលារៀន។ រីឯការចំណាយដោយប្រយោលគឺជាតម្លៃនៃឱកាសចម្បងសម្រាប់រក្សាប្រាក់ចំណូល ឬកម្លាំងពលកម្មរបស់កុមារដែលគ្រួសារក្រីក្រភាគច្រើនមិនអាចមានលទ្ធភាពផ្តល់ឱ្យ។ ហើយការលើកទឹកចិត្តមានច្រើនទម្រង់ដូចជា អាហារូបករណ៍ ការផ្ទេរសាច់ប្រាក់ដោយមានលក្ខខណ្ឌ ការផ្តល់ជាអាហារ (ការផ្តល់ប្រេងសម្រាប់ចម្អិនក្នុងក្រុមគ្រួសារ ឬសម្រាប់អាហារសម្រន់នៅសាលា) ប្រាក់ឧបត្ថម្ភសម្រាប់ឯកសណ្ឋាន និងអន្តេវាសិកដ្ឋានដោយឥតគិតថ្លៃ។ ដើម្បីឱ្យការអនុវត្តក្របខណ្ឌយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលចំពោះវិស័យអប់រំក្នុងការរួមចំណែកអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ និងដើម្បីកសាងសង្គមកម្ពុជាឱ្យក្លាយជាសង្គមរីកចម្រើន ផ្អែកលើចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន ក្រសួងអប់រំ យុវជន និងកីឡា ដែលជាសេនាធិកាឱ្យរាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញអនុក្រឹត្យលេខ៣៨អនក្រ.បក ស្តីពីការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រនៅបឋមសិក្សា និងមធ្យមសិក្សាចំណេះទូទៅ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥ និងក្រសួងបានចេញប្រកាសឱ្យអនុវត្តលេខ ២៥៥៧ អយក.ប្រក ស្តីពីការកំណត់លក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រនៅបឋមសិក្សានិងមធ្យមសិក្សាចំណេះទូទៅ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥។

## ២.២. និយមន័យពាក្យគន្លឹះ

យ៉ាងណាមិញ ដើម្បីឱ្យការសិក្សាស្រាវជ្រាវនេះកាន់តែមានភាពស៊ីជម្រៅ គឺត្រូវបានផ្តោតលើពាក្យគន្លឹះមួយគឺ អាហារូបករណ៍។ អាហារូបករណ៍គឺជាគ្រឿងឧបករណ៍ដើម្បីអាហារ ឬជាប្រាក់ដែលបើកឱ្យសិស្ស និស្សិត ដើម្បីទំនុកបម្រុងឬទប់ទល់នឹងថ្លៃអាហារក្នុងពេលកំពុងរៀនសូត្រ[1]។ ដូចនេះប្រធានបទនៃការសិក្សាស្រាវជ្រាវនេះ គឺចង់បង្ហាញពីការអនុវត្ត និងបញ្ហាប្រឈមនៃគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការផ្តល់ជាថវិកាគាំទ្រដល់សិស្សក្រីក្រ សិស្សជួបការលំបាក ឱ្យមានឱកាសបន្តការសិក្សារៀនសូត្របានជោគជ័យនៅបឋមសិក្សាក្នុងរាជធានីភ្នំពេញ។ ឆ្លងតាមរយៈការអនុវត្តកន្លង

[1] https://km.wiktionary.org/wiki/

មក ឃើញថាកម្មវិធីអាហារូបករណ៍នៅបឋមសិក្សាមានបញ្ហាចម្បងៗចំនួន៧ដូចជា៖ (១) ភាពយឺតយ៉ាវនៃការជ្រើសរើសសិស្សអាហារូបករណ៍ (២)ភាពយឺតយ៉ាវនៃការបើកប្រាក់អាហារូបករណ៍ជុំទីមួយ (៣)កង្វះថវិកាគាំទ្រនៅក្នុងដំណើរការជ្រើសរើសនិងពិនិត្យតាមតាម (៤)ភាពចន្លោះប្រហោងក្នុងការពិនិត្យតាមដាន និងការធ្វើរបាយការណ៍ (៥)កង្វះយន្តការទំនាក់ទំនងនិងការផ្តល់ព័ត៌មានត្រឡប់ (៦)ការកំណត់គោលដៅអាហារូបករណ៍(ការជ្រើសរើសសិស្ស និងទីតាំងភូមិសាស្រ្ត) មិនទាន់បានល្អ (៧)កង្វះយន្តការសម្របសម្រួលរវាងកម្មវិធីអាហារូបករណ៍នៅបឋមសិក្សា និងមធ្យមសិក្សាចំណេះទូទៅ ដើម្បីធានាដល់ការឆ្លងភូមិសិក្សារបស់សិស្សពីបឋមសិក្សាទៅមធ្យមសិក្សាបឋមភូមិ (នាយកដ្ឋានបឋមសិក្សា, ២០១៩-២០២៣, ទំព័រទី៣)។ ដោយឃើញពីបញ្ហាខាងលើនេះហើយទើបធ្វើមានការស្រាវជ្រាវនេះឡើង ដើម្បីសិក្សាស្វែងយល់ឱ្យបានលម្អិតជាក់ស្តែង ក្នុងការអនុវត្តកន្លងមកនៅក្នុងរាជធានីភ្នំពេញដែលជាបេះដូងនៃប្រទេសទាំងមូល។

## ២.៣. កម្មវិធីអាហារូបករណ៍ហៃទី

កម្មវិធីអាហារូបករណ៍ហៃទីបានទទួលមូលនិធិពី USAID ដែលបានចាប់ផ្តើមតាំងពីពីរឆ្នាំមុន (USAID 2006)។ វាជាសកម្មភាពមួយដែលផ្តល់ហិរញ្ញប្បទានដល់ការអប់រំសម្រាប់កុមារដែលជួបការលំបាក បាត់បង់ស្មារតីដោយសារអំពើហិង្សានយោបាយ។ កម្មវិធីអាហារូបករណ៍នេះបានផ្តល់អាហារូបករណ៍ជាថវិកាដល់សិស្សចំនួន ១៥៤៦នាក់សម្រាប់សាលាចំនួន២២៨នៅក្នុងទីក្រុងចំនួន៥នៃប្រទេសហៃទី។ ការសម្រេចលទ្ធផលនេះ គឺតាមរយៈការពង្រឹងសមត្ថភាពនៃការអនុវត្តគម្រោងរបស់អង្គការមិនមែនរដ្ឋាភិបាលហៃទីដែលមានបទពិសោធន៍ជាច្រើនឆ្នាំក្នុងការគ្រប់គ្រងកម្មវិធីអាហារូបករណ៍ហៃទី។

នៅឆ្នាំ ២០០៥ កម្មវិធីអាហារូបករណ៍នេះបានពង្រីកវិសាលភាពរបស់ខ្លួនក្នុងការផ្តល់ថវិកាបន្ថែមសម្រាប់ផ្តល់អាហារូបករណ៍ ដល់កុមារដែលទទួលរងគ្រោះដោយខ្យល់ព្យុះ និងទឹកជំនន់ ដែលបានវាយប្រហារមកលើប្រទេសហៃទីនៅក្នុងឆ្នាំ២០០៤ ក្នុងនោះរួមមានព្យុះត្រូពិចជីន ដែលបានសម្លាប់មនុស្សជាងបីពាន់នាក់ និងបន្សល់ទុកនៅមនុស្សគ្មានទីជម្រកជាច្រើននាក់ទៀត។ កម្មវិធីអាហារូបករណ៍ក៏បានផ្តល់ថ្លៃសិក្សាប្រចាំឆ្នាំដល់សិស្ស និស្សិតដែលរស់នៅក្នុងតំបន់ដែលរងផលប៉ះពាល់នេះដែរ។ ក្នុងនោះក៏មានការបោះជំរុំរដូវក្តៅសម្រាប់សិស្សដែលខកខានមិនបានទៅសាលា ក្នុងកំឡុងពេលជួបគ្រោះមហន្តរាយនោះ ដោយមានវគ្គជាសេចក្តីណែនាំពាក់ព័ន្ធនឹងបំណិនជីវិត និងផ្តល់ឱ្យដើម្បីទិញសម្លៀកបំពាក់ ជាថវិកាសម្រាប់កែលម្អសាលារៀន និងការផ្គត់ផ្គង់សម្រាប់ថ្នាក់រៀនផងដែរ។

## ២.៤. គោលនយោបាយទៅលើគំរូនៃទម្រង់នៃការបង្រៀន និងរៀននៅប្រទេសថៃ

### ២.៤.១. ប្រព័ន្ធអប់រំដោយឥតបង់ថ្លៃរយៈពេល១២ឆ្នាំ

ក្រសួងអប់រំរបស់ប្រទេសថៃ បានឯកភាពជាគោលការណ៍ក្នុងការគ្របដណ្តប់ទៅលើតម្លៃនៃការសិក្សារបស់សិស្សដោយឥតបង់ថ្លៃសម្រាប់ប្រព័ន្ធអប់រំក្រោម១២ឆ្នាំ និងពង្រីកការសិក្សាដោយឥតបង់ថ្លៃទៅដល់មត្តេយ្យសិក្សា រយៈពេល២ឆ្នាំ។ ប្រាក់ឧបត្ថម្ភសម្រាប់ការអប់រំដោយឥតបង់ថ្លៃនៅកម្រិតមត្តេយ្យសិក្សា នឹងអាចមានចំនួន ១៧០០បាតសម្រាប់សិស្សម្នាក់។ ហើយប្រាក់ឧបត្ថម្ភប្រចាំឆ្នាំសម្រាប់កម្រិតបឋមសិក្សានឹងអាចកើនឡើងពី ១៤៩៩បាត ទៅ ១៩០០បាត។ សម្រាប់សិស្សនៅកម្រិតអនុវិទ្យាល័យនឹងអាចទទួលបានពី ២៦៤៩បាត ទៅ ៣៥០០បាត។ ចំណែកឯកម្រិតសិស្សនៅវិទ្យាល័យអាចនឹងទទួលបានពី ៣ ២៤៩បាត ទៅ ៣៨០០បាត[2]។

### ២.៤.២. មូលនិធិកំចីសម្រាប់ការអប់រំ

មូលនិធិកំចីសម្រាប់ការអប់រំ គឺផ្តល់សម្រាប់សិស្សដែលមកពីគ្រួសារដែលមានប្រាក់ចំណូលទាប ហើយបន្តផ្តល់ការអប់រំក្រៅប្រព័ន្ធទៅដល់សិស្សនៅកម្រិតអនុវិទ្យាល័យនិងវិទ្យាល័យ រហូតដល់មហាវិទ្យាល័យទាំង mainstream and vocational curriculum។ សិស្សទាំងនោះត្រូវចំណាយត្រឡប់មកកំចីវិញ ជាមួយចំនួនអត្រាការប្រាក់ចំនួន១ភាគរយ ក្នុងមួយឆ្នាំ បន្ទាប់ពីរៀនចប់។ មូលនិធិកំចីសម្រាប់សិស្សនេះត្រូវបានបង្កើតឡើងនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ១៩៩៥ ហើយត្រូវបានចាត់ចែងដោយស្ថាប័នបីគឺ ក្រសួងហិរញ្ញវត្ថុ ក្រសួងអប់រំ និងគណៈកម្មការសម្រាប់កម្រិតឧត្តមសិក្សា[3]។

### ២.៤.៣. គម្រោងរៀនតាមបែបអឺមែលអន្តរកម្ម

ក្នុងគោលបំណងផ្តល់ដល់សិស្សនូវការសិក្សាពីចម្ងាយ តាមរយៈប្រព័ន្ធបណ្តាញខ្សែរណប។ គឺការបង្រៀនតាមរយៈឆាណែលមួយរបស់ក្រសួងអប់រំ ដើម្បីឆ្លើយឆ្លងសំណួររវាងសាស្ត្រាចារ្យ និងអ្នកជំនាញដ៏មានបទពិសោធន៍។ មិនតែប៉ុណ្ណោះវាជួយកាត់បន្ថយនៅគម្លាតរវាងសិស្សនៅតំបន់ជនបទ និងទីក្រុង និងផ្តល់ឱកាសឱ្យសិស្សដែលនៅតំបន់ជនបទដាច់ស្រយាល បានទំនាក់ទំនងជាមួយគ្រូដែលមានបទពិសោធន៍ផងជាច្រើនដែរ[4]។

[2] www.activemindsconsulting.com, November 2008

[3] Ibid.,

[4] www.activemindsconsulting.com, November 2008

២.៤.៤. សិក្សាពីការងារដើម្បីចាប់យកគម្រោងនៃក្ដីស្រម៉ៃរបស់អ្នក

គម្រោងនេះត្រូវបានផ្ដួចផ្ដើមដោយក្រសួងអប់រំ ដើម្បីបង្កើនផលិតភាពការងារនៅពេលទំនេររបស់សិស្សនៅអាយុ១៥ឆ្នាំ ឬលើសពីនេះ។ ក្រសួងអប់រំ ជាមួយនឹងផ្នែកឯកជនផ្សេងៗទៀត ផ្ដល់តួនាទីការងារដែលសមស្របជាមួយនឹងតម្រូវការរបស់សិស្សម្នាក់ៗ។ តម្លៃនៃការជួលនោះនឹងអាចមានចំនួន១០២លានបាត។ ការសិក្សាសាកល្បងនេះបានអនុវត្តនៅក្នុងខែមេសា ឆ្នាំ២០០៨ ដោយមានការចូលរួមពីសិស្សចំនួន ២៥០នាក់ សម្រាប់ការងាររយៈពេល១៨ថ្ងៃ ហើយទទួលបានប្រាក់កំរៃចំនួន ២០០បាត ក្នុងមួយថ្ងៃ ឬ ៣៦០០បាត ក្នុងមួយខែ[5]។

## ២.៥. ហិរញ្ញប្បទានរបស់ដៃគូរអភិវឌ្ឍ

កម្មវិធីហិរញ្ញប្បទានរបស់រាជរដ្ឋាភិបាលកម្ពុជាដែលបានស្នើឡើង គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រសម្របសម្រួលទូលំទូលាយ ដើម្បីបន្តកែលម្អសមធម៌នៃការសិក្សា។ ហិរញ្ញប្បទានដទៃដែលបានចូលរួមក្នុងការផ្ដល់អាហារូបករណ៍រួមមាន[6]៖

-ក. ការផ្ដល់អាហារូបករណ៍ដល់សិស្សនៅបឋមសិក្សា ដោយកម្មវិធីស្បៀងអាហារពិភពលោក (World Food Program)

-ខ. ការផ្ដល់អាហារូបករណ៍ទ្រង់ទ្រាយតូចសម្រាប់សិស្សក្រីក្រ ដែលឧបត្ថម្ភដោយអង្គការក្រៅរដ្ឋាភិបាលមួយចំនួន

-ឃ. ការផ្ដល់អាហារូបករណ៍បន្ថែម ១៥ដុល្លា លើថវិការាជរដ្ឋាភិបាលសម្រាប់សិស្សម្នាក់ៗ ដោយគម្រោងគាំទ្រវិស័យអប់រំ(SESSP) នៃមូលនិធិសាកលសម្រាប់ការអប់រំ (GPE)

-ង. បច្ចុប្បន្នកម្មវិធីអាហារូបករណ៍សម្រាប់សិស្សក្រីក្រ ត្រូវបានរាជរដ្ឋាភិបាលជ្រើសរើសផ្ដល់ឱ្យសិស្សទាំងស្រុងក្នុងការអនុវត្ត ដោយថវិកាកម្មវិធីរបស់ក្រសួងអប់រំ យុវជន និងកីឡា។

## ២.៦. គោលបំណងរួមនៃកម្មវិធីអាហារូបករណ៍

ការផ្ដល់អាហារូបករណ៍ដល់សិស្សក្រីក្រ មានគោលបំណងគាំទ្រការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤-២០១៨ ដើម្បីធានាឱ្យសម្រេចនូវវត្ថុបំណងគោលនយោបាយសម្រាប់អនុវិស័យបឋមសិក្សា ដូចជា (១)ធានាប្រមូលកុមារដល់វ័យនិងក្នុង វ័យសិក្សាឱ្យចូលរៀន និងរៀនបានចប់ឆ្នាំសិក្សានិងភូមិសិក្សា និង (២)ធានាកុមារទាំងអស់ទទួលបានចំណេះដឹង បំណិន សុខភាពពេញលេញ និងសីលធម៌ស្របតាមស្តង់ដារដែលបានកំណត់ និងធានាដំណើរការពេញលេញនូវប្រព័ន្ធគ្រប់គ្រងផ្អែកលើលទ្ធផល។

---

[5] Ibid.,

[6] នាយកដ្ឋានបឋមសិក្សា, ២០១៩-២០២៣

គោលបំណងសំខាន់ជាក់លាក់គឺដើម្បីបង្កើនវត្តមានការសិក្សា កាត់បន្ថយអត្រាបោះបង់ការសិក្សារបស់សិស្ស និងបង្កើនអត្រាបញ្ចប់ការសិក្សានៅកម្រិតបឋមសិក្សា តាមរយៈការផ្តល់ប្រាក់ឧបត្ថម្ភដើម្បីឆ្លើយតបទៅនឹងតម្រូវការសិក្សារបស់សិស្ស (នាយកដ្ឋានបឋមសិក្សា ឆ្នាំ២០១៥)។

## ២.៧. ការរក្សាសិស្សឱ្យនៅក្នុងប្រព័ន្ធអប់រំតាមរយៈកម្មវិធីអាហារូបករណ៍

យោងតាមការសិក្សាស្រាវជ្រាវរបស់នាយកដ្ឋានបឋមសិក្សា នៅឆ្នាំ២០១៥ ដើម្បីធានាសមធម៌ក្នុងការទទួលសេវាអប់រំរហូតដល់ចប់ភូមិសិក្សា ការសិក្សាយូរអង្វែង និងដើម្បីបង្កើនអត្រាគង់វង្ស អត្រាឆ្លងភូមិសិក្សាពីថ្នាក់ទី៦ ទៅទី៧ ការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ និងសិស្សក្រីក្ររៀនពូកែ ពិតជាមានសារៈសំខាន់ណាស់។ ជាក់ស្តែងកម្មវិធីអាហារូបករណ៍សិសក្រីក្រនៅបឋមសិក្សាបានរៀបចំឡើងក្នុងគោលបំណងដើម្បី៖

- ផ្តល់ឱកាសដល់សិស្ស ដែលមកពីគ្រួសារក្រីក្រ ជួបការលំបាក និងតំបន់ដាច់ស្រយាលទូទាំងប្រទេស ជាពិសេសសិស្សស្រី ទទួលបានសេវាអប់រំស្របតាមគោលនយោបាយអប់រំសម្រាប់ទាំងអស់គ្នា ទាំងអស់គ្នាសម្រាប់ការអប់រំ
- ផ្តល់លទ្ធភាពដល់សិស្សក្រីក្រដែលរៀនពូកែទូទាំងប្រទេស និងទទួលសេវាអប់រំចប់ភូមិសិក្សាប្រកបដោយសមធម៌ តាមរយៈការផ្តល់អាហារូបករណ៍
- កាត់បន្ថយអត្រាបោះបង់ការសិក្សារបស់សិស្ស និងបង្កើនការចុះឈ្មោះចូលរៀន
- ផ្តល់ឱកាសឱ្យសិស្សស្រី ដែលមកពីគ្រួសារក្រីក្រស្នាក់នៅអន្តេវាសិកដ្ឋានដោយទទួលបានសេវាថែទាំ ស្នាក់នៅ រៀនសូត្រ រហូតដល់ចប់ភូមិសិក្សានីមួយៗ
- បង្កើនការយកចិត្តទុកដាក់លើការងារយេនឌ័រ និងលើកទឹកចិត្តសិស្សស្រីដែលក្រីក្របំផុត និងសិស្សស្រីជនជាតិភាគតិចដែលមានសក្តានុពលភាពខ្ពស់ក្នុងការសិក្សាតាមរយៈការផ្តល់អាហារូបករណ៍។

## ២.៨. លក្ខខណ្ឌនៃការផ្តល់អាហារូបករណ៍

ការផ្តល់អាហារូបករណ៍ដល់សិស្សក្រីនៅតាមសាលារៀនត្រូវបានកំណត់លក្ខខណ្ឌដូចខាងក្រោម (ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៥)៖

- អាហារូបករណ៍ត្រូវផ្តល់ក្នុងមួយឆ្នាំសិក្សា ដល់សិស្សក្រីក្រម្នាក់ៗតាមកម្រិតដូចជា៖
  - បឋមសិក្សា ៖ ២៤០ ០០០រៀល
  - មធ្យមសិក្សាបឋមភូមិ ៖ ២៤០ ០០០រៀល
  - មធ្យមសិក្សាទុតិយភូមិ ៖ ៣៦០ ០០០រៀល
- ចំនួនសិស្សអាហារូបករណ៍នៅតាមគ្រឹះស្ថានសិក្សាសាធារណៈនីមួយៗ នឹងត្រូវផ្តល់ជូនទៅតាមចំនួនជាក់ស្តែងដោយផ្អែកលើអត្រាប្រជាជនមានប័ណ្ណក្រីក្រប្រភេទ១ និង

មានស្ថានភាពជីវភាពប្រហាក់ប្រហែលនេះ។ លក្ខខណ្ឌលម្អិតនៃការជ្រើសរើសអាហារូបករណ៍ត្រូវអនុវត្តតាមសៀវភៅណែនាំអនុវត្តកម្មវិធីអាហារូបករណ៍

- ការផ្តល់អាហារូបករណ៍ត្រូវផ្តោតលើក្រុមសិស្សចាប់ពីថ្នាក់ទី៤ ដល់ថ្នាក់ទី១២ ដើម្បីផ្តល់ឱកាសបានសិក្សាបន្តរហូតដល់ចប់មធ្យមសិក្សា

- អាហារូបករណ៍សម្រាប់សិស្សក្រីក្រម្នាក់ៗ ត្រូវផ្តល់ឱ្យដោយផ្សារភ្ជាប់ជាមួយលក្ខខណ្ឌមករៀនទៀងទាត់យ៉ាងតិច៨០ភាគរយនៃថ្ងៃសិក្សា ឬលទ្ធផលសិក្សាជាប់មធ្យមភាគ។

**តារាងទី1៖ លក្ខខណ្ឌជ្រើសរើសសិស្សអាហារូបករណ៍ក្រីក្រ (n=៣២)**

| ល.រ | លក្ខខណ្ឌជ្រើសរើស | ចំនួនចម្លើយ |
|---|---|---|
| ១ | មានបណ្ណអត្តសញ្ញាណគ្រួសារក្រីក្រប្រភេទ១ ឬ ប្រភេទ២ ឬបណ្ណសមធម៌ផ្សេងៗ | ២ |
| ២ | មានលិខិតស្នើសុំពីអាជ្ញាធរមូលដ្ឋាននិងជាគ្រួសារជួបការលំបាកធ្វើឱ្យអវត្តមានច្រើន | ០ |
| ៣ | មិនទទួលបានអាហារូបករណ៍ពីអង្គការ ឬស្ថានប័នផ្សេងៗ | ០ |
| ៤ | មានវត្តមានច្រើនជាង ៨០% នៃថ្ងៃសិក្សា និង លទ្ធផលជាប់មធ្យមភាគ | ០ |
| ៥ | ត្រូវមានលក្ខខណ្ឌទី១ និងទី២ខាងលើ | ៣ |
| ៦ | ត្រូវមានលក្ខខណ្ឌទី១ និងទី៤ខាងលើ | ១ |
| ៧ | ត្រូវមានលក្ខខណ្ឌទី១ ទី២ និងទី៣ខាងលើ | ១ |
| ៨ | ត្រូវមានលក្ខខណ្ឌទី១ ទី២ និងទី៤ខាងលើ | ២ |
| ៩ | ត្រូវមានលក្ខខណ្ឌទី១ ទី២ និងទី៥ខាងលើ | ៣ |
| ១០ | ត្រូវមានលក្ខខណ្ឌទី១ ទី៣ និងទី៤ខាងលើ | ៦ |
| ១១ | ត្រូវមានលក្ខខណ្ឌទី១ ទី២ ទី៣ និងទី៤ខាងលើ | ១៤ |

## ២.៩. នីតិវិធីនៃការផ្តល់អាហារូបករណ៍

គណៈកម្មការគ្រប់គ្រងអាហារូបករណ៍មូលដ្ឋាន(គ.អ.ម.) គឺជាគណៈកម្មការជ្រើសរើសអាហារូបករណ៍ ដែលត្រូវរៀបចំឡើងនៅដើមខែដំបូងនៃឆ្នាំសិក្សានីមួយៗ។ ទន្ទឹមនឹងនោះ ការជ្រើសរើសក្រុមសិស្សអាហារូបករណ៍ និងការកំណត់បញ្ជីឈ្មោះសិស្ស

អាហារូបករណ៍ផ្លូវការត្រូវរៀបចំឡើងវិញមួយឆ្នាំម្តង ដោយគណៈកម្មការគ្រប់គ្រងអាហារូប-ករណ៍មូលដ្ឋាន(គ.អ.ម.) និងដោយមានការយល់ព្រមពីប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត។ ការជ្រើសរើសនោះត្រូវអនុវត្តតាមនីតិវិធី និងលក្ខខណ្ឌវិនិច្ឆ័យស្របតាមសៀវភៅណែនាំអនុវត្តកម្មវិធីអាហារូបករណ៍។ ដោយឡែក ការបើកប្រាក់អាហារូបករណ៍សម្រាប់សិស្សម្នាក់ៗ ក្នុងមួយឆ្នាំសិក្សាត្រូវបើកជូនចំនួនបីលើកស្របតាមឆ្នាំថវិកា។ ក្នុងនោះរាល់ពេលបើកប្រាក់ត្រូវរៀបចំពិធីនៅតាមសាលារៀនគោលដៅនីមួយៗ ដោយមានតំណាងការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ឬតំណាងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត (នាយកដ្ឋានបឋមសិក្សា ឆ្នាំ២០១៥ ទំព័រទី៦-១៣)។

## ២.១០. គណៈកម្មការគ្រប់គ្រងអាហារូបករណ៍មូលដ្ឋាន

គណៈកម្មការគ្រប់គ្រងអាហារូបករណ៍មូលដ្ឋាន(គ.អ.ម.) ត្រូវបានង្កើតឡើងដើម្បីធ្វើការជ្រើសរើសក្រុមសិស្សអាហារូបករណ៍ក្រីក្រ បើកប្រាក់ជូនសិស្សអាហារូបករណ៍តាមដានវត្តមាននិងការសិក្សារបស់សិស្ស និងទំនាក់ទំនងជាមួយសហគមន៍និងអាជ្ញាធរដែនដី។ គណៈកម្មការនេះមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - នាយក ឬនាយិកាសាលាបឋមសិក្សា | ប្រធាន |
| - ប្រធានគណៈកម្មការទ្រទ្រង់សាលារៀន | អនុប្រធាន |
| - ប្រធាន ឬអនុប្រធានគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀន | សមាជិក |
| - នាយករង ឬនាយិការង | សមាជិក |
| - លេខាធិការ ឬហេរញ្ញិក | សមាជិក |
| - តំណាងគ្រូបង្រៀន (អាទិភាពស្ត្រី) ០១រូប | សមាជិក |
| - តំណាងក្រុមប្រឹក្សាឃុំ សង្កាត់ទទួលបន្ទុកកិច្ចការនារីនិងកុមារ | សមាជិក |

សមាសភាពជាក់ស្តែងរបស់គណៈកម្មការនេះ ត្រូវតែងតាំងដោយលិខិតបង្គាប់ការរបស់នាយក ឬនាយិកាសាលាបឋមសិក្សា និងមានការឯកភាពពីការិយាល័យអប់រំយុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ហើយអាចកែសម្រួលនៅដើមឆ្នាំសិក្សា តាមការចាំបាច់ (នាយកដ្ឋានបឋមសិក្សា ឆ្នាំ២០១៥ ទំព័រទី៨)។

### ២.១០.១. តួនាទី និងភារកិច្ច

គណៈកម្មការគ្រប់គ្រងអាហារូបករណ៍មូលដ្ឋាន(គ.អ.ម.) មានភារកិច្ចដូចតទៅ៖

- រៀបចំផែនការការងារផ្តល់អាហារូករណ៍ដល់សិស្សក្រីក្រ
- ផ្សព្វផ្សាយព័ត៌មានអាហារូបករណ៍ឱ្យបានទូលំទូលាយដល់គ្រូ សិស្សានុសិស្ស និងសហគមន៍

- ជ្រើសរើសក្រុមសិស្សអាហារូបករណ៍ក្រីក្រ ដោយធានាឱ្យមានតម្លាភាព និងអនុវត្តតាមនីតិវិធី និងលក្ខណវិនិច្ឆ័យនៃការជ្រើសរើស
- ដោះស្រាយរាល់បណ្តឹងតវ៉ានិងបាតុភាពនានា ដែលទាក់ទងនឹងការជ្រើសរើសក្រុមសិស្សអាហារូបករណ៍ក្រីក្រ និងការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ
- រៀបចំផែនការចំណូល ចំណាយក្នុងការផ្តល់អាហារូបករណ៍ និងចុះហត្ថលេខាលើទម្រង់ឯកសារ បង្កាន់ដៃ បានប្រើប្រាស់ក្នុងការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ
- រៀបចំសំណុំឯកសារសំណើសុំថវិកាប្រតិបត្តិ និងថវិកាអាហារូបករណ៍ទៅគណៈកម្មការគ្រប់គ្រងអាហារូបករណ៍រាជធានី ខេត្ត(គ.អ.ខ.) តាមរយៈគណៈ-កម្មការគ្រប់គ្រងអាហារូបករណ៍ក្រុង ស្រុក ខណ្ឌ(គ.អ.ស.) តាមកាលបរិច្ឆេទដែលបានកំណត់
- ជូនដំណឹងដល់សិស្ស និងអ្នកអាណាព្យាបាលសិស្សយ៉ាងតិច ៤ថ្ងៃមុន អំពីកាលបរិច្ឆេទ ទីកន្លែង ពេលវេលានៃការបើកប្រាក់អាហារូបករណ៍ និងឯកសារពាក់ព័ន្ធដែលត្រូវយកមកជាមួយ ដូចជា អត្តសញ្ញាណបណ្ណឬសៀវភៅគ្រួសារកិច្ចសន្យា និងផ្តាំផ្ញើដល់មាតាបិតាឬអ្នកអាណាព្យាបាល សិស្សឱ្យជូនកូនមកទទួលប្រាក់អាហារូបករណ៍
- រៀបចំសំណុំឯកសារនិងបញ្ជីវត្តមានសិស្សអាហារូបករណ៍ និងបញ្ជាក់វត្តមានសរុបរបស់សិស្ស គិតជាភាគរយមករៀនធៀបនឹងថ្ងៃសិក្សាសរុប(ភាគរយមករៀនស្មើនឹងចំនួនវត្តមាន គុណនឹង១០០ រួចចែកនឹងចំនួនថ្ងៃសិក្សា)
- ចូលរួមក្នុងសកម្មភាពបើកប្រាក់អាហារូបករណ៍ ដើម្បីជួយសម្របសម្រួលនិងធ្វើជាសាក្សី
- តាមដានវត្តមាននិងការសិក្សារៀនសូត្ររបស់សិស្សជាប្រចាំ និងទំនាក់ទំនងអ្នកអាណាព្យាបាល ចំពោះសិស្សទាំងឡាយណាដែលអវត្តមានច្រើន ឬអវត្តមានពី ០២(ពីរ) ទៅ ០៣(បី)ថ្ងៃជាប់ៗគ្នា
- រៀបចំកិច្ចប្រជុំ(គ.អ.ម.) ប្រចាំខែ សម្រាប់ការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ ដើម្បីពិភាក្សាវាយតម្លៃពីការរីកចម្រើន និងបញ្ហានានាដូចជាបញ្ហាសិស្សអវត្តមាន និងធ្លាក់មធ្យមភាគជាដើម
- រៀបចំឯកសាររបាយការណ៍រីកចម្រើនផ្ញើទៅ (គ.អ.ខ.) តាមកាលបរិច្ឆេទដែលបានកំណត់ និងរក្សាទុកដាក់ឯកសារទាក់ទងនឹងការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រឱ្យត្រឹមត្រូវ និងសុវត្ថិភាព

- បំពេញកិច្ចការដទៃទៀតក្នុងដំណើរការផ្តល់អាហារូបករណ៍ ដល់សិស្សក្រីក្រតាមការចាំបាច់
- ចំពោះប្រធាន ឬអនុប្រធានគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនមានភារកិច្ចបន្ថែម ជាអ្នកសម្របសម្រួលលើដំណើរការជ្រើសរើសក្រុមសិស្សអាហារូបករណ៍
- ក្រុមប្រឹក្សាឃុំសង្កាត់មានភារកិច្ចបន្ថែម ជាទីប្រឹក្សាក្នុងការជ្រើសរើសក្រុមសិស្សអាហារូបករណ៍។

(នាយកដ្ឋានបឋមសិក្សា ឆ្នាំ២០១៥ ទំព័រទី៥)

### ២.១០.២. របៀបរបបការងារ

គណៈកម្មការគ្រប់គ្រងអាហារូបករណ៍មូលដ្ឋាន(គ.អ.ម.) ត្រូវដំណើរការប្រជុំសាមញ្ញ និងវិសាមញ្ញក្រោមការដឹកនាំរបស់ប្រធាន ការប្រជុំសម្រេចផ្តល់អាហារូបករណ៍ ឬលុបឈ្មោះសិស្សអាហារូបករណ៍ អាចប្រព្រឹត្តទៅបានលុះត្រាមានសមាសភាពចូលរួមយ៉ាងតិចពីរភាគបី នៃចំនួនសមាជិកគណៈកម្មការសរុប។ រាល់ការសម្រេចក្នុងអង្គប្រជុំត្រូវកំណត់យកជាការបាន លុះត្រាតែមានសំឡេងគាំទ្រយ៉ាងតិចហាសិបភាគរយបូកមួយនៃសមាជិកគណៈកម្មការដែលបានចូលរួមប្រជុំ។ ករណីសំឡេងស្មើគ្នា សំឡេងរបស់ប្រធានមានឧត្តមានុភាពក្នុងការសម្រេច (នាយកដ្ឋានបឋមសិក្សា ឆ្នាំ២០១៥ ទំព័រទី១៦)។

## ២.១១. គណៈកម្មការគ្រប់គ្រងអាហារូបករណ៍ក្រុង ស្រុក ខណ្ឌ

គណៈកម្មការគ្រប់គ្រងអាហារូបករណ៍ក្រុង ស្រុក ខណ្ឌ(គ.អ.ស.) ត្រូវបានបង្កើតឡើង ដើម្បីសម្របសម្រួលការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលមានសមាសភាព តួនាទី ភារកិច្ច និងការទទួលខុសត្រូវផ្នែកបឋមសិក្សាដូចខាងក្រោម ៖

### ២.១១.១. សមាសភាព

- ប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ប្រធាន
- អនុប្រធានការិ.អ.យ.ក ក្រុង ស្រុក ខណ្ឌ ទទួលបន្ទុកបឋមសិក្សា អនុប្រធាន
- មន្ត្រីការិ.អ.យ.ក ក្រុង ស្រុក ខណ្ឌ ទទួលបន្ទុកផ្នែកហិរញ្ញវត្ថុ ០១(មួយ)រូប សមាជិក
- មន្ត្រីការិ.អ.យ.ក ក្រុង ស្រុក ខណ្ឌ ទទួលបន្ទុកបឋមសិក្សា ០២(ពីរ)រូប សមាជិក

### ២.១១.២. ភារកិច្ច និងការទទួលខុសត្រូវ

- បណ្តុះបណ្តាល គ.អ.ម. និងផ្សព្វផ្សាយអំពីការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ មានដូចជាការជ្រើសរើសសិស្សអាហារូបករណ៍ គោលបំណងនៃការផ្តល់

អាហារូបករណ៍ ដំណើរការនៃការផ្តល់អាហារូបករណ៍ ការពិនិត្យតាមដាន ការគាំទ្រសាលារៀន និងការធ្វើរបាយការណ៍

- ចុះពិនិត្យតាមដានដំណើរការជ្រើសរើសក្រុមសិស្សអាហារូបករណ៍នៅមូលដ្ឋាន
- ដោះស្រាយបណ្តឹងតវ៉ា និងបាតុភាពផ្សេងៗ ក្នុងដំណើរការជ្រើសរើសសិស្សអាហារូបករណ៍ និងក្នុងអំឡុងពេលអនុវត្តការផ្តល់អាហារូបករណ៍
- ពិនិត្យបញ្ជាក់បញ្ជីឈ្មោះសិស្សអាហារូបករណ៍ផ្លូវការ និងបញ្ជូនទៅ គ.អ.ខ. ដើម្បីអនុម័ត
- ពិនិត្យសំណុំឯកសារសំណើសុំថវិកាប្រតិបត្តិនិងថវិកាអាហារូបករណ៍របស់ គ.អ.ម. រួចបញ្ជូនទៅ គ.អ.ខ. ដើម្បីអនុម័ត
- ផ្តល់ការគាំទ្រជាចាំបាច់សម្រាប់ការគ្រប់គ្រង និងការបើកប្រាក់អាហារូបករណ៍ ដោយធានាថាការបើកប្រាក់ប្រព្រឹត្តទៅដោយរលូន និងដល់ដៃសិស្សគ្រប់ចំនួន
- រៀបចំការប្រជុំប្រចាំត្រីមាស ដើម្បីដោះស្រាយបញ្ហាផ្សេងៗ ដែលកើតមានទាក់ទងនឹងការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ
- រៀបចំរបាយការណ៍រីកចម្រើនប្រចាំឆមាស និងប្រចាំឆ្នាំ រួចបញ្ជូនទៅ គ.អ.ខ.
- តាមដាន និងវាយតម្លៃការបំពេញការងាររបស់ គ.អ.ម.
- បំពេញភារកិច្ចផ្សេងទៀតក្នុងការផ្តល់អាហារូបករណ៍ តាមការចាំបាច់។

(នាយកដ្ឋានបឋមសិក្សា ឆ្នាំ២០១៥ ទំព័រទី៣)

## ២.១២. គណៈកម្មការគ្រប់គ្រងអាហារូបករណ៍រាជធានី ខេត្ត (គ.អ.ខ.)

គណៈគ្រប់គ្រងអាហារូបករណ៍ថ្នាក់រាជធានី ខេត្ត(គ.អ.ខ.) បង្កើតឡើងដើម្បីសម្របសម្រួលដល់ការអនុវត្តកម្មវិធីអាហារូបករណ៍ដែលមានសមាសភាព តួនាទី ភារកិច្ច និងការទទួលខុសត្រូវដូចខាងក្រោម៖

### ២.១២.១. សមាសភាព

- ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត — ប្រធាន
- អនុប្រធានមន្ទីរ អ.យ.ក.ទទួលបន្ទុកបឋមសិក្សា — អនុប្រធាន
- ប្រធានការិ./អនុប្រធានការិ.បឋមសិក្សា — សមាជិក
- មន្ត្រីចាត់តាំងមកពីការិ.ផែនការ ហិរញ្ញវត្ថុ ០១(មួយ)រូប — សមាជិក
- មន្ត្រីនៅការិយាល័យបឋមសិក្សា ០២(ពីរ)រូប — សមាជិក

### ២.១២.២. ភារកិច្ច និងការងារទទួលខុសត្រូវ

- គ្រប់គ្រងរដ្ឋបាលលើការងារផ្តល់អាហារូបករណ៍ ដោយអនុវត្តគោលការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា និងសហការជាមួយស្ថាប័ននិងអាជ្ញា

ធរពាក់ព័ន្ធ ដើម្បីធានាដល់ដំណើរការអនុវត្តប្រកបដោយភាពរលូន មានការចូលរួមនិងភាពជាម្ចាស់

- ណែនាំបង្កើតគណៈកម្មការគ្រប់គ្រងអាហារូបករណ៍ក្រុង ស្រុក ខណ្ឌ និងគណៈកម្មការគ្រប់គ្រងអាហារូបករណ៍មូលដ្ឋាន និងពីដំណើរការនៃការផ្ដល់អាហារូបករណ៍ដល់សិស្សក្រីក្រ
- ផ្ដល់ការណែនាំពីវិធីសាស្ត្រ បច្ចេកទេស និងដំណើរការសម្រាប់ការអនុវត្តសកម្មភាពអប់រំ មើលការខុសត្រូវ និងតាមដានសកម្មភាពការផ្ដល់អាហារូបករណ៍ដល់សិស្សក្រីក្រ
- ផ្ដល់វគ្គបណ្ដុះបណ្ដាលនិងកសាងសមត្ថភាពដល់ គ.អ.ស. និង គ.អ.ម. និងផ្សព្វផ្សាយពីគោលបំណង ទិសដៅ និងគោលការណ៍ ព្រមទាំងនីតិវិធីនានានៃការគ្រប់គ្រង និងអនុវត្តការផ្ដល់អាហារូបករណ៍ដល់សិស្សក្រីក្រ ដោយធានានូវការចូលរួមរបស់សហគមន៍ ដូចជាការជ្រើសរើសសិស្ស ការតាមដានវត្តមាន និងការសិក្សារៀនសូត្ររបស់សិស្សជាដើម
- ចុះត្រួតពិនិត្យលើដំណើរការជ្រើសរើសក្រុមសិស្សអាហារូបករណ៍
- អនុម័តយល់ព្រមលើបញ្ជីឈ្មោះសិស្សអាហារូបករណ៍ជាផ្លូវការ និងបញ្ជូនទៅតាមសាលារៀនវិញ ដើម្បីប្រកាសព័ត៌មាន
- ប្រមូល និងចងក្រងទិន្នន័យរបស់សាលាគោលដៅទៅក្នុងប្រព័ន្ធទិន្នន័យ សម្រាប់រៀបចំផែនការអនុវត្តការផ្ដល់អាហារូបករណ៍ដល់សិស្សក្រីក្ររាល់ប្រចាំឆ្នាំ
- រៀបចំសំណុំឯកសារសំណើសុំថវិកាប្រតិបត្តិការនិងថវិកាអាហារូបករណ៍ រួចបញ្ជូនទៅអង្គភាពថវិកាខេត្ត (មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) ដោយភ្ជាប់ជាមួយនូវបញ្ជីឈ្មោះសិស្សអាហារូបករណ៍ផ្លូវការដែលបានអនុម័តរួច
- រៀបចំឯកសារជូនដំណឹង កំណត់ពេលវេលា និងសម្របសម្រួលការបើកប្រាក់អាហារូបករណ៍
- ធ្វើរបាយការណ៍រីកចម្រើនប្រចាំឆមាស និងប្រចាំឆ្នាំ រួចផ្ញើទៅ ក.អ.ជ. (នាយកដ្ឋានបឋមសិក្សា)
- រៀបចំកិច្ចប្រជុំប្រចាំឆមាសដើម្បីពិនិត្យលើរបាយការណ៍ឆមាស និងដោះស្រាយបញ្ហាផ្សេងៗ ដែលកើតមានទាក់ទងនឹងការផ្ដល់អាហារូបករណ៍
- ចុះធ្វើអធិការកិច្ច ពិនិត្យតាមដាន និងគាំទ្រគណៈកម្មការនៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងសាលារៀនរាល់ដំណាច់ឆ្នាំសិក្សានីមួយៗ និងនៅពេលដែលចាំបាច់
- បំពេញកិច្ចការផ្សេងទៀតក្នុងដំណើរការផ្ដល់អាហារូបករណ៍ តាមការចំបាច់។

(នាយកដ្ឋានបឋមសិក្សា ឆ្នាំ២០១៥ ទំព័រទី២)

## ២.១៣. ការបើកប្រាក់អាហារូបករណ៍ជូនសិស្សក្រីក្រ

ការបើកប្រាក់អាហារូបករណ៍ជូនសិស្សក្រីក្រធ្វើឡើងមានកាលកំណត់ ចំនួនបីលើកក្នុងមួយឆ្នាំសិក្សា។ លើកទីមួយត្រូវធ្វើឡើងនៅអំឡុងខែមករា លើកទីពីរខែឧសភា និងលើទី៣ ខែកក្កដា។ ក្នុងមួយលើកៗមានទឹកប្រាក់ចំនួន ៨០ ០០០រៀល សរុបស្មើនឹង ២៤០ ០០០រៀល សម្រាប់សិស្សម្នាក់ក្នុងមួយឆ្នាំសិក្សា។ ពិធីបើកប្រាក់ជូនសិស្សអាហារូបករណ៍ ត្រូវធ្វើនៅតាមសាលារៀននីមួយៗ មានន័យថាសិស្សអាហារូបករណ៍ទាំងអស់ជាមួយមាតាបិតា ឬអ្នកអាណាព្យាបាលត្រូវមកជួបជុំគ្នា ដើម្បីទទួលប្រាក់អាហារូបករណ៍នៅសាលារៀនរបស់ខ្លួន នៅចំពោះ មុខ គ.អ.ម. និងតំណាងមកពីថ្នាក់ក្រុង ស្រុក ខណ្ឌ និង/ឬថ្នាក់រាជធានី ខេត្ត (នាយកដ្ឋានបឋមសិក្សា ឆ្នាំ២០១៥ ទំព័រទី៩-១៣)។

## ២.១៤. យន្តការដោះស្រាយបណ្ដឹងតវ៉ា

### ២.១៤.១. របៀបប្ដឹងតវ៉ា

- ការប្ដឹងតវ៉ាគួរធ្វើតាមរយៈការបំពេញ ឬសរសេរពាក្យបណ្ដឹងជាលាយល័ក្ខអក្សរ ប្រសិនបើអាចធ្វើទៅបាន សូមប្រើទម្រង់(គអម៣) ហើយបញ្ជូនមក គ.អ.ម.
- ការប្ដឹងក៏អាចធ្វើដោយផ្ទាល់មាត់ចំពោះមុខ គ.អ.ម. ឬតាមរយៈលេខទូរស័ព្ទដែលបានផ្ដល់ជូនលើផ្ទាំងប៉ុស្ទ័រទៅគណៈកម្មការដោះស្រាយបណ្ដឹងតវ៉ា
- ប្រសិនបើបណ្ដឹងតវ៉ាទាក់ទងនឹងការជ្រើសរើសក្រុមសិស្សអាហារូបករណ៍ នោះការប្ដឹងតវ៉ាត្រូវធ្វើឡើងក្នុងអំឡុងពេល ១សប្ដាហ៍ក្រោយ ពេលបិទប្រកាសឈ្មោះបណ្ដោះអាសន្ននៅលើក្ដារព័ត៌មានរបស់សាលារៀន ឬសហគមន៍ ឃុំ
- ប្រសិនបើបណ្ដឹងតវ៉ាទាក់ទងនឹងការប្រតិបត្តិរបស់សិស្ស (សិស្សរៀនមិនទៀងទាត់) ឬទាក់ទងនឹងការផ្ដល់អាហារូបករណ៍ដល់សិស្សក្រីក្រ អាចធ្វើទៅបានក្នុងអំឡុងពេលនៃឆ្នាំសិក្សា
- រាល់ករណីនៃបណ្ដឹងតវ៉ានឹងត្រូវបញ្ចូលក្នុងរបាយការណ៍ស្ដីពី ការជ្រើសរើសក្រុមសិស្សអាហារូបករណ៍ និងរបាយការណ៍ពិនិត្យតាមដានការផ្ដល់អាហារូបករណ៍

(នាយកដ្ឋានបឋមសិក្សា ឆ្នាំ២០១៥ ទំព័រទី១៦)

### ២.១៤.២. គណៈកម្មការដោះស្រាយបណ្ដឹងតវ៉ា

- គ.អ.ម. គឺជាគណៈកម្មការដោះស្រាយបណ្ដឹងតវ៉ា គណៈកម្មការនេះអាចស្នើ ឬអញ្ជើញប្រធាន គ.អ.ស. ឬមេឃុំធ្វើជាប្រធានកិត្តិយសនៃគណៈកម្មការដោះស្រាយបណ្ដឹង តាមកម្រិតស្រាល ឬធ្ងន់នៃបណ្ដឹង និងតាមការចាំបាច់នៃករណីបណ្ដឹងនីមួយៗ

- ព្រមជាមួយគ្នានេះ បណ្ដឹងតវ៉ាអាចប្ដឹងផ្ទាល់ទៅ គ.អ.ស. គ.អ.ខ. និង ក .ជ.អ. នៅពេលចុះពិនិត្យតាមដានការផ្ដល់អាហារូបករណ៍ដល់សិស្សក្រីក្រ។

(នាយកដ្ឋានបឋមសិក្សា ឆ្នាំ២០១៥ ទំព័រទី១៧)

**២.១៤.៣. ដំណើរការដោះស្រាយបណ្ដឹងតវ៉ា**

- ប្រធានគណៈកម្មការដោះស្រាយបណ្ដឹងតវ៉ា នៅពេលបានទទួលបណ្ដឹងតវ៉ានឹងត្រូវបើកកិច្ចប្រជុំជាបន្ទាន់ ដើម្បីពិភាក្សាដោះស្រាយបណ្ដឹងតវ៉ា។ ប្រសិនបើមានបណ្ដឹងតវ៉ាបានទទួលនៅក្នុងអំឡុងសប្ដាហ៍នៃការប្រជុំប្រចាំខែ នោះការដោះស្រាយបណ្ដឹងនឹងត្រូវធ្វើឡើងក្នុងពេលប្រជុំប្រចាំខែតែម្ដង ជាជាងបើកកិច្ចប្រជុំមួយទៀតដោយឡែក
- ក្នុងពេលប្រជុំដោះស្រាយបណ្ដឹង ប្រធានគណៈកម្មការដោះស្រាយបណ្ដឹងត្រូវអានពាក្យបណ្ដឹង ឬកំណត់ហេតុប្ដឹងផ្ទាល់មាត់ បន្ទាប់មកត្រូវចាប់ផ្ដើមបើកការពិភាក្សាក្នុងអង្គប្រជុំជាមួយសមាជិកទាំងអស់
- ប្រសិនបើ បណ្ដឹងទាក់ទងនឹងបញ្ជីឈ្មោះសិស្សអាហារូបករណ៍បណ្ដោះអាសន្ន គណៈកម្មការនឹងធ្វើការពិនិត្យឡើងវិញនូវព័ត៌មានរបស់សិស្សទាំងនោះ ដើម្បីផ្ទៀងផ្ទាត់ទៅនឹងលក្ខណវិនិច្ឆ័យនៃការជ្រើសរើស។ ប្រសិនបើមានការចាំបាច់ គណៈកម្មការអាចធ្វើការចាត់តាំងសមាជិក០១(មួយ)នាក់ ឬ០២(ពីរ)នាក់ដើម្បីចុះទៅធ្វើអង្កេតដល់លំនៅដ្ឋានរបស់សិស្សទាំងនោះម្ដងទៀត
- ប្រសិនបើដើមបណ្ដឹងមិនព្រមទទួលយកនូវដំណោះស្រាយ ឬការឆ្លើយតបរបស់គណៈកម្មការដោះស្រាយបណ្ដឹងទេ ដើមបណ្ដឹងអាចសរសេរជាលាយល័ក្ខអក្សរប្ដឹងទៅ គ.អ.ស. ថែមទៀត។ ក្នុងករណីនេះ គ.អ.ម. ត្រូវផ្ដល់ព័ត៌មានដល់ដើមបណ្ដឹងអំពីរបៀបទំនាក់ទំនងមក គ.អ.ស.
- ករណីខ្លះ គ.អ.ស. នឹងជួបប្រជុំជាមួយ គ.អ.ខ. ដើម្បីពិភាក្សារកដំណោះស្រាយ រួចផ្ដល់ព័ត៌មានត្រឡប់ដល់សាលារៀន និងសហគមន៍វិញក្នុងករណីដែលពាក់ព័ន្ធ។ ក្នុងករណីបណ្ដឹងខ្លះនឹងត្រូវស៊ើបអង្កេតបន្តដោយមានការសហការគ្នារវាង គ.អ.ខ. គ.អ.ស. និងអាជ្ញាធរដែនដី។ របាយការណ៍លទ្ធផលនៃការស៊ើបអង្កេតត្រូវធ្វើឱ្យបានច្បាស់លាស់ដើម្បីអនុវត្តសេចក្ដីសម្រេច និងផ្ដល់ព័ត៌មានត្រឡប់ទៅអ្នកដែលពាក់ព័ន្ធ ដើម្បីធ្វើការកែលម្អ។

(នាយកដ្ឋានបឋមសិក្សា ឆ្នាំ២០១៥ ទំព័រទី១៧)

# ជំពូកទី៣
# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូកទី៣
# វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការសិក្សាស្វែងយល់ និងស្វែងរកឱ្យឃើញនូវអ្វីដែលជាបញ្ហាប្រឈម ឬឧបសគ្គក្នុងដំណើរការនៃការអនុវត្តកម្មវិធីអាហារូបករណ៍សិស្សក្រីក្ររបស់ក្រសួងដែលកំពុងដំណើរការ ព្រមទាំងភាពយឺតយ៉ាវ និងភាពអសកម្មនៃយន្តការអនុវត្តបច្ចុប្បន្ន។ ម្យ៉ាងវិញទៀត ការសិក្សាស្រាវជ្រាវនេះធ្វើឡើងក្នុងគោលបំណងធ្វើការវិភាគទាញរកសេចក្ដីសន្និដ្ឋានរួម ព្រមទាំងផ្ដល់ជាអនុសាសន៍ ឬសំណូមពរទៅដល់អង្គភាព ស្ថាប័ន ឬក្រសួងដែលកំពុងជួបប្រទះឧបសគ្គ ឬបញ្ហាប្រឈមនៅក្នុងការអនុវត្តការងារជាក់ស្តែងដើម្បីកែលម្អឱ្យប្រសើរឡើង។

## ៣.១. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការស្រាវជ្រាវលើប្រធានបទនេះ "**ការអនុវត្ត និងបញ្ហាប្រឈមនៃកម្មវិធីអាហារូបករណ៍សិស្សក្រីក្រនៅបឋមសិក្សាក្នុងរាជធានីភ្នំពេញ**" គឺប្រើវិធីសាស្ត្របែបពិពណ៌នាប្រៀបធៀប លើការអនុវត្តកម្មវិធីអាហារូបករណ៍ជាក់ស្ដែង និងយន្តការអនុវត្តដោយផ្អែកលើគោលការណ៍ណែនាំក្នុងសៀវភៅណែនាំប្រតិបត្តិ សម្រាប់គណៈកម្មការអាហារូបករណ៍ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងថ្នាក់សាលារៀនមូលដ្ឋាន។ ការប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវនេះត្រូវបានរៀបចំជាលក្ខណៈបរិមាណវិស័យ និងគុណវិស័យដែលមានអ្នកផ្តល់ ចម្លើយ៦ប្រភេទផ្សេងគ្នា ដើម្បីឆ្លើយនឹងកម្រងសំណួរ និងបំពេញកម្រងសំណួរដែលទាក់ទងទៅនឹងការអនុវត្តកម្មវិធីផ្តល់អាហារូបករណ៍កន្លងមក ដោយផ្សារភ្ជាប់ទៅនឹងយុទ្ធសាស្រ្តនានាដែលមាននៅក្នុងគោលនយោបាយស្ដីពីអាហារូបករណ៍។

## ៣.២. ដំណើរការនៃការជ្រើសរើសសំណាកគំរូ

ការសិក្សាស្រាវជ្រាវនេះត្រូវបានធ្វើឡើងនៅក្នុងរាជធានីភ្នំពេញតែប៉ុណ្ណោះ ដោយជ្រើសរើសយកសាលាបឋមសិក្សាចំនួន០៧ ដែលបានអនុវត្តការងារនេះកន្លងកម្រិតល្អបង្គួរ មធ្យម និងក្រោមមធ្យម ដែលស្ថិតនៅតំបន់គោលដៅផ្សេងៗគ្នាដូចជា តំបន់ផ្សារ តំបន់រោងចក្រ និងជាយក្រុង។

សំណាកគំរូសរុបចំនួន ១៧២នាក់ ត្រូវបានជ្រើសរើសសម្រាប់បំពេញកម្រងសំណួររួមមាន៖

- ប្រធានគណៈកម្មការគ្រប់គ្រងអាហារូបករណ៍ថ្នាក់រាជធានី ចំនួន០១នាក់
- មន្ត្រីមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញចំនួន០៣នាក់
- មន្ត្រីការិយាល័យអប់រំ យុវជន និងកីឡាខណ្ឌចំនួន០៧នាក់
- គណៈកម្មការគ្រប់គ្រងអាហារូបករណ៍មូលដ្ឋានចំនួន០៧នាក់
- នាយកឬនាយិកាសាលាចំនួន០៧នាក់
- គ្រូទទួលបន្ទុកថ្នាក់ចំនួន០៧នាក់

- មាតាបិតាឬអាណាព្យាលសិស្សដែលទទួលបានអាហារូបករណ៍ចំនួន៧០នាក់
- សិស្សដែលបានទទួលអាហារូបករណ៍ចំនួន៧០នាក់

**តារាងទី2 ៖ ប្រភេទអ្នកត្រូវចូលរួមផ្តល់បំពេញកម្រងសំណួរ**

| ល.រ | ប្រភេទអ្នកចូលរួម | សរុប(នាក់) |
|---|---|---|
| ១ | គណៈកម្មការគ្រប់គ្រងអាហារូបករណ៍រាជធានីភ្នំពេញ | ៤ |
| ២ | គណៈកម្មការគ្រប់គ្រងអាហារូបករណ៍ថ្នាក់ខណ្ឌ | ៧ |
| ៣ | នាយក ឬនាយិកា និងគណៈកម្មការអាហារូបករណ៍មូលដ្ឋាន | ១៤ |
| ៤ | គ្រូទទួលបន្ទុកថ្នាក់ដែលមានសិស្សអាហារូបករណ៍ | ៧ |
| ៥ | មាតាបិតា ឬអាណាព្យាបាលសិស្សទទួលបានអាហារូបករណ៍ | ៧០ |
| ៦ | សិស្សទទួលបានអាហារូបករណ៍ | ៧០ |
| **សរុបរួម៖** | | **១៧២** |

**តារាងទី3 ៖ ព័ត៌មានទូទៅអំពីសិស្សអាហារូបករណ៍ក្រីក្រដែលបានបំពេញកម្រងសំណួរ**

| ព័ត៌មានទូទៅ អំពីសិស្សអាហារូបករណ៍ក្រីក្រ | | ចំនួន | ភាគរយ | ភាគរយសរុប |
|---|---|---|---|---|
| សាលាបឋមសិក្សា | សន្តិភាព | ១០ | ១៤.៣ | ១០០.១ ≈១០០ |
| | វត្តគ្រូស | ១០ | ១៤.៣ | |
| | កោះដាច់ | ១០ | ១៤.៣ | |
| | ព្រែស្តី | ១០ | ១៤.៣ | |
| | ហ៊ុនសែនព្រែកប្រា | ១០ | ១៤.៣ | |
| | ចាក់អង្រែភូមិ៣ | ១០ | ១៤.៣ | |
| | អូហ្គុរ៉ាត្រកៀត | ១០ | ១៤.៣ | |
| កម្រិតសិក្សា | ថ្នាក់ទី៤ | ១៩ | ២៧.១ | ១០០ |
| | ថ្នាក់ទី៥ | ២៧ | ៣៨.៦ | |
| | ថ្នាក់ទី៦ | ២៤ | ៣៤.៣ | |
| ភេទ | ប្រុស | ២៨ | ៤០ | ១០០ |
| | ស្រី | ៤២ | ៦០ | |
| | មន្ត្រីរាជការ | ៤ | ៥.៧ | |

| | | | | |
|---|---|---|---|---|
| មុខរបរមាតាបិតាឬអាណាព្យាបាលសិស្ស | កម្មករ | ៤២ | ៦០ | ១០០ |
| | កសិករ | ៩ | ១២.៩ | |
| | សន្តិសុខ | ៣ | ៤.៣ | |
| | ម៉ូតូឌុប | ៤ | ៥.៧ | |
| | លក់ដូរបន្តិចបន្តួច | ៣ | ៤.៣ | |
| រស់នៅជាមួយ | សាច់ញាតិ | ៥ | ៧.១ | |
| | អ្នកដទៃ | ០ | ០ | |

## ៣.៣. ឧបករណ៍សម្រាប់ប្រមូលទិន្នន័យ

ក្នុងការចុះប្រមូលទិន្នន័យតាមគោលដៅដែលបានកំណត់រួចនេះ អ្នកស្រាវជ្រាវបានរៀបចំជាកម្រងសំណួរសម្រាប់បំពេញ និងកម្រងសំណួរសម្រាប់សម្ភាស ដោយបានដកស្រង់គំរូចេញពីឧបករណ៍ស្រាវជ្រាវរបស់នាយកដ្ឋានបឋមសិក្សា ឆ្នាំ២០១៧ យកមកផលិតជាឧបករណ៍៦ប្រភេទផ្សេងគ្នា ដើម្បីឆ្លើយតបទៅនឹងគោលបំណងនៃការស្រាវជ្រាវ ដោយមានការចូលរួមកែលម្អពីសំណាក់លោកគ្រូ អ្នកគ្រូដែលជាសាស្ត្រាចារ្យដឹកនាំ។ បន្ទាប់ពីផលិតបានរួចអ្នកស្រាវជ្រាវបានយកឧបករណ៍នោះចុះទៅតេស្តសាកល្បងជាក់ស្តែង ហើយមកកែតម្រូវបំពេញបន្ថែមក្រោមការដឹកនាំចង្អុលបង្ហាញពីសំណាក់សាស្ត្រាចារ្យដឹកនាំ។

### ៣.៣.១. កម្រងសំណួរសម្រាប់បំពេញ

កម្រងសំណួរសម្រាប់បំពេញ គឺត្រូវបានដាក់បញ្ចូលទៅក្នុងឧបករណ៍ប្រមូលទិន្នន័យប្រមាណ៩០% ដែលត្រូវបានដាក់ជូនដល់គ្រប់មុខសញ្ញាទាំងអស់ដើម្បីបំពេញជាលក្ខណ:បុគ្គល ដោយបែងចែកជាបួនផ្នែកធំៗដូចខាងក្រោម៖

(ក)ព័ត៌មានទូទៅ: ក្នុងផ្នែកនេះបានរៀបចំឡើងភ្ជាប់ឱ្យបាននូវទីតាំងភូមិសាស្ត្ររបស់អ្នកដែលត្រូវផ្តល់ព័ត៌មានដូចជា ខណ្ឌ សង្កាត់ ដើម្បីកំណត់ពីស្ថានភាពតំបន់ និងទីតាំងភូមិសាស្ត្រ។

(ខ)អត្តសញ្ញាណអ្នកបំពេញកម្រងសំណួរ: ត្រង់ផ្នែកនេះគឺចង់កំណត់មុខសញ្ញាឱ្យច្បាស់ លាស់ ដើម្បីទុកជាទុនក្នុងការវិភាគនូវចម្លើយបានផ្តល់មកក្នុងការទាញសេចក្តីសន្និដ្ឋានឱ្យកាន់តែរឹងមាំ។

(គ)ព័ត៌មានស្តីពីដំណើរការផ្តល់អាហារូបករណ៍: នៅក្នុងផ្នែកនេះគឺត្រូវបានបែងចែកជាប្រាំជំហានគឺ (១)ដំណើរការផ្សព្វផ្សាយដំណើរនិងការជ្រើសរើស (២)ប្រសិទ្ធភាពនៃការផ្តល់អាហារូបករណ៍ (៣)ការជំរុញការផ្តល់អាហារូបករណ៍ (៤)យន្តការនៃការគ្រប់គ្រងនិង៥)កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍។

(ឃ)បញ្ហាប្រឈមនានា និងសំណូមពរៈ នៅត្រង់ចំណុចនេះត្រូវបានបែងចែកជាពីរប្រភេទ គឺ (១)បញ្ហាប្រឈមនានា ដោយអ្នកស្រាវជ្រាវបានសិក្សាប្រមូលផ្ដុំនូវបញ្ហាប្រឈមមួយចំនួនដែលតែងតែកើតមានឡើងនាពេលអនុវត្តកន្លងមក បញ្ចូលជាស្រេចដើម្បីជូនអ្នកបំពេញកម្រងសំណួរជ្រើសរើស និងបានទុកចន្លោះឱ្យបញ្ចេញនូវទស្សនៈផ្ទាល់ខ្លួនផងដែរ។ (២) សំណូមពរ គឺបានរៀបចំឡើងប្រហាក់ប្រហែលនឹងបញ្ហាប្រឈមដែរ។

**៣.៣.២. កម្រងសំណួរសម្រាប់សម្ភាស**

កម្រងសំណួរសម្រាប់សម្ភាស គឺត្រូវបានរៀបចំក្នុងឧបករណ៍ដោយឡែកសម្រាប់សម្ភាសផ្ទាល់ជាលក្ខណៈបុគ្គលជាមួយសិស្ស មាតាបិតាសិស្ស គ្រូ នាយកឬនាយិកា មន្ត្រីទទួលបន្ទុកថ្នាក់ស្រុក និងមន្ទីរអប់រំ ដើម្បីបញ្ជាក់ឱ្យដឹងពីព័ត៌មានបន្ថែមឱ្យកាន់តែច្បាស់លាស់ជាក់ស្ដែងពិតប្រាកដ។

## ៣.៤ ដំណើរការនៃការប្រមូលទិន្នន័យ

ដំណើរការនៃការប្រមូលទិន្នន័យនេះ គឺអ្នកស្រាវជ្រាវបានប្រើវិធីសាស្ត្រនៃការប្រមូលទិន្នន័យដោយជ្រើសរើសវិធីសាស្ត្រចំនួនពីរមកប្រើ គឺការប្រមូលទិន្នន័យតាមបែបបរិមាណវិស័យ និងគុណវិស័យ។ ចំពោះទិន្នន័យតាមបែបបរិមាណវិស័យត្រូវបានប្រមូលតាមរយៈការបំពេញកម្រងសំណួរបិទ។ រីឯទិន្នន័យតាមបែបបរិមាណវិស័យត្រូវបានបំពេញតាមរយៈកម្រងសំណួរបើក។ ចំពោះទិន្នន័យទាំងពីរប្រភេទខាងលើត្រូវបានប្រមូលពីប្រធានមន្ទីរអប់រំ មន្ត្រីពាក់ព័ន្ធ នាយក នាយិកា នាយករង នាយិការង គ្រូបង្រៀន មាតាបិតាឬអាណាព្យាបាលសិស្ស និងសិស្សអាហារូបករណ៍ថ្នាក់ទី៤ ទី៥ ទី៦ ដែលអាចជាតំណាងសាលានៅរាជធានីភ្នំពេញ។ ដើម្បីឱ្យការស្រាវជ្រាវនេះទទួលបានជោគជ័យពោលគឺទាមទារឱ្យព័ត៌មាន និងប្រភពទិន្នន័យដែលទទួលបានត្រូវមានប្រភពច្បាស់លាស់គឺៈ

**ក.ទិន្នន័យទីមួយៈ** ទិន្នន័យនេះ នឹងត្រូវប្រមូលតាមរយៈកម្រងសំណួរសម្រាប់សម្ភាស និងកម្រងសំណួរសម្រាប់បំពេញ ជាមួយភាគីពាក់ព័ន្ធក្នុងគោលបំណងរកឱ្យឃើញនូវទស្សនៈអ្នកចូលរួម និងបញ្ហាប្រឈមនានាលើការអនុវត្តកម្មវិធីអាហារូបករណ៍។

កម្រងសំណួរសម្រាប់សម្ភាសៈ គឺសម្ភាសប្រធានមន្ទីរអប់រំនិងមន្ត្រីការិយាល័យមន្ទីរអប់រំដែលពាក់ព័ន្ធ នាយក នាយិកា នាយករង នាយិការង គ្រូបង្រៀន និងដើម្បីស្វែងរកពីយន្តការនៃការគ្រប់គ្រង និងការវិភាជន៍ថវិកា និងយន្តការនៃការបើកថវិការហូតដល់ដៃសិស្សអាហារូបករណ៍។

កម្រងសំណួរសម្រាប់បំពេញៈ គឺរៀបចំជាកម្រងសំណួរសម្រាប់សួរដល់ប្រធានមន្ទីរអប់រំ មន្ត្រីពាក់ព័ន្ធ នាយក នាយិកា នាយករង នាយិការង គ្រូបង្រៀន មាតាបិតាឬអាណាព្យាបាលសិស្ស និងសិស្សថ្នាក់ទី៤ ទី៥ ទី៦ ដើម្បីស្វែងរកភាពពេញចិត្ត និងអត្ថប្រយោជន៍ ព្រមទាំងបញ្ហាប្រឈមលើការអនុវត្តកម្មវិធីអាហារូបករណ៍នេះ។

**ខ.ទិន្នន័យទីពីរៈ** ទិន្នន័យបន្ទាប់បន្សំប្រមូលពីឯកសារបោះពុម្ពនានា និងរបាយការណ៍ស្នាដៃរបស់អ្នកស្រាវជ្រាវកន្លងមក ក្នុងគោលបំណងសិក្សាស្វែងយល់ពីទ្រឹស្តីនានា ដើម្បីធ្វើជាការអំណះអំណាងគាំទ្រដល់ការស្រាវជ្រាវ។

## ៣.៥. វិធីសាស្ត្រវិភាគទិន្នន័យ

ដើម្បីឆ្លើយតបទៅនឹងស្ថានភាពព្រមទាំងតម្រូវការជាក់ស្តែង ការសិក្សាជាលក្ខណៈបរិមាណវិស័យ និងគុណវិស័យត្រូវបានជ្រើសរើសជាវិធីសាស្ត្រនៃការស្រាវជ្រាវ ដើម្បីប្រមូលទិន្នន័យពីក្រុមគោលដៅនីមួយៗ។ ទិន្នន័យនឹងត្រូវវិភាគដាច់ដោយឡែកទៅតាមគោលដៅនីមួយៗនៅជំហានដំបូង បន្ទាប់មកនឹងទាញចេញនូវរូបភាពរួមដើម្បីឈានទៅកំណត់ឱ្យបានច្បាស់នូវកត្តាទាំងបីគឺ ការគ្រប់គ្រង ដំណើរការអនុវត្ត និងផលប៉ះពាល់ពីការផ្តល់អាហារូបករណ៍។ ដើម្បីសម្រួលដល់ការស្រាវជ្រាវមានដំណើរការល្អ ក្នុងការវិភាគលើការរំពឹងទុក និងធ្វើការអះអាងត្រឹមត្រូវក្នុងស្ថានភាពបច្ចុប្បន្នលើសមត្ថភាពជាក់ស្តែងក្នុងការអនុវត្តកម្មវិធីអាហារូបករណ៍សិស្សក្រីក្រ គឺការវិភាគទិន្នន័យប្រើប្រាស់កម្មវិធី SPSS សម្រាប់វិភាគសំណួរបែបបរិមាណវិស័យ(quantitative)។ ការវិភាគសំណួរបែបគុណភាព(qualitative) មានលក្ខណៈជាការប្រមូលផ្តុំនូវគំនិតទស្សនៈការយល់ឃើញដើម្បីយកមកប្រៀបធៀបទៅនឹងយន្តការ និងគោលការណ៍ណែនាំប្រតិបត្តិរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ការវិភាគបែបនេះគឺបានមកពីសម្ភាសដែលទទួលចម្លើយបានពីប្រធានមន្ទីរអប់រំនិងមន្ត្រីការិយាល័យមន្ទីរអប់រំដែលពាក់ព័ន្ធ នាយក នាយិកា នាយករង នាយិការង និងគ្រូបង្រៀន។

# ជំពូកទី៤
# លទ្ធផល និងការពិភាក្សា

# ជំពូកទី៤
# លទ្ធផល និងការពិភាក្សា

លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ គឺជាការវាស់វែង និងចង្អុលបង្ហាញពីលទ្ធផលក្នុងការអនុវត្តកម្មវិធីអាហារូបករណ៍សិស្សក្រីក្រ ដែលឆ្លុះបញ្ចាំងពីប្រសិទ្ធភាព និងប្រសិទ្ធផលក្នុងការអនុវត្តកម្មវិធីនេះក្នុងកម្រិតណាមួយដែលអាចផ្តល់ជាមតិ គំនិត និងជាសូចនាករថ្មីមួយក្នុងការពិនិត្យតាមដានសម្រាប់មន្ត្រី ឬស្ថាប័នក្រសួងអប់រំ យុវជន និងកីឡា ដើម្បីរៀបចំ និងកែលម្អឡើងវិញឱ្យកាន់តែមានភាពប្រសើរ និងបង្កើតជាគោលនយោបាយអាហារូបករណ៍មួយឱ្យបានត្រឹមត្រូវ ទន្ទឹមនឹងនេះដែរ លទ្ធផលនេះជួយដល់ស្ថាប័នពាក់ព័ន្ធក្នុងការធ្វើសេចក្តីសម្រេចចិត្តមួយដ៏មានភាពឆ្លាតវៃ ដើម្បីជួយឧបត្ថម្ភដល់សិស្សក្រីក្រក្នុងការបន្តការសិក្សារបស់ពួកគេ និងជួយសិស្សក្រីក្រក្នុងការកាត់បន្ថយ ការបោះបង់ការសិក្សាមុនបញ្ចប់បឋមសិក្សា និងបន្តទៅរៀននៅមធ្យមសិក្សាទៀតផង។ ការផ្តល់ជាអាហារូបករណ៍សិស្សក្រីក្រជួយឱ្យការសិក្សាប្រកបដោយសមភាព ក្នុងការសម្រេចបាននូវគោលនយោបាយនៃការអប់រំសម្រាប់ទាំងអស់គ្នា ជាពិសេសទៅទៀត កម្មវិធីនេះជួយជាធាតុចូលក្នុងការបង្កើតសូចនាករថ្មីមួយ ទាក់ទងនឹងការផ្តល់អាហារូបករណ៍ ព្រមទាំងជាគំនិតខ្លះក្នុងការជួយមន្ត្រីអប់រំធ្វើគោលនយោបាយស្តីពីអាហារូបករណ៍សិស្សក្រីក្រ។

## ៤.១ ព័ត៌មានទូទៅរបស់អាណាព្យាបាល និងសិស្សទទួលអាហារូបករណ៍

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានធ្វើឡើងនៅក្នុងសាលាបឋមសិក្សាចំនួនប្រាំពីរ នៅក្នុងរាជធានីភ្នំពេញ ដែលក្នុងនោះមាន៖ (១)សាលាបឋមសិក្សាសន្តិភាព (២)សាលាបឋមសិក្សាវត្តគ្រួស (៣)សាលាបឋមសិក្សាកោះដាច់ (៤)សាលាបឋមសិក្សាព្រៃស្ពឺ (៥)សាលាបឋមសិក្សាហ៊ុនសែនព្រែកប្រា (៦)សាលាបឋមសិក្សាចាក់អង្រែភូមិ៣ និង(៧)សាលាបឋមសិក្សាអូហ្គុរ៉ាត្រកៀត ក្នុងខណ្ឌទាំង៧របស់រាជធានីភ្នំពេញដែលមានអនុវត្តកម្មវិធីអាហារូបករណ៍សិស្សក្រីក្រ។ សំណាកគំរូសរុបចំនួន១៧២នាក់ ត្រូវបានកំណត់តាមវិធីសាស្ត្រផ្សេងៗគ្នា ដោយក្នុងនោះរួមមានបុគ្គលសំខាន់ៗដូចជាប្រធានមន្ទីរអប់រំ (គណៈកម្មការគ្រប់គ្រងអាហារូបករណ៍រាជធានី) ចំនួន ១រូប មន្ត្រីការិយាល័យនៃមន្ទីរអប់រំ ចំនួន ៣រូប មន្ត្រីការិយាល័យអប់រំខណ្ឌ(គណៈកម្មការគ្រប់គ្រងអាហារូបករណ៍ខណ្ឌ) ចំនួន ៧រូប នាយកឬនាយិកា ចំនួន ៧រូប និងគ្រូទទួលបន្ទុកថ្នាក់ចំនួន ៧រូប ត្រូវបានកំណត់តាមគោលបំណងទាំងចំនួន និងការជ្រើសរើសសម្រាប់បំពេញកម្រងសំណួរ ព្រោះថាអ្នកទាំងនោះសុទ្ធសឹងជាបុគ្គលសំខាន់ៗ(Key Informats) ដែលទទួលខុសត្រូវលើកម្មវិធីផ្តល់អាហារូបករណ៍សម្រាប់សិស្សក្រីក្រ តាំងពីថ្នាក់រាជធានីរហូតដល់ថ្នាក់មូលដ្ឋាន។

ទន្ទឹមនឹងនេះដែរ ចំនួនសិស្សក្រីក្រ ៧០នាក់ ដែលបានទទួលអាហារូបករណ៍ពីកម្មវិធី និងអាណាព្យាបាលរបស់សិស្សចំនួន ៧០នាក់ ត្រូវបានកំណត់តាមគោលបំណង និងការជ្រើសរើសដោយចៃដន្យសម្រាប់ធ្វើការបំពេញកម្រងសំណួរ ហើយចំនួនសិស្ស ព្រមទាំងអាណាព្យាបាលរបស់សិស្សទាំងនោះ ត្រូវបានបែងចែកស្មើៗគ្នា(Quota Sampling) ដោយកំណត់យកសិស្ស ១០នាក់ និងអាណាព្យាបាល ១០នាក់ ពីសាលាបឋមសិក្សានីមួយៗ។

**៤.១.១ ព័ត៌មានទូទៅរបស់សិស្សដែលបានទទួលអាហារូបករណ៍សិស្សក្រីក្រ**

ក្នុងក្រាហ្វិកទី១ ខាងក្រោមបង្ហាញពីលទ្ធផលនៃការបំពេញកម្រងសំណួរសិស្សដែលបានទទួលអាហារូបករណ៍សិស្សក្រីក្រ រៀននៅបឋមសិក្សាក្នុងសាលាបឋមទាំងប្រាំពីរនោះថា សិស្សដែលបានចូលរួមបំពេញកម្រងសំណួរដល់ការសិក្សាស្រាវជ្រាវនេះមានសិស្សដែលរៀនថ្នាក់ទី៤ ចំនួន ២៧.១ភាគរយ ថ្នាក់ទី៥ ចំនួន ៣៨.៦ភាគរយ និងថ្នាក់ទី៦ ចំនួន ៣៤.៣ភាគរយ ដែលក្នុងចំណោមនោះភាគច្រើនជាសិស្សស្រី ៦០ភាគរយ រីឯសិស្សប្រុសមានតែ ៤០ភាគរយទេ។ បើទោះបីជាសាលាទាំងនោះមានទីតាំងស្ថិតនៅក្នុងរាជធានីភ្នំពេញ តែក៏មានសាលាខ្លះដែលនៅទីប្រជុំជនក្នុងរាជធានីភ្នំពេញចំនួន ៤២.៩ភាគរយ ខ្លះនៅតំបន់រោងចក្រចំនួន ១៤.២ភាគរយ និងខ្លះទៀតនៅជាយក្រុងចំនួន ៤២.៩ភាគរយដែរ។

**ក្រាហ្វិកទី1៖ ស្ថិតិសិស្សដែលបានចូលរួមបំពេញកម្រងសំណួរ**



ក្នុងក្រាហ្វិកទី២ខាងក្រោម បង្ហាញពីមុខរបរអាណាព្យាបាលសិស្សអាហារូបករណ៍ក្រីក្រដែលរៀននៅតាមសាលាបឋមសិក្សានីមួយៗ ហើយលទ្ធផលបានបង្ហាញថា មាតាបិតារបស់សិស្សទាំងនោះប្រមាណជា ៦០ភាគរយ មានមុខរបរជាកម្មករ ១២.៩ភាគរយ ជាកសិករ ៥.៧ភាគរយ ជាអ្នករត់ម៉ូតូឌុប ៥.៧ភាគរយ ជាមន្ត្រីរាជការ ៤.៣ភាគរយ ជាសន្តិសុខ ៤.៣ភាគរយ លក់ដូរបន្តិចបន្តួចនៅផ្ទះ ឬផ្សារ និង៧.១ភាគរយ ជាកូនកំព្រារស់នៅជាមួយសាច់ញាតិ។ ក្នុងចំណោមសាលាទាំងប្រាំពីរ នៅក្នុងសាលាបឋមសិក្សាអូហ្វ៉ាត្រកៀតដែលស្ថិតនៅក្នុងខណ្ឌដង្កោ ចំនួន៩០ភាគរយ សាលាបឋមសិក្សាចាក់អង្រែភូមិ៣ ខណ្ឌមានជ័យ ចំនួន៨០ភាគរយ និងសាលាបឋមសិក្សាព្រៃស្ពឺ ខណ្ឌពោធិ៍សែនជ័យចំនួន៧០ភាគរយ ជាកម្មករ នេះដោយសារតែតំបន់នោះស្ថិតនៅជាយរាជធានីភ្នំពេញក្នុងតំបន់រោងចក្រ ដែលប្រជាជនភាគច្រើននៅទីនោះធ្វើការរោងចក្រដើម្បីរកចំណូលផ្គត់ផ្គង់គ្រួសារ។ ទន្ទឹមនឹងនេះ លទ្ធផលក៏បានបង្ហាញដែរថា សិស្សអាហារូបករណ៍ចំនួន ៧.១ភាគរយ ជាកូនកំព្រាដែលរស់នៅជាមួយសាច់ញាតិជាអាណាព្យាបាលនៅសាលាបឋមសិក្សាកោះដាច់ ចំនួន២០ភាគរយ សាលាបឋមសិក្សាព្រៃស្ពឺ ចំនួន១០ភាគរយ សាលាបឋមសិក្សាហ៊ុនសែនព្រែកប្រា ចំនួន១០ភាគរយ និងសាលាបឋមសិក្សាចាក់អង្រែភូមិ៣ ចំនួន១០ភាគរយ។ ប៉ុន្តែតាមរយៈលទ្ធផលនេះ ក៏គួរឱ្យមានការភ្ញាក់ផ្អើលផងដែរ ដែលមាតាបិតាសិស្សក្រីក្រនៅសាលាបឋមសិក្សាវត្តគ្រួស ចំនួន២០ភាគរយ សាលាបឋមសិក្សាកោះដាច់ ចំនួន១០ភាគរយ និងសាលាបឋមសិក្សាចាក់អង្រែភូមិ៣ ចំនួន១០ភាគរយ ជាមន្ត្រីរាជការឬគ្រូបង្រៀន ក៏ប៉ុន្តែជីវភាពនៅតែលំបាក នេះគឺមកពីអ្នកដែលរកចំណូលសម្រាប់ផ្គត់ផ្គង់គ្រួសារមានតែម្នាក់ និងមានសមាជិកច្រើនក្នុងគ្រួសារដែលធ្វើឱ្យសិស្សទាំងនោះស្ថិតនៅក្នុងជីវភាពលំបាក ហើយគ្រួសារមិនអាចផ្គត់ផ្គង់ការសិក្សារបស់ពួកគេបានគ្រប់គ្រាន់។

**ក្រាហ្វិកទី 2៖ មុខរបរមាតាបិតា ឬអាណាព្យាបាលសិស្សអាហារូបករណ៍ក្រីក្រ**



៤.១.២ ព័ត៌មានទូទៅរបស់អាណាព្យាបាលសិស្សអាហារូបករណ៍ក្រីក្រ

ដើម្បីផ្ទៀងផ្ទាត់ទិន្នន័យ និងសិក្សាឱ្យបានស៊ីជម្រៅបន្ថែម ការសិក្សាស្រាវជ្រាវក៏បានបំពេញកម្រងសំណួរអាណាព្យាបាលរបស់សិស្សផងដែរ ក្រាហ្វិកទី៣ខាងក្រោម បង្ហាញថាពី ព័ត៌មានទូទៅរបស់មាតាបិតាឬអាណាព្យាបាលសិស្សដែលបានចូលរួមបំពេញកម្រងសំណួរ ហើយក៏បានបញ្ជាក់ឱ្យកាន់តែច្បាស់អំពីមុខរបររបស់មាតាបិតា ឬអាណាព្យាបាលសិស្សអាហារូបករណ៍ និងវ័យរបស់ពួកគាត់ដែលមាន ៩១.៤ភាគរយ គឺស្ថិតក្នុងវ័យខ្លាំងក្លា និងវ័យពិចារណារកហេតុផលច្បាស់លាស់ ដែលអាចនឹងមានលទ្ធភាពជួយជំរុញការសិក្សារៀនសូត្ររបស់កូនបានល្អ ក៏ដូចជាមានលទ្ធភាពក្នុងការចូលរួមធ្វើឱ្យសម្រេចបាននូវគោលបំណងកម្មវិធីអាហារូបករណ៍សិស្សក្រីក្រនេះផងដែរ ដោយរក្សាបាននូវការសិក្សារបស់កូនៗគាត់រហូតដល់បញ្ចប់បឋមសិក្សា ក៏អាចនឹងឈានទៅសិក្សានៅកម្រិតសិក្សាជាបន្តបន្ទាប់បានដោយជោគជ័យ។

**ក្រាហ្វិកទី 3 ៖ អាយុរបស់មាតាបិតា ឬអាណាព្យាបាលសិស្សបានបំពេញកម្រងសំណួរ**




## ៤.២. ព័ត៌មានលម្អិតស្តីពីការទទួលបានអាហារូបករណ៍

### ៤.២.១ ការផ្សព្វផ្សាយអំពីកម្មវិធីអាហារូបករណ៍

ដំណើរការនៃការផ្តល់អាហារូបករណ៍ ត្រូវបានប្រព្រឹត្តឡើងជាច្រើនដំណាក់កាល ដែលរួមមានការផ្សព្វផ្សាយព័ត៌មានស្តីពីអាហារូបករណ៍ និងការជ្រើសរើស។ លទ្ធផលនៃការបំពេញកម្រងសំណួរគណៈកម្មការអាហារូបករណ៍ថ្នាក់រាជធានីនិងថ្នាក់ខណ្ឌ នាយក ឬនាយិកា និងគ្រូទទួលបន្ទុកថ្នាក់ដែលមាននៅក្នុងក្រាហ្វិកទី៤ខាងក្រោម បង្ហាញថា ការផ្សព្វផ្សាយអាហារូបករណ៍សិស្សក្រីក្រ ត្រូវបានធ្វើឡើងតាមរយៈមធ្យោបាយជាច្រើនដូច

ជា តាមរយៈលោកគ្រូអ្នកគ្រូ ការប្រជុំនិងបិទផ្សាយតាមក្តារខៀនព័ត៌មាននៅសាលារៀន និងការប្រជុំនៅតាមសង្កាត់ ក្រុមប្រឹក្សាខណ្ឌ និងអាជ្ញាធរមូលដ្ឋាន។ លទ្ធផលបង្ហាញថា ការផ្សព្វផ្សាយភាគច្រើន ត្រូវបានធ្វើឡើងតាមរយៈតាមការប្រជុំនៅសាលារៀន និងលោកគ្រូអ្នកគ្រូ។ ក្រៅពីនេះសាលាក៏បានធ្វើការផ្សព្វផ្សាយព័ត៌មានេះទៅដល់អាជ្ញាធរ មូលដ្ឋានផងដែរ តាមរយៈការប្រជុំនៅសាលាសង្កាត់ ព្រមទាំងបិទផ្សាយនៅក្តារព័ត៌មានជាដើម។ ក្រាហ្វិកទី៥ខាងក្រោម ក៏បានបង្ហាញពីមធ្យោបាយដែលសិស្សទទួលព័ត៌មានស្តីពីកម្មវិធីអាហារូបករណ៍នេះដែរ ជាលទ្ធផលគឺប្រហាក់ប្រហែលគ្នាពីលទ្ធផលដែលបានពីការបំពេញកម្រងសំណួរគ្រូៗ នាយកសាលា មន្ត្រីគម្រោង និងប្រធានមន្ទីរព្រោះថា សិស្សប្រមាណជា ៧០ភាគរយ គឺបានដឹងព័ត៌មានអាហារូបករណ៍តាមរយៈលោកគ្រូអ្នកគ្រូរបស់គេ ដែលជាការងាយស្រួលដល់សិស្សទាំងនោះឆាប់ចាប់បាននិងចងចាំបានយូរ ដោយស្តាប់ឮផ្ទាល់ពីលោកគ្រូ អ្នកគ្រូ ខណៈដែលសិស្សប្រមាណ ៩.៣ភាគរយ បានដឹងតាមរយៈការប្រជុំនៅសាលាពេលគោរពទង់ជាតិ ការបិទផ្សាយក្តារព័ត៌មាន ដោយសារសិស្សភាគច្រើន គឺមិនមានទម្លាប់អានឬមើលព័ត៌មាន និងខ្លះមិនសូវចេះអានអក្សរដែលបានបិទផ្សាយឡើយ ហើយក៏មិនសូវបានស្តាប់ប៉ុន្មានដែរពេលគោរពទង់ជាតិ ចំណែកឯមាតាបិតាភាគច្រើនដែរក៏ពុំសូវចាប់អារម្មណ៍លើក្តារខៀនព័ត៌មាន គឺផ្តោតធ្ងន់តែលើការជូនកូនទៅសាលារៀន និងទៅទទួលកូនចេញពីសាលារៀនមកវិញនោះទេ។ និងមានតែ ២.៩ភាគរយ ទេដែលដឹងតាមរយៈអាជ្ញាធរភូមិសង្កាត់ ដោយសារភាគច្រើនមិនសូវមានទំនាក់ទំនងនឹងអាជ្ញាធរភូមិសង្កាត់ ខ្លះរវល់នឹងការងាររផ្គត់ផ្គង់គ្រួសារ។

**ក្រាហ្វិកទី4 ៖ ដំណើរការផ្សព្វផ្សាយព័ត៌មានអាហារូបករណ៍បានពីមន្ត្រីទទួលបន្ទុក**



ក្រាហ្វិកទី5៖ មធ្យោបាយដែលសិស្សទទួលព័ត៌មានស្តីពីកម្មវិធីអាហារូបករណ៍




## ៤.២.២ ការជ្រើសរើសសិស្សអាហារូបករណ៍

ក្រោយពីបានផ្សព្វផ្សាយព័ត៌មានរួចមក ការស្នើសុំអាហារូបករណ៍ពីសំណាក់មាតាបិតាសិស្សមកពីគ្រួសារក្រីក្រ ត្រូវបានប្រព្រឹត្តជាពីរដំណាក់កាលសំខាន់គឺ ការពិនិត្យមើលទៅលើលក្ខខណ្ឌសមស្រប និងការចុះពិនិត្យស្ថានភាពជាក់ស្តែងនៅតាមផ្ទះសិស្សក្រីក្រដែលបានស្នើសុំ។ លទ្ធផលនៃការបំពេញកម្រងសំណួរ (ដំណាក់កាលទី១ នៃការជ្រើសរើស) គណៈកម្មការអាហារូបករណ៍ថ្នាក់រាជធានី ថ្នាក់ខណ្ឌ នាយកឬនាយិកា និងគ្រូទទួលបន្ទុកថ្នាក់ ដែលមាននៅក្នុងតារាងទី១(ទំព័រទី១១)ខាងលើ បានបង្ហាញពីលក្ខខណ្ឌនៃការជ្រើសរើសសិស្សអាហារូបករណ៍មានដូចជា៖

១)មានបណ្ណអត្តសញ្ញាណគ្រួសារក្រីក្រប្រភេទ១ ឬប្រភេទ២ ឬបណ្ណសមធម៌ផ្សេងៗ
២)មានលិខិតស្នើសុំពីអាជ្ញាធរមូលដ្ឋាននិងជាគ្រួសារជួបការលំបាកធ្វើឱ្យអវត្តមានច្រើន
៣)មិនទទួលបានអាហារូបករណ៍ពីអង្គការ ឬស្ថានប័នផ្សេងៗ
៤)មានវត្តមានច្រើនជាង ៨០% នៃថ្ងៃសិក្សា និងលទ្ធផលជាប់មធ្យមភាគ។

ក្រាហ្វិកទី៦ខាងក្រោម ក៏បានបង្ហាញពីលក្ខខណ្ឌដែលសិស្សត្រូវទទួលបានអាហារូបករណ៍នេះដែរ ប៉ុន្តែលទ្ធផលខុសពីលទ្ធផលដែលបានពីការបំពេញកម្រងសំណួរគ្រូនាយកសាលា មន្ត្រីគម្រោង និងប្រធានមន្ទីរ ព្រោះថាសិស្ស និងមាតាបិតាសិស្សប្រមាណជា ៥៦.៤ភាគរយ គឺបានដឹងពីលក្ខខណ្ឌនៃការជ្រើសរើសសិស្សអាហារូបករណ៍កម្រិតតិចតួចបំផុត ដោយមូលហេតុថា សិស្ស និងមាតាបិតាឬអ្នកអាណាព្យាបាលសិស្សពុំសូវយកចិត្តទុកដាក់នឹងលក្ខខណ្ឌទាំងនោះទេ ដោយគាត់គិតថាគ្រួសារគាត់ក្រីក្រ អញ្ចឹងគ្រាន់តែមករៀន និងឱ្យកូនមករៀនជាប្រចាំទៅ គឺទទួលបានប្រាក់អាហារូបករណ៍ក្រីក្រនោះហើយ និងម្យ៉ាងទៀតគឺភាគច្រើននៃសិស្សទាំងនេះរៀននៅថ្នាក់ទី៤ ឬខ្លះទៀតជាសិស្សដែលរៀនមិនសូវពូកែ រីឯ ២៨.៦ភាគរយ បានយល់ដឹងពីលក្ខខណ្ឌជ្រើសរើសកម្រិតមធ្យម ក៏ព្រោះតែពួកគាត់យកចិត្តទុកដាក់ខ្លាំងនឹងប្រាក់អាហារូបករណ៍ដែលទទួលបាននោះ បើគាត់បាត់បង់ប្រាក់នោះទៀត គឺជីវភាពគាត់កាន់តែលំបាកហើយ ចំណែកឯ ១៤.៣ភាគរយ ទៀតយល់ដឹងពីលក្ខខណ្ឌជ្រើសរើសកម្រិតបង្គួរ ព្រោះភាគច្រើនក្នុងចំណោមនេះមានកូន ឬប្អូន ឬ ក្មួយៗ រៀននៅសាលារៀនជាមួយកូនដែលទទួលបានប្រាក់អាហារូបករណ៍ដែរ ជាហេតុធ្វើឱ្យគាត់ទទួលបានព័ត៌មានច្រើន និង០.៧ភាគរយប៉ុណ្ណោះដែលយល់ដឹងពីលក្ខខណ្ឌជ្រើសរើសបានល្អ ដោយសារភាគច្រើនក្នុងចំណោមនេះជាកូនមន្ត្រីរាជការ ឬគ្រូបង្រៀន ឬមានបងប្អូន ឬសាច់ញាតិជាគ្រូបង្រៀននៅសាលារៀននោះ។

**ក្រាហ្វិកទី6៖ លក្ខខណ្ឌជ្រើសរើសអាហារូបករណ៍ដែលសិស្សនិងមាតាបិតាសិស្សបានដឹង**



ដើម្បីជ្រើសរើសបានសិស្សដែលត្រូវផ្តល់អាហារូបករណ៍ គឺគណៈកម្មការជ្រើសរើសត្រូវចុះទៅដល់ផ្ទះរបស់សិស្ស ក្នុងគោលបំណងធ្វើការផ្ទៀងផ្ទាត់លក្ខណៈវិនិច្ឆ័យជាមួយមួយនឹងស្ថានភាពជាក់ស្តែងរបស់គ្រួសារសិស្ស។ យ៉ាងណាមិញ លទ្ធផលនៅក្នុងដ្យាក្រាមទី១នៃការបំពេញកម្រងសំណួរ(ដំណាក់កាលទី២នៃការជ្រើសរើស) គណៈកម្មការអាហារូបករណ៍ថ្នាក់រាជធានី ថ្នាក់ខណ្ឌ នាយកឬនាយិកា និងគ្រូទទួលបន្ទុកថ្នាក់គឺបានបង្ហាញថា គណៈកម្មការជ្រើសរើសធ្លាប់បានចុះពិនិត្យផ្ទៀងផ្ទាត់ពីស្ថានភាពដល់ផ្ទះសិស្ស ១០០ភាគរយ។ ប៉ុន្តែលទ្ធផលនៃការបំពេញកម្រងសំណួរសិស្ស និងមាតាបិតាសិស្សក្នុងក្រាហ្វិកទី៧ខាងក្រោម បានបង្ហាញថា មិនមានការចុះផ្ទៀងផ្ទាត់ដល់ផ្ទះសិស្សរហូតដល់៨៧.៩ភាគរយ បានចុះផ្ទៀងផ្ទាត់ដោយគ្រូ នាយកតែ ៥ភាគរយ បានចុះផ្ទៀងផ្ទាត់ដោយអាជ្ញាធរភូមិ សង្កាត់មានតែ ៣.៦ភាគរយ ប៉ុណ្ណោះ និង៣.៥ភាគរយ បានបញ្ជាក់ថាមិនដឹងពីបញ្ហានេះ។ កត្តាទាំងនេះគឺមកពីគណៈកម្មការបានរៀបចំផែនការចុះពិនិត្យហើយ តែដោយមិនមានពេលវេលា និងខ្វះថវិកាគ្រប់គ្រាន់សម្រាប់អនុវត្តជាក់ស្តែងនៅតាមមូលដ្ឋានសាលារៀន និងបណ្តាលមកពីភាពមមាញឹកខ្លាំងនឹងការងារបន្ទាន់ៗជាច្រើន ដែលត្រូវធ្វើនៅដើមឆ្នាំសិក្សានីមួយៗ។

**ដ្យាក្រាមទី1៖ ការចុះផ្ទៀងផ្ទាត់ព័ត៌មានរបស់គណៈកម្មការជ្រើសរើសនៅតាមផ្ទះសិស្ស**



ក្រាហ្វិកទី7៖ ការបញ្ជាក់របស់សិស្ស មាតាបិតាសិស្សពីការចុះពិនិត្យផ្ទៀងផ្ទាត់ដល់ផ្ទះ




ស្របជាមួយគ្នានេះដែរការសម្រេចផ្តល់ ឬមិនផ្តល់ឱ្យអាហារូបករណ៍ដល់គ្រួសារសិស្សក្រីក្រណាមួយជាកត្តាសំខាន់បំផុតមួយផងដែរ។ លទ្ធផលនៅក្នុងដ្យាក្រាមទី២ នៃការបំពេញកម្រងសំណួរគណៈកម្មការអាហារូបករណ៍ថ្នាក់រាជធានី ថ្នាក់ខណ្ឌ ថ្នាក់សាលារៀន និងគ្រូទទួលបន្ទុកថ្នាក់ដែលមានសិស្សអាហារូបករណ៍ គឺបានបង្ហាញថាគណៈកម្មការជ្រើសរើសបានសម្រេចការជ្រើសរើសសិស្សអាហារូបករណ៍ក្រីក្រ ក្រោមការឯកភាពយល់ព្រមពីសមាសភាពគណៈកម្មការទាំងមូល ដោយមានកិច្ចប្រជុំត្រឹមត្រូវ ១០០ភាគរយ ដែលស្របតាមលក្ខខណ្ឌនៃការជ្រើសរើសបានល្អប្រសើរ។

ដ្យាក្រាមទី2៖ ការប្រជុំសម្រេចជ្រើសរើសសិស្សអាហារូបករណ៍ក្រីក្ររបស់គណៈកម្មការ




### ៤.២.៣ ប្រសិទ្ធភាពនៃការផ្តល់អាហារូបករណ៍

ការរក្សាសិស្សអាហារូបករណ៍ដែលបានជ្រើសរើសរួចជាផ្លូវការឱ្យស្ថិតនៅក្នុងប្រព័ន្ធនៃការសិក្សារបស់ពួកគេគឺជាកត្តាសំខាន់ និងចាំបាច់បំផុតដែលគណៈកម្មការអាហារូបករណ៍នៅគ្រប់កម្រិតថ្នាក់ត្រូវយកចិត្តទុកដាក់និងតាមដានជាប្រចាំ។ ការរៀបចំផែនការសកម្មភាពដើម្បីអនុវត្តក្នុងដំណាក់កាលនេះ គឺត្រូវតែបញ្ចូលទៅក្នុងផែនការប្រតិបត្តិ នៅតាមអង្គភាពពាក់ព័ន្ធ ដើម្បីរួមចំណែកធ្វើឱ្យសម្រេចបាននូវគោលបំណងរបស់កម្មវិធីអាហារូបករណ៍សិស្សក្រីក្រទាំងមូល។ លទ្ធផលដូចបានរកឃើញក្នុងក្រាហ្វិកទី៨ខាងក្រោម ដែលបង្ហាញពីផែនការសកម្មភាពរបស់គណៈកម្មការអាហារូបករណ៍ថ្នាក់រាជធានីថ្នាក់ខណ្ឌ ថ្នាក់សាលារៀន និងគ្រូទទួលបន្ទុកថ្នាក់ បានរៀបចំផែនការរៀងៗខ្លួនជាច្រើនដូចជា ការជួយឧបត្ថម្ភជាសម្ភារៈសិក្សាបន្ថែម ការអប់រំនិងផ្តល់កម្លាំងចិត្ត ការសម្របសម្រួលឱ្យបានសិក្សានូវជំនាញផ្សេងៗ ការតាមដានវត្តមានសិក្សា និងដោយជួបជាមួយមាតាបិតាឬអាណាព្យាបាលសិស្សដោយផ្ទាល់ ឬដោយប្រយោល និងការប្រជុំនិងពិនិត្យតាមដានជាដើម។ ផែនការសកម្មភាពទាំងនេះពិតជាប្រសិទ្ធភាពខ្ពស់ក្នុងការចូលរួមចំណែកធ្វើឱ្យសម្រេចបាននូវការរក្សាឱ្យក្រុមសិស្សទាំងនោះ បានទទួលការសិក្សាអប់រំរហូតចប់ភូមិសិក្សាប្រាកដណាស់។

**ក្រាហ្វិកទី8៖ ផែនការសកម្មភាពរបស់គណៈកម្មការអាហារូបករណ៍**




លទ្ធផលនៅក្នុងក្រាហ្វិកទី៨ ក៏បានបង្ហាញពីការអនុវត្តតាមផែនការជាក់ស្តែងរបស់គណៈកម្មការ និងគ្រូប្រចាំថ្នាក់ដែលសិស្សអាហារូបករណ៍បានបំពេញកម្រងសំណួរជាលទ្ធផល គឺប្រហាក់ប្រហែលគ្នាពីលទ្ធផលដែលបានពីការបំពេញកម្រងសំណួរគ្រូៗ និងគណៈកម្មការអាហារូបករណ៍ដែរ ព្រោះថាសិស្សប្រមាណជា ៨៤ភាគរយ គឺបានបញ្ជាក់ថាគ្រូមានការត្រួតពិនិត្យតាមសិស្ស ជំរុញការសិក្សា លើកទឹកចិត្តសិស្សជាប្រចាំ និង ៣៣ភាគរយ បានទទួលសម្ភារៈសិក្សាបន្ថែមពីជួយជ្រោមជ្រែងរបស់គ្រូ។

**ក្រាហ្វិកទី9៖ ការបញ្ជាក់របស់សិស្ស ពីការយកចិត្តទុកដាក់របស់គ្រូមកលើពួកគេ**



អ្វីដែលគួរឱ្យកត់សម្គាល់ក្នុងក្រាហ្វិកទី១០ មួយទៀតគឺ ការរំពឹងទុកដែលថាសិស្សអាហារូបករណ៍នឹងបន្តរៀនរហូតដល់ចប់បឋមសិក្សារបស់ថ្នាក់មន្ទីរអប់រំមាន ៧៥ភាគរយ ថ្នាក់ការិយាល័យអប់រំមាន ៧១ភាគរយ ថ្នាក់សាលារៀនមាន ៨២ភាគរយ ដោយសំអាងលើរបាយការណ៍ឆ្នាំចាស់ៗកន្លងមក រីឯមាតាបិតាឬអ្នកអាណាព្យាបាលសិស្សមានការតាំងចិត្តឱ្យកូនរៀនចប់បឋមសិក្សារហូតដល់ ៩៣ភាគរយ ដោយគាត់បានប្តេជ្ញាថានឹងបំពេញឱ្យបាន និងម្យ៉ាងទៀតកូនៗគាត់បានទទួលអាហារូបករណ៍ពីរាជរដ្ឋាភិបាលក្នុងការទំនុកបំរុងឱ្យ ក្នុងការសិក្សាខ្លះហើយ និងសិស្សមានតាំងចិត្តរហូតដល់ ៩៩ភាគរយ ព្រោះថាឪពុកម្តាយរបស់គាត់បានធ្វើកិច្ចសន្យាជាមួយសាលារួចហើយ។ ចំណុចទាំងនេះបង្ហាញយ៉ាងច្បាស់ថា ពិតជាសមស្របតាមវត្ថុបំណងនៃកម្មវិធីអាហារូបករណ៍ប្រាកដណាស់។

**ក្រាហ្វិកទី10៖ ការរំពឹងទុកថាសិស្សអាហារូបករណ៍នឹងបន្តរៀនរហូតដល់ចប់បឋមសិក្សា**




ក្នុងនោះផងដែរតាមរយៈការសម្ភាសផ្ទាល់ជាមួយសិស្ស និងមាតាបិតាឬអ្នកអាណាព្យាបាលសិស្សដែលមានក្នុងក្រាហ្វិកទី១១ បានបង្ហាញពីបញ្ហាប្រឈមមួយចំនួនដូចជា ៦៥% នៃសិស្សពីសាលាដែលបានជ្រើសរើសមានបញ្ហាខ្លាំងចំពោះជីវភាព ដោយពួកគាត់បានទទួលប្រាក់ពីឪពុកម្តាយពេលមកសាលាតិចជាងមួយពាន់រៀលក្នុងមួយថ្ងៃ ដោយមិនបានហូបបាយពេលព្រឹកទៀតក៏មាន ឯខ្លះទៀតគឺមិនមានប្រាក់តែម្តង ៥៩% ក្នុងចំណោមពួកគេខ្វះខាតសម្ភារៈសិក្សា ព្រោះកាបូបស្ពាយខ្លះរហែក ខ្លះមិនមាន(ច្រកស្បោង) សរសេរសៀវភៅចូលគ្នាមុខវិជ្ជាខុសគ្នា សម្លៀកបំពាក់ចាស់ខ្លាំង និង៣៩%ក្នុងចំណោមពួកគេខ្វះខាតមធ្យោបាយធ្វើដំណើរប្រចាំថ្ងៃទៅសាលារៀន រាល់ថ្ងៃគឺដើរមករៀន។ លើសពីនេះទៀត ១៩% នៃអាណាព្យាបាលបានប្រឈមនិងផលលំបាក ហើយចំណាយពេលវេលាច្រើន ក្នុងការធ្វើដំណើរទៅចូលរួមបើកប្រាក់អាហារូបករណ៍ ដោយ

ខ្លះមិនមានមធ្យោបាយ ខ្លះរវល់នឹងការងារចិញ្ចឹមជីវិតប្រចាំថ្ងៃ ខ្លះសុំច្បាប់ពីការងារមិនបាន(គេកាត់លុយ) ខ្លះចាស់ជរាពិបាក ធ្វើដំណើរមក។

**ក្រាហ្វិកទី11៖ ការសម្ភាសផ្ទាល់ជាមួយសិស្ស និងមាតាបិតាឬអ្នកអាណាព្យាបាល**




ការចូលរួមកាត់បន្ថយបន្ទុកចំណាយប្រចាំថ្ងៃ លើការសិក្សារបស់សិស្សក្រីក្រជួបការលំបាក គឺជាចំណុចស្នូលមួយនៃកម្មវិធីអាហារូបករណ៍សិស្សក្រីក្រ។ ក្រាហ្វិកទី១២ ខាងក្រោមបានបង្ហាញពីការយល់ឃើញរបស់មាតាបិតាឬអ្នកអាណាព្យាបាល និងសិស្សក្រីក្រលើបរិមាណថវិកាអាហារូបករណ៍ដែលទទួលបានរួមមាន៖ ៥៦ភាគរយ ក្នុងចំណោមសិស្ស និងមាតាបិតាសិស្សឬអ្នកអាណាព្យាបាលសិស្សដែលបានចូលរួមបំពេញកម្រងសំណួរយល់ឃើញថាថវិកាអាហារូបករណ៍គឺបានជួយដោះស្រាយបន្ទុកចំណាយលើការសិក្សាបានកម្រិតបង្គួរ ដោយបានជួយសម្រួលជីវភាពគ្រួសារគាត់មួយផ្នែកធំក្នុងការផ្គត់ផ្គង់ជាថវិកាសម្រាប់ការរៀនសូត្របានល្អ។ ចំណែក ៥៧ភាគរយ ផ្សេងទៀតបញ្ជាក់ថាថវិកាអាហារូបករណ៍នេះបានជួយដោះស្រាយលើការសិក្សាបានក្នុងកម្រិតមធ្យម ដោយថវិកានេះបានបំពេញនូវកង្វះខាតរបស់ពួកគាត់សម្រាប់ផ្គត់ផ្គង់លើសម្ភារៈសិក្សា សំលៀកបំពាក់ និងការហូបចុកនៅសាលារៀន ដែលបានជួយឱ្យមានលទ្ធភាព និងពេលវេលាគ្រប់គ្រាន់ក្នុងការសិក្សារៀនសូត្របានល្អ និងបានផ្តល់ជាកំលាំងចិត្តក្នុងការជួយជំរុញនិងតាមដានការសិក្សារបស់កូនៗគាត់ផងដែរ។ មានតែ ៦ភាគរយ ប៉ុណ្ណោះដែលបានបញ្ជាក់ថាតិចតួច ដោយសារភាគច្រើន គឺជាគ្រួសារដែលមានកូនរៀនច្រើននាក់ ហើយ

ប្រាក់អាហារូបករណ៍គឺទទួលបានតែម្នាក់ ហើយថវិកានេះគ្រាន់តែបានជួយលើការផ្គត់ផ្គង់សម្ភារសិក្សា និងសំលៀកបំពាក់បានមួយចំនួនតែប៉ុណ្ណោះ។

**ក្រាហ្វិកទី12៖ យោបល់របស់សិស្ស និងមាតាបិតាឬអ្នកអាណាព្យាបាលអំពីបរិមាណនៃប្រាក់អាហារូបករណ៍**




លទ្ធផលសិក្សាក៏ជាចំណុចស្នួលសំខាន់មួយដែរ នៃកម្មវិធីអាហារូបករណ៍សិស្សក្រីក្រ។ ក្រាហ្វិកទី១៣ ខាងក្រោមបានបង្ហាញថាសិស្សដែលទទួលប្រាក់អាហារូបករណ៍ទាំងអស់នៅសាលាទាំង៧នេះ សិស្សចំនួន ៩៨ភាគរយ គឺបានឡើងថ្នាក់និងរៀនបានចប់ថ្នាក់ទី៦ ៩៥ភាគរយ គឺបានចូលរៀននៅថ្នាក់ទី៧ នៃមធ្យមសិក្សាបឋមភូមិ ជាងនេះទៅទៀតក្នុងចំណោមពួកគេទាំងអស់ គឺមិនមានអ្នកបោះបង់ការសិក្សាឡើយ ដោយសារសិស្សទាំងនោះបានមករៀនទៀងទាត់ ខិតខំរៀនសូត្រ មានពេលវេលាគ្រប់គ្រាន់ក្នុងការសិក្សារៀនសូត្រ និងមានការយកចិត្តទុកដាក់តាមដានការសិក្សារបស់ពួកគេជាប្រចាំពីសំណាក់ លោកគ្រូ អ្នកគ្រូ សិស្សរួមថ្នាក់ និងមាតាបិតាឬអ្នកអាណាព្យាល។

**ក្រាហ្វិកទី13៖ លទ្ធផលសិក្សារបស់សិស្សអាហារូកបរណ៍**



### ៤.២.៤ ការជំរុញការផ្តល់អាហារូបករណ៍

តាមរយៈគោលការណ៍អាហារូបករណ៍ ការបើកប្រាក់អាហារូបករណ៍សិស្សក្រីក្រ ត្រូវធ្វើឡើងមានកាលកំណត់ចំនួនបីលើកក្នុងមួយឆ្នាំសិក្សា។ ក្នុងមួយលើកៗមានចំនួន ៨០ ០០០ រៀល សរុបស្មើនឹង ២៤០ ០០០រៀល សម្រាប់សិស្សម្នាក់ក្នុងមួយឆ្នាំសិក្សា។ ពិធីបើកប្រាក់ជូនសិស្សអាហារូបករណ៍ក្រីក្រ ត្រូវប្រព្រឹត្តទៅនៅតាមសាលារៀននីមួយៗ មានន័យថា សិស្សអាហារូបករណ៍ទាំងអស់ជាមួយមាតាបិតា ឬអ្នកអាណាព្យាបាល ត្រូវមកជួបជុំគ្នាដើម្បីទទួលប្រាក់អាហារូបករណ៍នៅតាមសាលារៀនរបស់ខ្លួននៅចំពោះមុខ គ.អ.ម. និងតំណាងមកពីថ្នាក់ក្រុង ស្រុក ខណ្ឌ និងឬ ថ្នាក់រាជធានី ខេត្ត។

លទ្ធផលក្នុងដ្យាក្រាមទី៣ ខាងក្រោមបង្ហាញថា ៧៤ភាគរយ ក្នុងចំណោមសិស្សទាំងអស់ដែលបានបំពេញកម្រងសំណួរ គឺបានដឹងពីចំនួនលើកនៃការបើកប្រាក់អាហារូបករណ៍ រីឯ ១៦ភាគរយ ទៀតគឺមិនច្បាស់លាស់ ហើយប្រមាណ ១០ភាគរយ ទៀតគឺយល់ច្រឡំ លទ្ធផលនេះបង្ហាញថា សិស្សភាគច្រើនគឺបានដឹងព័ត៌មាននៃការបើកប្រាក់អាហារូបករណ៍ក្នុងកម្រិតល្អបង្គួរ។

**ដ្យាក្រាមទី3៖ ព័ត៌មានស្តីពីការបើកប្រាក់អាហារូបករណ៍ដែលទទួលបានពីសិស្ស**




ចំពោះលទ្ធផលក្នុងដ្យាក្រាមទី៤ខាងក្រោម បញ្ជាក់ថា សិស្សប្រមាណ ៩៩ភាគរយ ក្នុងចំណោមសិស្សដែលបានបំពេញកម្រងសំណួរ គឺបានទទួលប្រាក់គ្រប់ចំនួន និងមានតែ ១ភាគរយ ប៉ុណ្ណោះដែលថាមិនបានគ្រប់ចំនួន ដែលអាចនិយាយបានថាសាលារៀនទាំង៧នេះ គឺបានបើកប្រាក់ជូនសិស្សបានត្រឹមត្រូវគោលការណ៍ណែនាំ។

**ដ្យាក្រាមទី4៖ ព័ត៌មានស្តីពីការបើកប្រាក់អាហារូបករណ៍ដែលទទួលបានពីសិស្ស**




ការបដិសេធមិនបើកប្រាក់ដល់សិស្សនៅថ្ងៃបើកប្រាក់ គឺជាការអនុវត្តតាមគោលការណ៍នៃកម្មវិធីអាហារូបករណ៍ ដោយសិស្សត្រូវមករៀនឱ្យបានយ៉ាងហោចណាច់៨០ភាគរយនៃថ្ងៃសិក្សា និងរៀនបានជាប់មធ្យមភាគ ហើយនៅថ្ងៃបើកប្រាក់ត្រូវមានវត្តមានទាំងសិស្សដែលទទួលបានអាហារូបករណ៍ និងមាតាបិតាឬអ្នកអាណាព្យាបាលរបស់គេយ៉ាងណាមុិញតាមលទ្ធផលដ្យាក្រាមទី៥ ខាងក្រោមបានបង្ហាញថា សិស្សប្រមាណជា២៥ភាគរយ ក្នុងចំណោមសិស្សដែលបានបំពេញកម្រងសំណួរត្រូវបានបដិសេធមិនបើកប្រាក់ឱ្យក្នុងថ្ងៃបើកប្រាក់ ដោយមិនមានវត្តមានពីមាតាបិតា ឬអ្នកអាណាព្យាបាលដែលប្រការនេះគឺមកពីមាតាបិតា ឬអ្នកអាណាព្យាបាលសិស្សទាំងនោះគ្មានមធ្យោបាយមកបើកប្រាក់ ឯខ្លះទៀតជាប់រវល់កិច្ចការងាររកស៊ីចិញ្ចឹមជីវិត តែត្រូវបានបើកឱ្យវិញនៅពេលក្រោយបន្ទាប់ពីមាតាបិតា ឬអ្នកអាណាព្យាបាលសិស្សមកបើករួមជាមួយសិស្ស។ ប្រការនេះគួរមានលក្ខខណ្ឌណាមួយផ្សេងបន្ថែម ដើម្បីជួយសម្រួលដល់ការបើកប្រាក់នេះឱ្យមានដំណើរការរលូន ហើយមិនប៉ះពាល់ដល់ពេលវេលាទាំងមាតាបិតាឬអ្នកអាណាព្យាបាលសិស្ស ក៏ដូចជាគណៈកម្មការដែរ។

**ដ្យាក្រាមទី5៖ ព័ត៌មានស្តីពីខកខានមិនអាចបើកប្រាក់បាន ដែលទទួលបានពីសិស្ស**



ការទម្លាក់ថវិកាអាហារូបករណ៍ក៏ជាផ្នែកមួយសំខាន់ក្នុងដំណើរការនៃកម្មវិធីអាហារូករណ៍ លទ្ធផលក្នុងក្រាហ្វិកទី១៤ ខាងក្រោម បង្ហាញថាការទម្លាក់ថវិកាដែលបានទាន់ពេលនៅកម្រិតថ្នាក់មន្ទីរអប់រំមាន ៧៥ភាគរយ កម្រិតថ្នាក់ការិយាល័យអប់រំមាន ៧១ភាគរយ កម្រិតសាលារៀនមាន ៦៤ភាគរយ ប៉ុណ្ណោះ។ ដូចនេះអាចបញ្ជាក់ថាលំហូរនៃការទម្លាក់ថវិកានៅមានលក្ខណៈយឺតយ៉ាវ ដែលទាមទារឱ្យមានការជំរុញបន្ថែមពីគ្រប់ភាគីពាក់ព័ន្ធ ដើម្បីឱ្យការផ្តល់ប្រាក់អាហារូបករណ៍នោះបានជួយដោះស្រាយតម្រូវការរបស់សិស្សបានពិតប្រាកដ និងបានទាន់ពេលវេលា។

**ក្រាហ្វិកទី14៖ ភាពទៀងទាត់នៃលំហូរថវិកាអាហារូបករណ៍នៅតាមកម្រិត**




ការជួយគាំទ្រសិស្សឱ្យបន្តទទួលបានអាហារូបករណ៍នៅភូមិសិក្សា ជាបន្តបន្ទាប់ គឺជាគោលការណ៍អាហារូបករណ៍មួយដែលធានារក្សាសិស្សទាំងនោះ ឱ្យស្ថិតក្នុងប្រព័ន្ធអប់រំ លទ្ធផលក្នុងក្រាហ្វិកទី១៥ ខាងក្រោម បង្ហាញថាសិស្សអាហារូបករណ៍នៅបឋមសិក្សាដែលបន្តទទួលបានប្រាក់អាហារូបករណ៍នៅមធ្យមសិក្សាបឋមភូមិ នៅកម្រិតថ្នាក់មន្ទីរអប់រំមាន ៥០ភាគរយ កម្រិតថ្នាក់ការិយាល័យអប់រំមាន ២៩ភាគរយ កម្រិតសាលារៀនមាន ១៨ភាគរយ ប៉ុណ្ណោះ។ នេះមកពីនីតិវិធីនៃការជ្រើសរើសសិស្សអាហារូបករណ៍នៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិមិនដូចគ្នា និងមិនទាន់មានគោលការណ៍បន្ស៊ីគ្នានៅឡើយ ហើយសាលាគោលដៅដែលមានសិស្សអាហារូបករណ៍ថ្នាក់ទី៦ត្រូវទៅរៀននោះ មិនទាន់មានកម្មវិធីអាហារូបករណ៍ជាដើម ដែលទាមទារឱ្យមានគោលការណ៍បន្ស៊ីគ្នារវាងបឋមសិក្សា និងមធ្យមសិក្សាឱ្យបានច្បាស់លាស់ ហើយត្រូវរៀបចំយន្តការការងារទាក់ទងគ្នាជាប្រចាំ។

ក្រាហ្វិកទី15៖ ការសម្របសម្រួលសិស្សឱ្យបន្តទទួលបានប្រាក់អាហារូបករណ៍




### ៤.២.៥ យន្តការនៃការគ្រប់គ្រង

ដើម្បីធានាបាននូវដំណើរការកម្មវិធីអាហារូបករណ៍ទាំងមូល គឺទាមទារឱ្យមានការបណ្តុះបណ្តាលដល់គ្រប់អ្នកពាក់ព័ន្ធ ជាពិសេសមន្ត្រីទទួលបន្ទុកអំពីនីតិវិធី និងលក្ខខណ្ឌផ្សេងៗដែលមានក្នុងសៀវភៅណែនាំប្រតិបត្តិ។ លទ្ធផលដ្យាក្រាមទី៦ បង្ហាញថាក្នុងរយៈពេល ៣ឆ្នាំចុងក្រោយនេះ មន្ត្រីទទួលបន្ទុកការងារអាហារូបករណ៍ធ្លាប់ទទួលបានទទួលការបណ្តុះបណ្តាលតិចជាង២ដង ៣៨ភាគរយ ធ្លាប់ទទួលការបណ្តុះបណ្តាលច្រើនជាង២ដង ៩ភាគរយ និងមិនធ្លាប់ទទួលការបណ្តុះបណ្តាលសោះរហូតដល់ ៥៣ភាគរយ។ យោងតាមការសម្ភាសផ្ទាល់ជាមួយមន្ត្រីទទួលបន្ទុកបានបញ្ជាក់ឱ្យឃើញថា ថ្នាក់មន្ទីរអប់រំ ការិយាល័យអប់រំ និងសាលារៀនពុំមានខ្ទង់ថវិកា និងពុំបានរៀបចំផែនការថវិកាគាំទ្រការបណ្តុះបណ្តាលឡើយ ដោយគ្រាន់តែបានចូលរួមប្រជុំ និងប្រើប្រាស់បទពិសោធន៍នាឆ្នាំកន្លងមកដើម្បីអនុវត្តការងារនេះ។ ចំណុចនេះគឺត្រូវរៀបចំយន្តការដោះស្រាយជាបន្ទាន់ ដើម្បីឱ្យដំណើរការប្រព្រឹត្តទៅនៃកម្មវិធីអាហារូបករណ៍ទាំងមូលកាន់តែទទួលបានប្រសិទ្ធភាពខ្ពស់ និងមានលទ្ធផលកាន់តែល្អប្រសើរឡើងថែមទៀត។

**ដ្យាក្រាមទី6៖ ការបណ្តុះបណ្តាលដល់មន្ត្រីទទួលបន្ទុកក្នុងរយៈពេល៣ឆ្នាំចុងក្រោយ**



ប៉ុន្តែទោះបីលទ្ធផលដែលបានរកឃើញដូចដ្យាក្រាមទី៦ ខាងលើពុំសូវអំណោយផលដល់ការអនុវត្តការងារនេះក្តី ក៏មន្ត្រីទទួលបន្ទុកនៅតែសប្បាយរីករាយពេញចិត្តក្នុងការទទួលយកកម្មវិធីនេះមកបន្តអនុវត្ត ក្នុងន័យជួយសិស្សក្រីក្រឱ្យមានឱកាសក្នុងការបន្តការសិក្សាបាន ដូចលទ្ធផលក្នុងដ្យាក្រាមទី៧ ខាងក្រោមបានបញ្ជាក់ពីភាពពេញចិត្តខ្លាំងរហូតដល់ ៣១ភាគរយ ដោយសារគាត់មើលឃើញថាប្រាក់អាហារូបករណ៍នេះពិតជាមានសារៈសំខាន់ និងចាំបាច់ដល់សិស្សក្រីក្រជួបការលំបាកដែលត្រូវការ ជាពិសេសគឺជួយជំរុញឱ្យសិស្សទាំងនោះបានមករៀន និងរៀនបានពូកែ។ ចំណែកការពេញចិត្ត ៦៦ ភាគរយ នោះគឺគាត់យល់ឃើញថាកម្មវិធីអាហារូបករណ៍សិស្សក្រីក្រនេះល្អហើយ តែកម្មវិធីនេះបានធ្វើឱ្យគាត់មានការមមាញឹកខ្លះៗដែរ។ និងមិនពេញចិត្តមានត្រឹមតែ ៣ ភាគរយ ប៉ុណ្ណោះ ដោយសារគាត់មិនសប្បាយចិត្តនឹងការអនុវត្តនាពេលកន្លងមកមានការស្មុគស្មាញច្រើន ជួបការលំបាកច្រើនក្នុងការដោះស្រាយជាមួយសហគមន៍ ឬពេលខ្លះមមាញឹកខ្លាំងជាមួយកិច្ចការនេះ។ នេះជាកត្តាយ៉ាងសំខាន់ក្នុងការបន្តនិរន្តភាពនៃកម្មវិធីរហូតមកទល់នឹងពេលបច្ចុប្បន្ន ហើយអ្នកដែលទទួលផលពិតប្រាកដ គឺសង្គមជាតិទាំងមូលដែលនឹងសំបូរទៅដោយធនធានមនុស្សពិតប្រាកដនាថ្ងៃអនាគត។

**ដ្យាក្រាមទី7៖ ការពេញចិត្តនឹងការអនុវត្តកម្មវិធីអាហារូបករណ៍របស់មន្ត្រីទទួលបន្ទុក**




ជាមួយគ្នានេះដែរ លទ្ធផលក្នុងដ្យាក្រាមទី៨ខាងក្រោម ក៏បានបញ្ជាក់ឱ្យឃើញថារាល់បាតុភាពមិនប្រក្រតី និងការតវ៉ាផ្សេងៗក្នុងដំណើរការអនុវត្តកម្មវិធីអាហារូបករណ៍នៅបឋមសិក្សានេះពុំមានបញ្ហាជាអវិជ្ជមានឡើយដោយ ៩៤ភាគរយ នៃមន្ត្រីទទួលបន្ទុកបានបញ្ជាក់ថាមិនមានការតវ៉ាណាមួយទេគឺមិនដែលលេចឮពាក្យដែលមិនប្រក្រតី ឬការតវ៉ាពីមាតាបិតា ឬអាណាព្យាបាលសិស្សឡើយ។ រីឯ ៣ភាគរយ ធ្លាប់ទទួលការតវ៉ាដោយផ្ទាល់មាត់ អំពីការបដិសេធមិនបើកប្រាក់ឱ្យសិស្សខណៈពេលដែលអវត្តមានមាតាបិតាឬអ្នកអាណាព្យាបាល និង៣ភាគរយផ្សេងទៀតឆ្លើយថាមិនច្បាស់លាស់ ដោយពុំធ្លាប់ទទួលព័ត៌មានអំពីការតវ៉ាណាមួយទេ ពាក់ព័ន្ធនឹងកម្មវិធីអាហារូបករណ៍។

### ៤.២.៦ កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍

ដើម្បីជួយសម្រួលដល់ដំណើរការនៃការអនុវត្តកម្មវិធី ឱ្យកាន់តែមានលក្ខណៈល្អប្រសើរឡើងគឺទាមទារឱ្យមានការចូលរួមពីដៃគូអភិវឌ្ឍន៍ ជាក់ស្តែងលទ្ធផលក្នុងដ្យាក្រាមទី៨ ខាងក្រោម បានបង្ហាញថា ក្នុងចំណោមអ្នកចូលរួមបំពេញកម្រងសំណួរទាំងអស់គឺមាន ៩៦ភាគរយ បានឆ្លើយថាគ្មានការចូលរួមជួយពីដៃគូអភិវឌ្ឍន៍ទេ ដោយគាត់បានបញ្ជាក់ថាអង្គការដៃគូភាគច្រើន ចាប់អារម្មណ៍ចូលរួមជួយនៅតាមបណ្តាខេត្តទេ និងបណ្តាក្រុមហ៊ុន ឬស្ថាប័នឯកជនគឺពុំចាប់អារម្មណ៍នឹងការងារអប់រំឡើយ។ ប្រការនេះគួរតែមានយុទ្ធនាការផ្សព្វផ្សាយជំរុញដោយធ្វើការយកចិត្តទុកជាពិសេស ឬសិក្សាឱ្យបានស៊ីជម្រៅលើបញ្ហានេះ ជាពិសេសប្រព័ន្ធផ្សព្វផ្សាយរដ្ឋគួរមានកម្មវិធីជំរុញទឹកចិត្តឱ្យមានការចូលរួមគាំទ្រដល់វិស័យអប់រំផង។

**ដ្យាក្រាមទី8៖ ការចូលរួមសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍**




ប៉ុន្តែទោះជាយ៉ាងណាក្តីលទ្ធផលក្នុងដ្យាក្រាមទី៩ ខាងក្រោមបានប្រាប់ឱ្យដឹងថាមានការចូលរួមជួយដល់សិស្សក្រីក្រទូទៅពីសហគមន៍មានច្រើនរូបភាពដែរគឺ ២៧ភាគរយ ជាសម្ភារៈសិក្សា ដែលជួយសិស្សជាលក្ខណៈទូទៅមិនចំពោះសិស្សណាឡើយ ហើយភាគច្រើន គឺជួយនៅពេលមានកម្មវិធីដូចជាទិវាកុមារអន្តរជាតិ ថ្ងៃបើកបវេសនកាល និងជូនសិស្សរៀនពូកែជាដើម។ ចំណែកឯ ៥ភាគរយ ផ្តល់ជាកង់ដល់សិស្សរៀនពូកែរបស់គណៈអភិបាលខណ្ឌ ខ្លះបានផ្តល់ជាមធ្យោបាយធ្វើដំណើរក្នុងពេលមានកម្មវិធីមួយចំនួនដូចជាការប្រកួតកីឡា ទស្សនៈកិច្ចសិក្សា និងជួយដឹកជញ្ជូនពេលមានកម្មវិធីជួបប្រជុំនៅតាមកម្រង និងមានផ្តល់ជាថវិកាមួយចំនួនក្នុងការចូលរួមកសាង និងអភិវឌ្ឍសាលារៀន ដែលទាំងនេះជាពន្លឺមួយដ៏ល្អក្នុងការកៀរគររកដៃគូបន្ថែម។

ដ្យាក្រាមទី៩៖ ការចូលរួមរបស់សហគមន៍




### ៤.២.៧ បញ្ហាប្រឈមនានា

លទ្ធផលនៃការស្រាវជ្រាវនេះ បានរកឃើញនូវបញ្ហាប្រឈមមួយចំនួនដែលបានអនុវត្តកម្មវិធីអាហារូបករណ៍នៅបឋមសិក្សានេះរួមមាន៖

-នៅថ្នាក់មន្ទីរ៖ ១.លំហូរកិច្ចការមានការយឺតយ៉ាវដោយសារមន្ត្រីទទួលបន្ទុកកាន់ការងារច្រើន និងខ្វះពិសោធន៍ការត្រួតពិនិត្យកិច្ចការដែលនាំឱ្យធ្វើកិច្ចការដដែលច្រើនដង ២.ពុំសូវមានការចូលរួមពីអ្នកពាក់ព័ន្ធ ដោយអាជ្ញាធរភូមិឃុំមួយចំនួនមិនចាប់អារម្មណ៍មកចូលរួមជួយ នេះក៏អាស្រ័យដោយខ្វះការទំនាក់ទំនងគ្នា ៣.គ្មានកញ្ចប់ថវិកាប្រតិបត្តិនិងពិនិត្យតាមដាន ដោយពុំមានការណែនាំឱ្យលើកនៅក្នុងផែនការប្រតិបត្តិឡើយ ៤.លក្ខខណ្ឌជ្រើសរើសមិនសមស្របចំពោះអ្នកគ្មានប័ណ្ណក្រីក្រ ដោយត្រូវមានទ្រព្យសម្បត្តិតម្លៃខ្ពស់បំផុតត្រឹម ៤០ម៉ឺនរៀល ត្រូវគ្មានអគ្គិសនីប្រើប្រាស់ ដំបូលផ្ទះត្រូវប្រក់ស្លឹកឬស្បូវជាដើម ៥.មិនមានកម្មវិធីគ្រប់គ្រងទិន្នន័យសិស្សអាហារូបករណ៍សម្រាប់ជួយសម្រួលការងារមន្ត្រីទទួលបន្ទុក ដែលត្រូវចំណាយពេលច្រើនក្នុងការធ្វើរបាយការណ៍ ឬប្រមូលទិន្នន័យម្តងៗ ៦.ការទម្លាក់សាច់ប្រាក់មិនទាន់ពេល ដោយមូលហេតុដំណើរនៃការស្នើសុំថវិកាទៅមន្ទីរសេដ្ឋកិច្ចមានការស្មុគស្មាញ និងបែបបទច្រើនពេក។

-នៅថ្នាក់ការិយាល័យអប់រំខណ្ឌ៖ ១.ពុំសូវមានការចូលរួមពីអ្នកពាក់ព័ន្ធជាពិសេសគឺអាជ្ញាធរភូមិ សង្កាត់ ដោយបានពឹងផ្អែកទាំងស្រុងតែនឹងសាលារៀន និងមិនបានលើកជាផែនការសកម្មភាពនៅថ្នាក់សង្កាត់ ២.គ្មានកញ្ចប់ថវិកាប្រតិបត្តិនិងពិនិត្យតាមដាន ដោយពុំមានការណែនាំឱ្យដាក់បញ្ចូលក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ ៣.ការទម្លាក់សាច់ប្រាក់មិនទាន់ពេល ដោយត្រូវការស្នើសុំថវិកាបីដងក្នុងមួយឆ្នាំសិក្សា ហើយពេលស្នើសុំថវិកា

ម្តងៗត្រូវការបែបបទច្រើនដំណាក់កាល ៤.និងខ្វះមន្ត្រីទទួលបន្ទុក ដែលត្រូវឱ្យមន្ត្រីម្នាក់ៗទទួលបន្ទុកការងារច្រើនផ្នែកអាចធ្វើឱ្យមានចន្លោះប្រហោងការប្រតិបត្តិការងារ។

-នៅសាលារៀន៖ ១.គ្មានឯកសារណែនាំអនុវត្ត មិនធ្លាប់ទទួលបានឯកសារណែនាំឡើយ គឺគ្រាន់តែអនុវត្តតាមទម្លាប់ និងបទពិសោធន៍ពីឆ្នាំសិក្សាមុនៗ ២.ពុំសូវមានការចូលរួមពីអ្នកពាក់ព័ន្ធ ដោយសារសមាជិកគណៈកម្មការទាំងអស់ពុំទាន់យល់ច្បាស់ពីតួនាទីរបស់ខ្លួនដែលជាហេតុមិនបានធ្វើឱ្យសកម្មភាពចូលរួមអនុវត្តកិច្ចការនេះនៅមានកម្រិត ៣.ពុំមានការបណ្តុះបណ្តាលណែនាំប្រតិបត្តិជាផ្លូវការទេ គឺគ្រាន់តែប្រជុំតៗគ្នាពីថ្នាក់មន្ទីរអប់រំរាជធានី ដល់ថ្នាក់ការិយាល័យអប់រំខណ្ឌ ហើយការិយាល័យអប់រំខណ្ឌបន្តមកដល់កម្រងសាលា ឬសាលារៀនប៉ុណ្ណោះ ៤.គ្មានកញ្ចប់ថវិកាប្រតិបត្តិនិងចុះពិនិត្យតាមដាន ដោយមិនមានការណែនាំណាមួយឱ្យច្បាស់លាស់ថា ត្រូវដកថវិកាពីខ្ទង់ណាមកចំណាយលើប្រតិបត្តិការការងារនេះ និងសម្រាប់ចុះពិនិត្យតាមដាននៅផ្ទះរបស់សិស្សក្រីក្រទេ ៥.លក្ខខណ្ឌជ្រើសរើសមិនសមស្រប ដោយភាគច្រើនសិស្សក្រីក្រនៅពុំទាន់មានប័ណ្ណក្រីក្រគ្រប់គ្នានៅឡើយ ហើយការវាយតម្លៃជ្រើសរើសសិស្សក្រីក្រ គឺមិនអាចផ្អែកតាមទ្រព្យសម្បត្តិដែលមានក្រោម ៤០ម៉ឺនរៀល នោះបានទេ ៦.ខ្វះគ្រូទទួលបន្ទុកដោយត្រូវរ៉ាប់រងដោយនាយកឬនាយិកាសាលាផ្ទាល់ដែលងាយនឹងធ្វើឱ្យខ្វះចន្លោះនៃប្រសិទ្ធភាពការងារ ៧.ការទម្លាក់សាច់ប្រាក់មិនទាន់ពេល ដែលត្រូវទាមទារឱ្យមានការស្នើសុំថវិកាច្រើនដង ហើយត្រូវការពិនិត្យ និងសម្រេចច្រើនដំណាក់កាល និងត្រូវប្រើពេលយូរ។

-សិស្ស៖ ១.គ្មានអ្នកទៅបើកប្រាក់ជាមួយ ដោយមាតាបិតាឬអ្នកអាណាព្យាបាលជាប់រវល់បំពេញការងារ ឬគ្មានមធ្យោបាយមកបាន ២.ក្រដល់ថ្ងៃបើកប្រាក់ពេក ដោយត្រូវរង់ចាំបើកប្រាក់នៅវគ្គបន្តបន្ទាប់ជាច្រើនខែពេក ដែលជាហេតុឱ្យសិស្សខ្វះខាតថវិកាសម្រាប់ផ្គត់ផ្គង់ការសិក្សាបានទាន់ពេល ៣.ពិបាករកមធ្យោបាយទៅបើកប្រាក់ នៅពេលដែលសាលាតម្រូវឱ្យទៅបើកប្រាក់រួមនៅបណ្តុំឆ្ងាយម្តងៗ។

-មាតាបិតាសិស្ស៖ ១.ពុំសូវមានពេលទៅបើកប្រាក់ជាមួយកូន ដោយជាប់បំពេញការងារប្រចាំថ្ងៃដើម្បីផ្គត់ផ្គង់គ្រួសារ ២.ក្រដល់ថ្ងៃបើកប្រាក់ពេក វគ្គបើកប្រាក់នីមួយៗមានរយៈពេលច្រើនខែ ធ្វើឱ្យមានការខ្វះខាតប្រាក់សម្រាប់ផ្គត់ផ្គង់ការសិក្សាកូនតាមតម្រូវការ ៣.អត់មធ្យោបាយទៅបើកប្រាក់ ពេលទៅបើកប្រាក់នៅកន្លែងឆ្ងាយពីសាលាម្តងៗ ៤.ពិបាករកលិខិតបញ្ជាក់ផ្សេងៗជូនសាលា ភាគច្រើនគឺមិនមានឯកសារគាំទ្រពីស្ថានភាពក្រីក្រមិនមានសៀវភៅស្នាក់នៅឱ្យត្រូវតាមអាសយដ្ឋាន ពុំសូវយល់ពីយន្តការក្នុងការស្នើសុំលិខិតបញ្ជាក់ផ្សេងៗពីអាជ្ញាធរសង្កាត់ ៥.និងត្រូវទៅមកសាលាច្រើនសារដើម្បីផ្តល់ឯកសារគាំទ្រផ្សេងៗដល់សាលា ដោយមូលហេតុមិនមានឯកសារច្បាស់លាស់។

## ៤.៣ ការពិភាក្សាលើលទ្ធផល

នៅក្នុងផ្នែកនេះ លទ្ធផលសំខាន់ៗនៃការសិក្សាស្រាវជ្រាវ ត្រូវបានលើកយកមកបង្ហាញម្តងទៀត ដោយធ្វើការពិភាក្សាជាមួយនឹងមន្ត្រីជំនាញដែលទទួលបន្ទុកការងារនេះ និងឯកសារពិគ្រោះផ្សេងៗដូចជាគោលការណ៍ណែនាំ សៀវភៅណែនាំប្រតិបត្តិ និងគោលនយោបាយរបស់រដ្ឋាភិបាលផងដែរ។

លទ្ធផលស្រាវជ្រាវបង្ហាញថា ៨៣.៣ភាគរយ ទទួលព័ត៌មានស្តីពីការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ តាមរយៈលោកគ្រូ អ្នកគ្រូ និងពេលគោរពទង់ជាតិ ឬបិទផ្សាយព័ត៌មានតាមក្តារខៀននៅសាលារៀន ជាការផ្សព្វផ្សាយមានប្រសិទ្ធភាពជាងគេបំផុត ខណៈត្រឹមតែ ១៦.៧ភាគរយ ប៉ុណ្ណោះ បានដឹងព័ត៌មានតាមរយៈភូមិ សង្កាត់ ឬអាជ្ញាធរ។ ការរកឃើញមួយទៀតបានបង្ហាញថា ការចុះផ្ទៀងផ្ទាត់នៅតាមខ្ទង់ផ្ទះរបស់គណៈកម្មការមូលដ្ឋាន មានតែ ១២.១ភាគរយ ក្នុងចំណោមសិស្សទាំងអស់ ដូច្នេះនាំឱ្យការជ្រើសរើសសិស្សអាហារូបករណ៍ពុំបានចំគោលដៅពិតប្រាកដទេ។ ទន្ទឹមនឹងនេះដែរ សិស្សដែលទទួលបានអាហារូបករណ៍សិស្សក្រីក្រនៅក្នុងសាលាបឋមសិក្សាទាំង៧ គឺត្រូវបានជ្រើសរើសដោយផ្អែកលើលក្ខណៈវិនិច្ឆ័យយ៉ាងតឹងរឹង ដើម្បីឱ្យមានសុក្រឹតភាព និងត្រូវគោលដៅដោយផ្អែកលើស្ថានភាពគ្រួសារ វត្តមាននៃការសិក្សារបស់សិស្សដែលត្រូវមករៀនឱ្យបាន ៨០ភាគរយ និងរៀនជាប់មធ្យមភាគ ត្រូវមានបណ្ណគ្រួសារក្រីក្រប្រភេទទី១ ឬទី២ ឬមានស្ថានភាពប្រហាក់ប្រហែល និងមិនមែនជាសិស្សដែលកំពុងទទួលបានការឧបត្ថម្ភអាហារូបករណ៍ស្ថាប័នដទៃ។ លទ្ធផលបង្ហាញថាលក្ខណៈវិនិច្ឆ័យដែលសាលាបានប្រើភាគច្រើនសម្រាប់ជ្រើសរើសសិស្ស គឺខាងសាលាបានសហការជាគ្រូប្រចាំថ្នាក់ដោយពិនិត្យមើលពីស្ថានភាពសិស្សដែលមករៀនរាល់ថ្ងៃ និងសិស្សដែលឧស្សាហ៍អវត្តមាន បន្ទាប់អញ្ជើញមាតាបិតា ឬអ្នកអាណាព្យាបាលមកជួបដោយផ្ទាល់នៅសាលារៀន។ យ៉ាងណាមិញ Cameron(2000) ដែលបានធ្វើការសិក្សានៅឥណ្ឌូនេស៊ីអំពីកម្មវិធីអាហារូបករណ៍សិស្សក្រីក្របានលើកឡើងថា ការជ្រើសរើសសិស្សនៅតាមគ្រួសារគោលដៅគឺត្រូវធ្វើតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់ ក៏ប៉ុន្តែវានៅតែខ្វះចន្លោះដោយមិនបានបង្ហាញឱ្យច្បាស់លាស់ អំពីចំណូលគ្រួសារសិស្សដែលត្រូវបានជ្រើសរើសឱ្យបានទទួលអាហារូបករណ៍សិស្សក្រីក្រ។ លទ្ធផលនៃការស្រាវជ្រាវក៏បានបង្ហាញថា ការផ្តល់អាហារូបករណ៍សិស្សក្រីក្រដល់គ្រឹះស្ថានតាមចំនួនជាក់លាក់មួយដើម្បីលើកកម្ពស់សមភាពយេនឌ័រ ក្នុងនោះចំនួនសិស្សស្រីមាន ៦០% និងសិស្សប្រុសចំនួន ៤០%។ ហេតុផលដែលគិតថាការផ្តល់អាទិភាពឱ្យសិស្សស្រីច្រើនជាងសិស្សប្រុស ដោយសារ

សិស្សស្រីជាសិស្សងាយរងការបោះបង់ការសិក្សា តែលទ្ធផលសិក្សាល្អជាងសិស្សប្រុស។ នេះអាចជាប់ពាក់ព័ន្ធនឹងគោលការណ៍របស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការលើកកម្ពស់ និងផ្តល់ឱកាសឱ្យសិស្សស្រីបានចូលរៀន និងបញ្ចប់ការសិក្សា ដែលអាចជាហេតុនាំឱ្យចំនួនសិស្សស្រីជាប់អាហារូបករណ៍ច្រើនជាងសិស្សប្រុស។ មិនខុសគ្នាដែរ Hasan(2010) បង្ហាញថាកម្មវិធីអាហារូបករណ៍សិស្សក្រីក្រ គឺទទួលបានជោគជ័យក្នុងការបង្កើនការចុះឈ្មោះចូលរៀនរបស់ក្មេងស្រីនៅក្នុងថ្នាក់ទី១ ទៅទី៦ ដូចដែលបានគ្រោងទុក។ ការបង្កើនអត្រាចូលរៀនរបស់សិស្សស្រី គឺជាបញ្ហាប្រឈមមួយនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន ហើយ Filmer and Schady(2006) បានធ្វើការវាយតម្លៃ ទៅលើផលប៉ះពាល់នៃកម្មវិធីអាហារូបករណ៍ដល់ក្មេងស្រី ដែលធ្វើឱ្យមានការផ្លាស់ប្តូររវាងចុងឆ្នាំក្រោយនៃឆ្នាំសិក្សានៅកម្រិតថ្នាក់បឋមសិក្សា និងដើមឆ្នាំនៃអនុវិទ្យាល័យនៅកម្ពុជា។ លទ្ធផលបង្ហាញថាកម្មវិធីអាហារូបករណ៍មានឥទ្ធិពលវិជ្ជមានដល់ការចុះឈ្មោះចូលរៀន និងការចូលរួមរបស់ក្មេងស្រីដែលមានកំណើន ៣០ ទៅ ៤០ភាគរយ។ កម្មវិធីនេះបានជួយឱ្យសិស្សស្រីដែលស្ថិតនៅក្នុងគ្រួសារដែលមានជីវភាពខ្សត់ខ្សោយឱ្យទទួលបានឱកាសសិក្សា។

ការស្រាវជ្រាវបានរកឃើញថា សាលាបឋមសិក្សាទាំង៧នេះ បានផ្តល់នូវចំនួនប្រាក់អាហារូបករណ៍ចំនួន ២៤០ ០០០រៀល ឱ្យទៅសិស្សម្នាក់ៗដែលបានទទួលអាហារូបករណ៍ក្រីក្រ សម្រាប់ផ្គត់ផ្គង់ការសិក្សាពេញមួយឆ្នាំ។ ម្យ៉ាងវិញទៀត ការបើកប្រាក់អាហារូបករណ៍ គឺបានធ្វើឡើងចំនួន ៣លើក ស្របតាមគោលការណ៍ណែនាំ។ ជារួមអាចធ្វើបានសន្និដ្ឋានបានថា ការអនុវត្តគម្រោងសិស្សអាហារូបករណ៍ក្រីក្រគឺមានប្រសិទ្ធភាពល្អកម្រិតមធ្យម។ ក៏ប៉ុន្តែការរកឃើញរបស់ Ahmed et. al.,(2006) បង្ហាញថាប្រសិទ្ធភាពនៃការអនុវត្តគម្រោង គឺមានទាំងប្រយោល និងដោយផ្ទាល់ ដោយក្នុងនោះលទ្ធផលបង្ហាញថាការចុះឈ្មោះចូលរៀនរបស់កុមារដែលមានអាយុពី៦ ដល់១៤ឆ្នាំ គឺមានកំនើនតិចតួច ដែលនេះបង្ហាញថាវាមានផលវិជ្ជមានតិចតួច។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងសំណូមពរ

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១- សេចក្តីសន្និដ្ឋាន

ការសិក្សាស្តីពី ការអនុវត្ត និងបញ្ហាប្រឈមនៃកម្មវិធីអាហារូបករណ៍សិស្សក្រីក្រ នៅបឋមសិក្សាក្នុងរាជធានីភ្នំពេញ ដែលបានការចូលរួមពីអ្នកពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ និងលទ្ធផលស្រាវជ្រាវបង្ហាញលទ្ធផលជាវិជ្ជមាន ដែលបានឆ្លុះបញ្ចាំងយ៉ាងច្បាស់ពីស្ថានភាពជាក់ស្តែងពីថ្នាក់មូលដ្ឋាន ព្រមទាំងបានផ្តល់ជាព័ត៌មានដ៏មានសារៈសំខាន់ដល់មន្ត្រីអនុវត្តផ្ទាល់។ តាមរយៈលទ្ធផលនៃការស្រាវជ្រាវ និងឆ្លងកាត់ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធលើលទ្ធផលនេះ អ្នកស្រាវជ្រាវអាចសន្និដ្ឋានបានថាការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ គួរត្រូវបានធ្វើការបញ្ជាក់ពីលក្ខខណ្ឌនៃការជ្រើសរើសមួយចំនួនឱ្យបានច្បាស់លាស់ ដោយមិនត្រូវពឹងផ្អែកទាំងស្រុងទៅប័ណ្ណក្រីក្រ និងមិនត្រូវកំណត់ចំនួននៅតាមសាលារៀនគោលដៅឡើយ ពោលគឺត្រូវផ្អែកលើភាពជាក់ស្តែងពិតប្រាកដ និងបង្កើតកញ្ចប់ថវិកាក្នុងដំណើរការចុះពិនិត្យជាក់ស្តែងតាមផ្ទះរបស់សិស្ស ដើម្បីវាយតម្លៃជ្រើសរើសឱ្យចំគោលដៅពិតប្រាកដ។ លើសពីនេះទៀត ការយល់ឃើញរបស់សិស្ស និងមាតាបិតាឬអ្នកអាណាព្យាបាលសិស្សដែលទទួលបានអាហារូបករណ៍ ចំពោះការផ្តល់អាហារូបករណ៍សិស្សក្រីក្រមានការពេញចិត្តបង្គួរហូតដល់ទៅ ៧០ភាគរយ តាមរយៈលទ្ធផលនេះ អ្នកសិក្សាស្រាវជ្រាវអាចធ្វើការសន្និដ្ឋានថា ដំណើរការ និងយន្តការនៃការផ្តល់អាហារូបករណ៍មានលក្ខណៈល្អ មានប្រសិទ្ធភាពខ្ពស់ដែលអាចទទួលយកបានលើសពី ៥០ ភាគរយ។ ការផ្តល់អាហារូបករណ៍នេះ គួរគិតទៅលើទីតាំងរបស់សាលារៀនជាជាងទំហំសាលារៀន ហើយការផ្តល់អាហារូបករណ៍គួរផ្តល់ទៅគ្រួសារក្រីក្រដែលមានកូនកំពុងសិក្សាច្រើន ក្នុងមួយគ្រួសារពី ២ ទៅ ៣នាក់ តាមការវាយតម្លៃជាក់ស្តែងរបស់គណៈកម្មការគ្រប់គ្រងអាហារូបករណ៍មូលដ្ឋាន ដោយផ្តល់មិនត្រឹមតែជាថវិកាប៉ុណ្ណោះទេ ថែមទាំងផ្តល់ជាសម្ភារៈសិក្សាបន្ថែមទៀត។ តាមលទ្ធផលនៃការសិក្សាស្រាវជ្រាវបង្ហាញថា ការប្រើប្រាស់ប្រាក់អាហារូបករណ៍របស់សិស្សបានត្រឹមត្រូវល្អ ដោយបានប្រើប្រាក់អាហារូបករណ៍នោះទៅលើការទិញសម្ភារៈសិក្សារហូតដល់ ៨៣ភាគរយ និងការចំណាយបន្ទាប់ទៅលើការផ្គត់ផ្គង់គ្រួសារ និងមធ្យោបាយធ្វើដំណើរ ១៧ភាគរយ។ ទន្ទឹមនឹងនេះដែរ លទ្ធផលស្រាវជ្រាវនេះ ក៏បង្ហាញពីភាពលេចធ្លោលើការផ្សព្វផ្សាយព័ត៌មានស្តីអំពីអាហារូបករណ៍សិស្សក្រីក្រ គឺការផ្សព្វផ្សាយព័ត៌មានតាមរយៈលោកគ្រូ អ្នកគ្រូ ដែលមានប្រសិទ្ធភាពជាងគេ ក្នុងចំណោមការប្រជុំ ការបណ្តុះបណ្តាល ការប្រជុំនៅសាលាតាមភូមិស្រុក ក្រុមប្រឹក្សាឃុំ សង្កាត់ ការបិទផ្ទាំងរូបភាព។ ហើយចំណុចប្រឈមលើ

ការងារផ្សព្វផ្សាយ ឬប្រតិបត្តិរបស់គណៈកម្មការគ្រប់គ្រងអាហារូបករណ៍ថ្នាក់ក្រោមជាតិ និងថ្នាក់មូលដ្ឋានគឺពុំមានថវិកាគ្រប់គ្រាន់ក្នុងការចំណាយលើការពិនិត្យតាមដាន លើកិច្ចការរដ្ឋបាល ថតចម្លងឯកសារក្នុងការផ្សព្វផ្សាយឱ្យបានទូលំទូលាយ ជាពិសេសលើការកំណត់ស្ថានភាពសិស្សអាហារូបករណ៍ កំព្រា ពិការ កម្រិតក្រីក្រ និងជនជាតិភាគតិច។ ការផ្សព្វផ្សាយពីសារសំខាន់នៃកម្មវិធីអាហារូបករណ៍ ការបណ្តុះបណ្តាលមន្ត្រីគ្រប់គ្រងអាហារូបករណ៍ និងការផ្លាស់ប្តូរញឹកញាប់ពេករបស់សមាសភាពមន្ត្រី ឬគណៈកម្មការជាហេតុធ្វើឱ្យការធ្វើឱ្យដំណើរការប្រព្រឹត្តទៅនៃកម្មវិធីទាំងមូលពុំសូវមានប្រសិទ្ធភាព។ នេះបើតាមលទ្ធផលស្រាវជ្រាវបង្ហាញថា ចំនួនសិស្សនិងមាតាបិតាសិស្សដែលបានចូលរួមបំពេញកម្រងសំណួរ ៨៨ភាគរយឆ្លើយថា គណៈកម្មការគ្រប់គ្រងអាហារូកបរណ៍មូលដ្ឋានមិនដែលធ្លាប់ចុះតាមដាន និងមានតែ ១២ភាគរយ ឆ្លើយថាបានចុះពិនិត្យតាមដាន។ ទន្ទឹមនឹងការខ្វះខាត ការសិក្សានេះក៏រកឃើញនូវចំណុចខ្លាំងផងដែរ ទាក់ទងនឹងការផ្តល់ប្រាក់អាហារូបករណ៍ទៅដល់សិស្សស្រីច្រើនជាងសិស្សប្រុស មានការយល់ស្របរហូត ៦៩ភាគរយ និងមិនយល់ស្រប ៣១ភាគរយ ព្រមទាំង ៨៩ភាគរយ នៃសិស្សដែលទទួលបានអាហារូបករណ៍រួមនឹងមាតាបិតាឬអ្នកអាណាព្យាបាលសិស្សឆ្លើយថា នៅតែសិក្សាបន្តរហូតចប់ថ្នាក់ទី១២ ទោះបីជាគ្មានអាហារូបករណ៍ក៏ដោយ។ ទោះជាយ៉ាងណាក្តី សិស្សដែលទទួលអាហារូបករណ៍ហើយនៅតែបោះបង់ការសិក្សា បណ្តាលមកពីមូលហេតុដូចជា កត្តាជីវភាពសិស្សក្នុងគ្រួសារក្រីក្រ ចំនួនថវិកាតិចតួច ហើយផ្តល់មិនទាន់ពេលវេលា គ្រួសារមិនផ្តល់តម្លៃដល់ការអប់រំ ទៅធ្វើការតាមរោងចក្រ តាមមិត្តភក្តិ(ទោះមិនគ្រប់អាយុ) ចំណាកស្រុក ឬផ្លាស់ប្តូរទីលំនៅ កត្តាទីតាំងភូមិសាស្ត្រ ឬសិស្សដែលមានសាលាឆ្ងាយពីផ្ទះ គ្មានមធ្យោបាយធ្វើដំណើរ កត្តាសុខភាព(សិស្សអាហារូបករណ៍ ឬឪពុកម្តាយ) រៀនមិនទាន់គេ គ្មានមូលដ្ឋានគ្រឹះពីថ្នាក់ក្រោម អំពើហិង្សាក្នុងគ្រួសារ ខ្វះការពិនិត្យតាមដានលើកទឹកចិត្ត និងជំរុញពីអាណាព្យាបាល។

សរុបសេចក្តីមក ការអនុវត្តកម្មវិធីអាហារូបករណ៍នៅបឋមសិក្សា ក្នុងរាជធានីភ្នំពេញមានលក្ខណៈល្អកម្រិតមធ្យម ប៉ុន្តែជារួមសង្កេតឃើញថាការផ្តល់ប្រាក់អាហារូបករណ៍សិស្សក្រីក្រនេះ ពិតជាបានជួយសម្រួលដល់សិស្សក្នុងការបន្តការសិក្សារបស់រហូតដល់បញ្ចប់ភូមិសិក្សា កាត់បន្ថយអត្រាបោះបង់ការសិក្សា និងអត្រាត្រួតថ្នាក់របស់សិស្សក្រីក្រ ជាពិសេសសិស្សស្រីផងដែរ ព្រមទាំងបានជំរុញសិស្សក្រីក្រទាំងនោះឱ្យបន្តការសិក្សានៅភូមិសិក្សាជាបន្តបន្ទាប់។

## ៥.២- សំណូមពរ និងអនុសាសន៍

ការសិក្សាស្រាវជ្រាវនេះក៏បានសួរអំពីសំណូមពររបស់សិស្ស មាតាបិតាឬអ្នកអាណាព្យាបាលសិស្ស និងគណៈកម្មការគ្រប់គ្រងអាហារូបករណ៍ផងដែរ។ ជាលទ្ធផល

បានរកឃើញនូវសំណូមពរមួយចំនួនពីការអនុវត្តកម្មវិធីនេះផងដែររួមមាន៖ (១)សុំឱ្យបន្តការផ្តល់ប្រាក់អាហារូបករណ៍ ដោយអ្នកចូលរួមបំពេញកម្រងសំណួរទាំងអស់បានគាំទ្រឱ្យបន្តអនុវត្តកម្មវិធីអាហារូបករណ៍នេះនាឆ្នាំសិក្សាក្រោយៗទៀត ដើម្បីចូលរួមចំណែកក្នុងការជួយឱ្យសិស្សក្រីក្រមានឱកាសបន្តការសិក្សាដោយជោគជ័យ និងបានជួយមាតាបិតាឬអ្នកអាណាព្យាបាលសិស្សក្រីក្រមួយផ្នែកធំ លើការចំណាយក្នុងការសិក្សារបស់កូនៗគាត់ លើសពីនេះទៀតគឺបានជួយជំរុញសូចនាករលទ្ធផលសិក្សារបស់សិស្សឱ្យកាន់តែល្អប្រសើរឡើងផងដែរ (២)បន្តបើកប្រាក់ឱ្យសិស្សអាហារូបករណ៍រៀនខ្សោយដែលខំមករៀនជាប្រចាំផង ដើម្បីរក្សាពួកគេឱ្យស្ថិតក្នុងប្រព័ន្ធអប់រំ ក៏ដូចជាការផ្តល់ឱកាស ពេលវេលាបន្ថែម ឬការលើកទឹកចិត្តគេឱ្យខិតខំរៀនសូត្របន្ថែមទៀតបើទោះបីជាកម្រិតលូតលាស់ផ្នែកបញ្ញា ឬការចងចាំខ្សោយក៏ដោយ (៣)កែសម្រួលចំនួនសិស្សអាហារូបករណ៍នៅតាមសាលារៀនគោលដៅតាមស្ថានភាពជាក់ស្តែង ព្រោះការកំណត់ចំនួនដោយផ្អែកលើទំហំសាលារៀន គឺមិនត្រឹមត្រូវតាមស្ថានភាពជាក់ស្តែងដែលមានទេ (៤)សុំឱ្យទម្លាក់ថវិកាលើកទី១នៅខែវិច្ឆិកា ដើម្បីឱ្យសិស្សក្រីក្រមានសម្ភារៈសិក្សា និងមានសម្លៀកបំពាក់គ្រប់គ្រាន់នៅដើមឆ្នាំសិក្សា ព្រោះវេលានេះ គឺជំរុញទឹកចិត្តពួកគេឱ្យខិតខំរៀនសូត្របានពូកែ ដោយសេចក្តីសប្បាយរីករាយដូចសិស្សដទៃទៀត និងបណ្តុះស្មារតីឱ្យពួកគេចង់មកសាលារៀន (៥)ពិនិត្យកែសម្រួលលើសមាសភាពគណៈកម្មការនីមួយៗដោយកំណត់ពីតួនាទីភារកិច្ចទទួលខុសត្រូវឱ្យបានច្បាស់លាស់ងាយស្រួលអនុវត្ត និងឆ្លុះបញ្ចាំងបានសមស្របដើម្បីពង្រឹងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធី (៦)ធ្វើបច្ចុប្បន្នភាពសៀវភៅណែនាំប្រតិបត្តិ និងរៀបចំឱ្យមានប្រព័ន្ធព័ត៌មានគ្រប់គ្រងកម្មវិធី ដោយកែសម្រួលលិខិតបទដ្ឋានឱ្យនៅតិចបំផុត ព្រោះដើម្បីកាត់បន្ថយទំហំការងារ និងពេលវេលានៃការប្រតិបត្តិដល់មន្ត្រីទទួលបន្ទុក ក៏ដូចជាកាត់បន្ថយបន្ទុកចំណាយផ្សេងៗដែលទាក់ទងនឹងដំណើរការលើលិខិតបទដ្ឋានទាំងនោះ និងអាចឆ្លើយតបព័ត៌មានត្រឡប់បានឆាប់រហ័សទៅនឹងតម្រូវការជាក់ស្តែង (៧)បណ្តុះបណ្តាលពីនីតិវិធីនានាក្នុងការប្រតិបត្តិតាមសៀវភៅណែនាំ ដើម្បីឱ្យការអនុវត្តការងារកាន់តែមានសុក្រឹតភាព តម្លាភាព និងកាត់បន្ថយកំហុសឆ្គងដោយអចេតនាដោយប្រការណាមួយ (៨)កែសម្រួលលក្ខខណ្ឌជ្រើសរើសឱ្យស្របតាមស្ថានភាពជាក់ស្តែង ឬប្រគល់ភារកិច្ចនេះទៅឱ្យគណៈកម្មការនៅថ្នាក់អាជ្ញាធរសង្កាត់ជាអ្នកចេញលិខិតបញ្ជាក់ពីស្ថានភាពក្រីក្រ(IDpoor) ដែលនឹងត្រូវជ្រើសរើស (៩)បង្កើតឱ្យមានកម្មវិធីប្រជុំអន្តរក្រសួង និងអ្នកពាក់ព័ន្ធដើម្បីសម្រួលបែបបទនៃការរៀបចំឯកសារដំណើរការនានា ឱ្យមានប្រសិទ្ធភាព ចំណេញពេលវេលា និងងាយស្រួលអនុវត្តបានពីគ្រប់អ្នកពាក់ព័ន្ធ (១០)បង្កើនចំនួនថវិកាអាហារូបករណ៍ឱ្យសមស្របតាម

ស្ថានភាពសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន ដើម្បីបំពេញនូវកង្វះខាតផ្នែកសម្ភារៈសិក្សា និងសម្លៀកបំពាក់របស់សិស្សក្រីក្រដែលនៅតែជួបប្រទះ និង(១១)បង្កើតឱ្យមានកញ្ចប់ថវិកាប្រតិបត្តិគាំទ្រ ព្រោះដើម្បីធានាឱ្យដំណើរការប្រព្រឹត្តទៅនៃកម្មវិធីទាំងមូលទទួលបានជោគជ័យខ្ពស់ ស្របតាមគោលនយោបាយជាតិនៃការអប់រំ។

ដូចនេះដោយផ្អែកតាមសំណូមពរដូចមានខាងលើនេះ បានបង្ហាញឱ្យឃើញថាពិតជាមានតម្រូវការចាំបាច់ក្នុងបន្តអនុវត្តកម្មវិធីអាហារូបករណ៍សិស្សក្រីក្រ តទៅទៀតណាស់ ហើយដើម្បីបន្តការអនុវត្តនេះគប្បីពិនិត្យមើលឡើងវិញពីការបង្កើនកញ្ចប់ថវិកាសម្រាប់ក្រុមការងារអនុវត្តកម្មវិធី គឺជាតម្រូវការចាំបាច់ដែលត្រូវដោះស្រាយ ដើម្បីឱ្យគម្រោងនេះកាន់តែមានប្រសិទ្ធភាពខ្ពស់។ ព្រោះថាបើមានថវិកាឧបត្ថម្ភដល់មន្ត្រីអនុវត្តកម្មវិធីគឺអាចជួយជំរុញ និងសម្រួល ព្រមទាំងបង្កលក្ខណៈងាយស្រួលដល់មន្ត្រីក្នុងការចុះតាមដាន និងត្រួតពិនិត្យការងារ រីឯសិស្សក៏អាចនឹងមានភាពងាយស្រួលក្នុងការបំពេញតម្រូវការសិក្សារបស់គេផងដែរ។ ជាងនេះទៅទៀត ការបើកប្រាក់ឱ្យសិស្សអាហារូបករណ៍ក្រីក្រដែលរៀនខ្សោយ ហើយបានខិតខំមករៀនសូត្រជាប្រចាំគួរត្រូវបានអនុវត្តដើម្បីជាការលើកទឹកចិត្ត ក៏ដូចជាការជំរុញពួកគេឱ្យខិតខំរៀនសូត្របន្ថែម ក្រោមការបង្ហាត់បង្រៀនពីលោកគ្រូ អ្នកគ្រូ និងមាតាបិតាឬអ្នកអាណាព្យាបាលដោយការយកចិត្តទុកដាក់។

យោងតាមលទ្ធផលនៃការស្រាវជ្រាវ ដើម្បីឱ្យការផ្តល់អាហារូបករណ៍សិស្សក្រីក្រកាន់ទទួលបានប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់ គួរអនុវត្តដូចខាងក្រោម៖

-គួររៀបចំជាអនុគណៈកម្មការរួមមួយនៅកម្រិតថ្នាក់ខណ្ឌ ក្នុងការចុះពិនិត្យនិងវាយតម្លៃស្ថានភាពគ្រួសារសិស្សនៅតាមផ្ទះដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋានផង ដើម្បីពិនិត្យផ្ទៀងផ្ទាត់ពីស្ថានភាពក្រីក្រជាក់ស្តែងឱ្យស្របតាមលក្ខខណ្ឌក្នុងការជ្រើសរើស និងចុះជួយសម្របសម្រួលព្រមទាំងជំរុញបន្ថែមក្នុងការសិក្សារៀនសូត្ររបស់សិស្ស

-ការជ្រើសរើសសិស្សអាហារូបករណ៍ក្រីក្រ គួរត្រូវបានវាយតម្លៃនៅត្រឹមកម្រិតថ្នាក់ខណ្ឌ ដើម្បីកាត់បន្ថយពេលវេលា និងយន្តការការងារឱ្យដល់ថ្នាក់មូលដ្ឋានក្នុងការសម្រេចចិត្តជ្រើសរើសសិស្សដោយផ្អែកលើស្ថានភាពក្រីក្រជាក់ស្តែង

-គួរធ្វើការពង្រាយចំនួនសិស្សឱ្យបានច្រើនសាលាបន្ថែមទៀត ទៅតាមស្ថានភាពជាក់ស្តែង ដោយសាលារៀនជាច្រើនទៀតមានសិស្សក្រីក្រជួបការលំបាកជាច្រើននាក់ស្របតាមលក្ខខណ្ឌដែរ តែនៅមិនទាន់មានកម្មវិធីអាហារូបករណ៍បានផ្តល់ជូន

-គួរធ្វើបច្ចុប្បន្នកម្មសៀវភៅណែនាំប្រតិបត្តិស្តីពីកម្មវិធីអាហារូបករណ៍សិស្សក្រីក្រ និងបង្កើតឱ្យមានប្រព័ន្ធព័ត៌មានគ្រប់គ្រងកម្មវិធី ដើម្បីកែប្រែនីតិវិធីមួយចំនួនឱ្យមានភាពងាយស្រួលអនុវត្ត និងសមស្របតាមស្ថានភាពនៃការអនុវត្តនាពេលកន្លងមក

-គួរមានកម្មវិធីបណ្ដុះបណ្ដាលដើម្បីពង្រឹងសមត្ថភាព និងយន្តការការងាររបស់មន្ត្រីទទួលបន្ទុក ដោយសារកម្មវិធីអាហារូបករណ៍សិស្សក្រីក្រនេះមាននីតិវិធី បែបបទស្មុគស្មាញ និងច្រើនដំណាក់កាល ដែលទាមទារឱ្យមន្ត្រីអនុវត្តការងារនេះមានការយល់ដឹងច្បាស់លាស់ និងបទពិសោធន៍គ្រប់គ្រាន់ដើម្បីបំពេញកិច្ចការនេះទទួលជោគជ័យ និងប្រកបដោយប្រសិទ្ធភាពខ្ពស់
-គួរផ្ដល់ភារកិច្ចដល់គណៈកម្មការនៅមូលដ្ឋានសង្កាត់ចេញជាលិខិតបញ្ជាក់ពីស្ថានក្រីក្រ (IDpoor) ក្រោមកិច្ចសហការ និងទទួលស្គាល់ដោយក្រសួងជំនាញ ដើម្បីជ្រើសរើសបាននូវសិស្សដែលមានតម្រូវការថវិកាពិតប្រាកដ ហើយត្រូវការកិច្ចគាំពារពីរាជរដ្ឋាភិបាល ដើម្បីបន្តការសិក្សារបស់ពួកគេឱ្យបានដល់គោលដៅ នៃគោលនយោបាយជាតិស្ដីពីការអប់រំ
-គួរមានកម្មវិធីប្រជុំអន្តរក្រសួង និងអ្នកពាក់ព័ន្ធដើម្បីសម្រួលបែបបទ នៃការរៀបចំឯកសារអាហារូបករណ៍ឱ្យបានស៊ីសង្វាក់គ្នាតាមឋានុក្រម និងជាមួយក្រសួងពាក់ព័ន្ធ ពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីទម្លាក់ថវិកាឱ្យបានទៀងទាត់ និងទាន់ពេលដែលជាតម្រូវការចាំបាច់របស់សិស្ស
-គួរមានកញ្ចប់ថវិកាសម្រាប់ដំណើរការគណៈកម្មការអាហារូបករណ៍ថ្នាក់មូលដ្ឋាន ថ្នាក់ខណ្ឌ និងរាជធានី ដើម្បីដោះស្រាយនូវមុខចំណាយមួយចំនួនដែលទាក់ទងនឹងកម្មវិធីអាហារូបករណ៍ ហើយដែលមិនអាចដកខ្ទង់ចំណាយផ្សេងមកប្រើប្រាស់ជំនួសបាន ដូចជាការចុះពិនិត្យតាមដានដល់ផ្ទះសិស្ស ការប្រជុំប្រចាំខែរបស់គណៈកម្មការអាហារូបករណ៍ និងការធ្វើដំណើរទៅមកក្នុងដំណើរការការងារអារូបករណ៍ជាដើម។

ក្នុងនោះដែរក្រៅពីសំណូមពរ និងអនុសាសន៍ពីគ្រប់ភាគីដែលពាក់ព័ន្ធ អ្នកសិក្សាស្រាវជ្រាវក៏មានសំណូមពរមួយចំនួនផងដែរដូចជា៖
-គួរជួយសម្រួលឯកសារផ្សេងៗ ដូចជាបញ្ជីឈ្មោះសិស្សអាហារូបករណ៍ បញ្ជីបើកថវិកាអាហារូបករណ៍ឱ្យមានចំនួនកាន់តិច កាន់តែប្រសើរ ជាពិសេសគឺចងប្រព័ន្ធកូដនៅក្នុងកុំព្យូទ័រដើម្បីផ្ដល់ភាពងាយស្រួលដល់មន្ត្រីគ្រប់គ្រងទិន្នន័យ
-គួរកាត់បន្ថយយន្តការស្មុគស្មាញមួយចំនួនទាំងឯកសារបើកប្រាក់ ការរៀបចំនៅមន្ទីរសាមី និងនៅរតនាគារជាតិ ដើម្បីពន្លឿនការបើកប្រាក់ជូនសិស្សឱ្យបានទៀងទាត់ និងទាន់ពេលវេលា
-គួរបង្កើតប្រព័ន្ធបើកថវិកាដល់សិស្សដោយប្រព័ន្ធកុំព្យូទ័រ ឬវីង ឬតាមធនាគារ ដើម្បីជៀសជាងបើកប្រាក់ដោយផ្ទាល់ និងកាត់បន្ថយហានីភ័យដែលអាចកើតមានដល់មន្ត្រីទទួលបន្ទុកការបើកប្រាក់ និងការរំខានពេលវេលាច្រើនក្នុងការមកបើកប្រាក់របស់មាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស។

# ឯកសារយោង

# ឯកសារយោង

- យ៉ង់ ឌី និង ស៊ន សំណាង(១៩៩៨-១៩៩៩)៖ ប្រវត្តិនៃការអប់រំ បឋម និងមធ្យមសិក្សា នៅកម្ពុជា
- រាជរដ្ឋាភិបាលកម្ពុជា(២០១៥)៖ អនុក្រឹត្យលេខ ៣៤ ស្តីពី ការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រនៅបឋមសិក្សា និងមធ្យមសិក្សាចំណេះទូទៅ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ ២០១៥
- ក្រសួងអប់រំ យុវជន និងកីឡា(២០១៥)៖ ប្រកាសលេខ ២៥៥៧ ស្តីពី ការកំណត់លក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រនៅបឋមសិក្សា និងមធ្យមសិក្សាចំណេះទូទៅ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥
- នាយកដ្ឋានបឋមសិក្សា(២០១៥)៖ កម្មវិធីផ្តល់អាហារូបករណ៍នៅបឋមសិក្សា"សៀវភៅណែនាំប្រតិបត្តិការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រនៅបឋមសិក្សា"
- នាយកដ្ឋានបឋមសិក្សា(២០១៥)៖ កម្មវិធីអាហារូបករណ៍នៅបឋមសិក្សា
- ហាង់ជួន ណារ៉ុន(២០១៦)៖ កំណែទម្រង់វិស័យអប់រំនៅកម្ពុជា, មាគ៌ាឆ្ពោះទៅរកសង្គមពុទ្ធិ និងវិបុលភាព
- ក្រសួងអប់រំ យុវជន និងកីឡា(២០១៧)៖ សន្និបាតបូកសរុបការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា ២០១៥-២០១៦ និងទិសដៅឆ្នាំសិក្សា ២០១៦-២០១៧
- មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ(២០១៧)៖ របាយការណ៍បូកសរុបវាយតម្លៃការងារអប់រំ ឆ្នាំសិក្សា ២០១៥-២០១៦ និងទិសដៅឆ្នាំសិក្សា ២០១៦-២០១៧
- ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(២០១៨)៖ ប្រកាសអន្តរក្រសួងលេខ ១២៤៥ ស្តីពី ការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រថ្នាក់ទី ១ ទី២ និងថ្នាក់ទី៣ ចុះថ្ងៃទី០៦ វិច្ឆិកា ឆ្នាំ២០១៨
- ក្រសួងអប់រំ យុវជន និងកីឡា(២០១៩)៖ ក្របខណ្ឌអាហារូបករណ៍ផ្តោតលើគោលការណ៍សមធម៌នៅបឋមសិក្សា
- វីគីនានុក្រម(2019), https://km.wiktionary.org/wiki/
- USAID(2006), កម្មវិធីអាហារូបករណ៍ហៅទីបានទទួលមូលនិធិពី USAID
- Asia-Pacific Economic Coorpoeration(2015), Current Thai Education Policies and Reform
- Chansopheak, K. (2009). Basic education in Cambodia: Quality and equity. In The Political Economy of Educational Reforms and Capacity Development in Southeast Asia (pp. 131-152). Springer Netherlands.
- Bangkok, U. N. E. S. C. O. (2008). Secondary Education Regional Information Base: Country Profile-Cambodia. Ministry of Education and Training.
